**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Économiques**

**Royal university of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ការស្នងមត៌កតាមច្បាប់
# នៅក្នុងព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ៖ **ក. ជុង សំណាងមាស**

**ក. ទួន រក្សា**

សាស្ត្រាចារ្យណែនាំ

**លោក ឡឿក ពិដោរ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលរៀន ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ ជុង សំណាងមាស និង ទូន រក្សា ជានិស្សិតឆ្នាំទី៤ ថ្នាក់ L4A2 នៃថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៧-២០២១ ។

**សូមថ្លែងអំណរអគុណ និងសម្តែងនូវកត្តញ្ញូតាធម៌ដ៏ធំធេងបំផុតជូនចំពោះ**

លោកឪពុក អ្នកម្តាយ និងក្រុមគ្រួសារជាទីគោរពស្រឡាញ់របស់កូន ដែលលោកអ្នកមានគុណបានផ្តល់កំណើតដល់រូបកូន រួមទាំងចិញ្ចឹមបីបាច់រហូតដល់បច្ចុប្បន្ននេះ ។ អ្នកមានគុណទាំងពីរបានខិតខំប្រឹងប្រែងបំពេញការងារយ៉ាងនឿយហត់ ដើម្បីផ្តល់ថវិការ សម្ភារៈគ្រប់សព្វបែបយ៉ាងឱ្យរូបកូនបានសិក្សា និងមានសម្ភារៈសិក្សាបានគ្រប់គ្រាន់ សម្រាប់ក្រេបជញ្ជក់យកចំណេះវិជ្ជាពីលោកគ្រូ និងអ្នកគ្រូ ។ លើសពីនេះ លោកទាំងពីរបានខិតខំទូន្មានប្រៀនប្រដៅ កូនឱ្យមានគុណធម៌ កត្តញ្ញូតាធម៌ សីលធម៌ល្អនៅក្នុងសង្គម ។ មិនតែប៉ុណ្ណោះ អ្នកមានគុណតែងតែ ផ្តល់កម្លាំងចិត្ត ជួយជ្រោមជ្រែងយើងខ្ញុំជំនះនូវរាល់ឧបសគ្គកន្លងមក រហូតដល់កូនបានបញ្ចប់ឧត្តមសិក្សានេះ ព្រមទាំងជឿជាក់ទៅលើរូបកូនថា អាចសសេរសម្រេចកិច្ចការស្រាវជ្រាវសារណាមួយនេះផងដែរ ។

**ឯកឧត្តម សាកលវិទ្យាធិកា សាកលវិទ្យាធិការរង ថ្នាក់ដឹកនាំ និង លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ** ដែលបានខិតខំបង្ហាត់បង្រៀន ផ្តល់ចំណេះដឹង និងដំបូន្មានល្អៗ ព្រមទាំងចែករំលែកនូវបទពិសោធន៍ដ៏មានតម្លៃនៅក្នុងការសិក្សា ដល់យើងខ្ញុំយ៉ាងយកចិត្តទុកដាក់ជាទីបំផុត ដើម្បីឱ្យយើងខ្ញុំបានបញ្ចប់ការសិក្សាប្រកបដោយភាពជោគជ័យ ។

ជាពិសេសចំពោះសាស្ត្រាចារ្យ ឌឿក ពិដោរ ដែលជាសាស្ត្រាចារ្យណែនាំរបស់យើងខ្ញុំផ្ទាល់លើកិច្ចការសារណាបញ្ចប់ការសិក្សាមួយនេះ ។ យើងខ្ញុំសូមធ្វើការដឹងគុណចំពោះលោកសាស្ត្រាចារ្យដែលបានចំណាយពេលវេលាដ៏មានតម្លៃរបស់លោក ក្នុងការដឹកនាំ ពន្យល់ណែនាំ និងកែតម្រូវនូវរាល់ចំណុចខ្វះខាតជាច្រើន លើកិច្ចការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះ តាំងពីពេលចាប់ផ្តើម រហូតមកដល់ពេលដែលយើងខ្ញុំបានបញ្ចប់ និងសម្រេចបាននូវកិច្ចការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះ ទទួលបាននូវលទ្ធផលដ៏សមប្រកបជាស្ថាពរ ។

# អារម្ភកថា

យើងខ្ញុំជានិស្សិត សិក្សាជំនាញនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០១៧-២០២១ ខ្ញុំមានសេចក្តីមោទនភាពជាពនពេក ដែលបានទទួលកិត្តិយស បានក្លាយជានិស្សិតសរសេរសារណាបញ្ចប់ការសិក្សានៅក្នុងកម្រិតថ្នាក់បរិញ្ញាបត្រនេះ ។ ក្រោយពីបានឆ្លងកាត់ ការសិក្សា ទ្រឹស្តី ផ្នែកច្បាប់យ៉ាងយកចិត្តទុកដាក់ពីលោកគ្រូសាស្ត្រាចារ្យ អ្នកគ្រូសាស្ត្រា ដែលមានជំនាញ និងទេពកោសល្យបង្រៀនរួចមក ដោយចិត្តស្រឡាញ់ មានចំណាប់អារម្មណ៍លើមុខជំនាញនីតិឯកជន ចាប់តាំងពីបានសិក្សាពីថ្នាក់មូលដ្ឋាន រហូតដល់ឆ្នាំទី៤ នេះ ក្រុមយើងខ្ញុំបានសម្រេចចិត្តជ្រើសរើសប្រធានបទមួយ មានចំណងជើងថា " ការស្នងមត៌កតាមច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា " មកធ្វើការស្រាវជ្រាវ ដើម្បីជាសារណាក្នុងការបញ្ចប់ការសិក្សា ។

មូលហេតុចម្បងដែលយើងខ្ញុំសម្រេចចិត្ត លើកយកប្រធានបទនេះមកធ្វើការសរសេរសារណា គឺដើម្បីឱ្យមិត្តនិស្សិត ឬ មិត្តអ្នកអាន ដែលមានបំណងស្វែងយល់អំពីខ្លឹមសារនៃការស្នងមត៌កតាមច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ជាការលើកស្ទួយចំណេះដឹងរបស់ប្អូនៗ និងមិត្តអ្នកអានទាំងអស់គ្នា ។ ជាការពិតណាស់នៅពេលជនណាម្នាក់មិនបានធ្វើមតកសាសន៍ ឬ មិនបានបន្សល់ទុកបណ្តាំមត៌កនោះទេ ចំពោះការបែងចែកមត៌កទៅកាន់សន្តតិជនគឺប្រព្រឹត្តទៅបានដោយមានច្បាប់ជាអ្នកកំណត់ ដើម្បីឱ្យមានភាពយុត្តិធ៌មពិតប្រាកដទៅលើជនដែលត្រូវស្នងមត៌ក អនុលោមតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ ។ ហេតុនេះ ក្រុមយើងខ្ញុំខិតខំបង្កើតស្នាដៃនៃការសរសេរសារណានេះឡើង ទោះជាជួបការលំបាកដោយសារតែវីរុសថ្មីមួយ ឈ្មោះ កូវីត ១៩ ( Covid-19 ) នេះ ដែលធ្វើឱ្យប៉ះពាល់យ៉ាងធំធេងចំពោះការសិក្សាស្រាវជ្រាវ នៅក្នុងការស្វែងរកឯកសារ ការចុះកម្មសិក្សានៅស្ថាប័ននានាផងដែរ ។ សរុបមកឧបសគ្គទាំងអស់នេះវាធ្វើឱ្យយើងខ្ញុំចេះបត់បែនតាមកាលៈទេសៈ និងអត់ធនក្នុងការសរសេរសារណានេះឱ្យសម្រេចដោយភាពជោគជ័យ ។ យើងខ្ញុំសង្ឃឹម យ៉ាងមុតមាំថា អត្ថបទសារណានេះចូលរួម ផ្សព្វផ្សាយ ជាជំនួយស្មារតីផ្នែកច្បាប់ និងសម្រាប់បុគ្គលទូទៅមិនចំពោះតែអ្នកច្បាប់ ជាពិសេសសម្រាប់បុគ្គលណាម្នាក់ដែលចង់ស្វែងយល់ និងចង់ដឹងអំពីខ្លឹមសារលក្ខណៈនៃការស្នងមត៌កតាមច្បាប់ លក្ខខណ្ឌដែលអាចក្លាយជាសន្តតិជន នីតិវិធីនៃការដាក់ពាក្យសុំឱ្យបែងចែកមត៌ក និងលក្ខណៈផ្សេងជាច្រើនទៀត។

ទោះបីជាការខិតខំប្រឹងប្រែង និងការយកចិត្តទុកដាក់ដោយភាពហ្មត់ចត់យ៉ាងណាក៏ដោយគឺ នៅតែមានចំណុចខ្វះខាតដោយយថាហេតុ មិនអាចជៀសផុតបាន ដូចសភាសិតមួយពោលថា " ដំរីជើងបួនគង់មានភ្លាត់ អ្នកប្រាជ្ញចេះស្ទាត់គង់មានភ្លេច " ។ ដូច្នេះយើងខ្ញុំជានិស្សិតសូមអភ័យទោសជាមុន រាល់កំហុសខុសឆ្គង

ទាំងឡាយដែលកើតឡើងដោយឥតព្រាងទុក ។ យើងខ្ញុំទទួលយកមតិរិះគន់ទាំងឡាយដោយសេចក្ដីពេញចិត្ត ក្នុងន័យស្ថាបនាដើម្បីឱ្យសមិទ្ធិផលមួយនេះ កាន់តែប្រសើរឡើង ។

ជាចុងក្រោយយើងខ្ញុំសូមជូនពរដល់ឯកឧត្ដម សាកលវិទ្យាធិកា សាកលវិទ្យាធិការរង ថ្នាក់ដឹកនាំ និង លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ មិត្តនិស្សិតគ្រប់រូបមានសុខភាពល្អ សំណាងល្អ និងសូមឱ្យវត្ថុសាកសិទ្ធិតាម ការពារថែរក្សា និងសូមប្រសិទ្ធិពរជ័យជូនចំពោះអ្នកមានគុណទាំងទ្វេ ឱ្យជួបប្រទះតែពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃាតឡើយ ។

# មាតិកា

ទំព័រ

**សេចក្ដីផ្ដើម**..................................................................... ១

## ជំពូកទី១

## សញ្ញាណទូទៅនៃសន្តតិកម្មតាមច្បាប់

ផ្នែកទី១៖ ការកំណត់ខ្លឹមសារនៃការស្នងមត៌កតាមច្បាប់ ............................ ៤
១.១. និយមន័យ............................................................... ៤
១.២. ចរិតលក្ខណៈនៃការស្នងមត៌កតាមច្បាប់............................. ៥
ផ្នែកទី២៖ អំពីអ្នកស្នង................................................................ ៥
២.១. លក្ខខណ្ឌនៃការទទួលសិទ្ធិជាសន្តតិជន............................. ៦
២.១.១. ករណីសន្តតិជនស្ថិតក្នុងស្ថានភាពជាទារកក្នុងគភ៌ ............... ៦
២.១.២. ករណីសន្តតិជនជារូបវន្តបុគ្គល.......................................៧
២.២. លំដាប់នៃសន្តតិជន....................................................... ៩
២.៣. ការសម្រួលចំណែករបស់សន្តតិជនតាមច្បាប់...........................១១
២.៣.១. អ្នកទទួលផលប្រយោជន៍ពិសេស ...................................១១
២.៣.២. ករណីភាគនៃវិភាគទាន...............................................១៥
២.៤. ការផ្ដាច់សិទ្ធិជាសន្តតិជន ...............................................១៦
២.៤.១. ករណីអភ័ព្វបុគ្គល.....................................................១៦
២.៤.២. ករណីបុគ្គលដែលត្រូវផ្ដាច់ចេញពីសន្តតិកម្ម...........................១៧
ផ្នែកទី៣៖ ការយល់ព្រម និងការបោះបង់ចោលសន្តតិកម្មតាមច្បាប់.....................១៩
៣.១. ការយល់ព្រមទទួលយកសន្តតិកម្ម ......................................១៩
៣.១.១. ការយល់ព្រមទទួលយកទាំងស្រុង ...................................២០
៣.១.២. ការយល់ព្រមទទួលយកដោយមានកម្រិត.............................២១
៣.២. ការបោះបង់ចោលសន្តតិកម្មតាមច្បាប់................................. ២២
ផ្នែកទី៤៖អំពីស្ថានភាពពិសេសនៃសន្តតិកម្មតាមច្បាប់..................................២២

៤.១. អំពីនត្តិភាពនៃសន្តតិជន........................................................................................................២៣
៤.១.១. នីតិបុគ្គលមត៌ក .............................................................................................................២៣
៤.១.២. ចំណែកចំពោះជនដែលមាននិស្ស័យពិសេស..................................................................២៤
៤.១.៣. មត៌កដែលក្លាយជារដ្ឋ ........................................................................................................២៤
៤.២. អំពីបដិទាននៃសន្តតិកម្ម............................................................................................................ ២៥

## ជំពូកទី២

## ការអនុវត្តនៃសន្តតិកម្មតាមច្បាប់

ផ្នែកទី១៖ របបនៃការគ្រប់គ្រង និងការបែងចែកសន្តតិកម្មតាមច្បាប់.................................................. ២៧
១.១. របបនៃការគ្រប់គ្រង ..................................................................................................................... ២៧
១.២. ការបែងចែកសន្តតិកម្មតាមច្បាប់ .................................................................................................. ២៨
១.២.១. ការបែងចែកសន្តតិកម្មតាមការព្រមព្រៀង..................................................................................២៩
១.២.២. ការបែងចែកសន្តតិកម្មតាមផ្លូវតុលាការ.....................................................................................៣០
ផ្នែកទី២ ៖ នីតិវិធីនៃការប្តឹងទាមទារមត៌ក ...........................................................................................៣១
២.១. របៀបនៃការដាក់ពាក្យសុំ .............................................................................................................. ៣១
២.១.១. ចំណុចដែលត្រូវសរសេរក្នុងពាក្យសុំបែងចែកមត៌ក.......................................................................៣១
២.១.២. ភាគី និង អ្នកតំណាង.....................................................................................................................៣៣
២.២. សមត្ថកិច្ចសាលាជម្រះក្តី.................................................................................................................. ៣៦
២.២.២. ពន្ធដាក់ពាក្យសុំ.............................................................................................................................៣៦
២.២.៣. ការទទួល និងពិនិត្យពាក្យសុំ............................................................................................................៣៦
២.២.៤. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង ការទាញហេតុផលដោយផ្ទាល់មាត់.................៣៨
២.២.៥. ការចេញដីកាសម្រេច ......................................................................................................................៣៨
**សេចក្តីសន្និដ្ឋាន**......................................................................................................................................៤០
**អនុសាសន៍** .............................................................................................................................................៤២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្ដីផ្ដើម

ការកើតមាន ក៏ដូចជាការប្រើប្រាស់នូវរបបសន្តតិកម្ម មិនមែនទើបតែមាននាពេលបច្ចុប្បន្ននោះទេ ពោលគឺវាបានកើតឡើងតាំងពីយូរលង់ណាស់មកហើយ ដែលវាត្រូវបានគេប្រើប្រាស់រហូតក្លាយទៅជាទំនៀមទំលាប់ និងមានការប្រែប្រួលពីមួយសម័យកាលទៅមួយសម័យកាល ។ ជាក់ស្ដែងកាលពីសម័យបុរាណ គឺគ្មានការចែងច្បាស់លាស់ពីរបៀបនៃការបែងចែកមត៌កទៅឱ្យសាច់ឈាម ខ្សែលោហិតនោះទេ តែផ្ទុយទៅវិញនាសម័យដែលស្ដេចគ្រងរាជ្យ គឺនៅពេលដែលទ្រង់ចូលទីវង្គត់ទៅ ទ្រង់ក៏បានធ្វើការដាក់រាជ្យទៅឱ្យបុត្ររបស់ទ្រង់ដើម្បីបន្តនូវតួនាទី នឹងធ្វើការដឹកនាំប្រទេសបន្តពីទ្រង់ តែក្នុងនោះបណ្ដាំមត៌កជាលាយលក្ខណ៍អក្សរ ក៏ដូចជាការផ្ដែផ្ដាំ គឺមិនមានការបែងចែកទ្រព្យបន្តទៅឱ្យប្រពន្ធ ឬបងប្អូនឡើយ ។ ដោយសារតែនាសម័យបុរាណការផ្ទេរមត៌ក គឺត្រូវមានការគោរពនូវឆន្ទៈរបស់អ្នកស្លាប់ជាចាំបាច់ បើទោះបីជាវាគ្មាននូវភាពយុត្តិធម៌ចំពោះខ្សែលោហិតឯទៀតក៏ដោយ ក៏នៅតែគោរព និងប្រតិបត្តិតាមយ៉ាងល្អ ។ ការអនុវត្តបែបនេះពីមួយសម័យកាលទៅមួយសម័យកាលទើបធ្វើឱ្យប្រទេសកម្ពុជាមានការលេចឡើងច្បាប់ដំបូងគេនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ បានធ្វើការកែប្រែទំលាប់នៃការបែងចែកទ្រព្យពីសម័យបុរាណដែលគ្មានមូលដ្ឋានគ្រឹះច្បាស់លាស់ ដោយយល់ឃើញថានៅសម័យមុនការបែងចែកទ្រព្យសម្បត្តិគឺ ធ្វើតែទៅតាមអារម្មណ៍របស់មតកជន ដែលធ្វើឱ្យការបែងចែកនេះមិនមានភាពស្មើភាពគ្នារវាងសន្តតិជន ពោលគឺកូនណាដែលមតកជនស្រឡាញ់ជាងគេនោះប្រកដជាបានទ្រព្យពីមតកជននោះជាក់ជាពុំខាន ។

ជាងនេះទៅទៀតដោយសារតែប្រទេសកម្ពុជាបានឆ្លងកាត់នៅសង្គ្រាម ការផ្លាស់ប្ដូររបបនយោបាយឥតឈប់ឈរទើបបានធ្វើឱ្យវិស័យគតិយុត្តក្នុងប្រទេសកម្ពុជាមានភាពទន់ខ្សោយ ។ ក្នុងឆ្នាំ ១៩៧៥ ដល់ ១៩៧៩ (របបកម្ពុជាប្រជាធិបតេយ្យ) គឺជារបបមួយដែលធ្វើឱ្យប្រទេសកម្ពុជាបានឆ្លងកាត់របបដ៏ខ្មៅងងឹត និងបានធ្វើឱ្យប្រជាជនបាក់ស្បាត មិនតែប៉ុណ្ណោះរបបដឹកនាំដ៏ព្រៃផ្សៃមួយនេះបានបំផ្លាញប្រទេសជាតិខ្លួនឱ្យទទួលរងនៅភាពខ្ទេចខ្ទី គ្មានសល់លើគ្រប់វិស័យ ។ ការរស់នៅរបស់ប្រជាជននាសម័យកាលនោះ រស់នៅជាអង្គការគ្មាននូវទ្រព្យសម្បត្តិឯកជន គ្មានសិទ្ធិកាន់កាប់លើអចលនវត្ថុ គ្មានការផ្ទេរ គ្មានការធ្វើសន្តតិកម្ម ។ ប័ណ្ណកម្មសិទ្ធិដែលមានពីមុនត្រូវបានលុបបំបាត់ចោល រហូតដល់ថ្ងៃ ៧ មករា ១៩៧៩ ដែលជាថ្ងៃដែលប្រជាពលរដ្ឋបានរួចផុតពីនរកលើដែនដីកំណើតខ្លួន ពេលនោះអចលនវត្ថុមានភាពទូលំទូលាយ និងដោយហេតុប្រជាជននៅសល់អារម្មណ៍ភ័យខ្លាចផងនោះ ទើបមិនមានការគិតគូរពីកម្មសិទ្ធិលើទ្រព្យសម្បត្តិអ្វីទេ ។ មួយវិញទៀតប្រទេសជាតិត្រូវបានរងនូវការបំផ្លិតបំផ្លាញដែលជាហេតុដែលធ្វើឱ្យប្រព័ន្ធគតិយុត្តិនាសម័យនោះនៅមិនទាន់មានការលូតលាស់នៅឡើយ ។ ដូចនេះប្រជាជនមិនមានសិទ្ធិឯកជនទៅលើដីធ្លីដែលខ្លួនមាននោះឡើយ ដោយប្រជាជន

ម្នាក់មានសិទ្ធិរស់នៅ អាស្រ័យផល តែគ្មានសិទ្ធិចាត់ចែងទិញ លក់ បញ្ចាំ គ្មានសិទ្ធិផ្ទេរបន្តទៅឱ្យកូនចៅនោះទេ។

រហូតដល់ឆ្នាំ ១៩៨៩ ប្រទេសកម្ពុជាមានការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដែលនាំឱ្យមានការចាប់ផ្ដើមប្រគល់សិទ្ធិកាន់កាប់អចលនវត្ថុទៅឱ្យប្រជាពលរដ្ឋ ក្នុងការកាន់កាប់ដីធ្លីឯកជន ក៏ដូចជាមានសិទ្ធិផ្ដាច់មុខទៅលើអចលនវត្ថុដែលខ្លួនបានកាន់កាប់ ។ មិនតែប៉ុណ្ណោះ ដំណើរការនៃការបង្កើតច្បាប់នៅក្នុងប្រទេសកម្ពុជាមានការវិវត្ត ក៏ដូចជាកែប្រែនូវចំនុចខ្វះខាតដែលមានកន្លងមក ជាក់ស្ដែងនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៩ ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារបានលេចរូបរាងឡើង ដោយសារតែជាតម្រូវការសង្គម ក៏ដូចជាការផ្លាស់ប្ដូររបបដឹកនាំ បានធ្វើឱ្យមានការកែទម្រង់ច្បាប់ជាបន្តបន្ទាប់ ជាហេតុនាំឱ្យមានការបង្កើតច្បាប់ភូមិបាល ឆ្នាំ ២០០១ ។ ការវិវត្តសន្សឹមៗនៃច្បាប់បានធ្វើឱ្យប្រជាពលរដ្ឋមានសិទ្ធិក្លាយខ្លួនជាម្ចាស់កម្មសិទ្ធិករ មានប័ណ្ណកម្មសិទ្ធិសំគាល់អចលនវត្ថុដែលចេញចំពោះម្ចាស់កម្មសិទ្ធិ មានការផ្ទេរសិទ្ធិត្រឹមត្រូវស្របតាមច្បាប់ ។ ជាពិសេសជាងនេះទៅទៀត សភាបានបញ្ញត្តិពីនីតិវិធីនៃការបែងចែងទ្រព្យសម្បត្តិ នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ការបែងចែងត្រូវអនុវត្តតាមក្រមរដ្ឋប្បវេណី ដែលបានចែងយ៉ាងលម្អិតពីបុគ្គលដែលមានសិទ្ធិក្លាយខ្លួនជាសន្តតិជនបន្ទាប់ពីមរណភាពរបស់មតកជន ក្នុងនោះផងដែរមិនមែនមានតែកូនប៉ុណ្ណោះទេដែលមានសិទ្ធិជាសន្តតិជនដូចទៅនឹងការអនុវត្តកាលពីសម័យបុរាណនោះទេ តែផ្ទុយទៅវិញ សហព័ទ្ធរបស់មតកជន បងប្អូន ឪពុកម្ដាយចៅ ក្មួយសុទ្ធតែមានសិទ្ធិឡើងស្នងនូវសន្តតិកម្មបានទៅតាមចំណែក និងលំដាប់របស់ពួកគេ ។ យើងឃើញថាការបែងចែកទ្រព្យសម្បត្តិនៅសម័យមុនគឺធ្វើឡើងតាមអារម្មណ៍ ភាពយកចិត្តទុកដាក់ស្រឡាញ់ថ្នាក់ថ្នមទៅលើកូនណាកូននោះប្រាកដជាទទួល ប៉ុន្តែដោយច្បាប់មើលឃើញពីភាពអយុត្តិធម៌នៅចំនុចនេះ ទើបច្បាប់ដើរតួយ៉ាងសំខាន់ក្នុងការបែងចែកករណីដែលមតកជនគ្មានបន្សល់នៅបណ្ដាំ ។ មួយវិញទៀតច្បាប់ក៏បានទុកសិទ្ធិមួយផ្នែកទៅឱ្យសន្តតិជន ក្នុងការទទួលបោះបង់សន្តតិកម្ម ថែមទាំងមានការសម្រួលនូវចំណែកមត៌កដើម្បីជាភាពអព្យាក្រឹត្យចំពោះសហសន្តតិជន ។

លើសពីនេះទៅទៀតសកម្មភាពដែលកើតចេញពីបុគ្គលដែលមាននិស្ស័យពិសេសជាមួយមតកជនក៏មានសិទ្ធិទទួលការតមស្នងពីមត៌ករបស់មតកជនផងដែរ ។ ដូចទៅក្នុងករណីដែលមត៌ករបស់មតកជនពុំមានសន្តតិជនដើម្បីបន្តនូវសិទ្ធិ និងកាតព្វកិច្ច ការបែងចែកមត៌កត្រូវបានចែកទៅឱ្យជនដែលមាននិស្ស័យពិសេស ប៉ុន្តែបើគ្មានជនដែលមាននិស្ស័យពិសេសទេនោះ មត៌កទាំងអស់នឹងត្រូវធ្លាក់ទៅជាទ្រព្យរដ្ឋ ។ បើទោះបីជាមានការចែងច្បាស់លាស់យ៉ាងណាក៏ដោយ ក៏នៅតែមានអ្នកមួយចំនួនមានចម្ងល់ទាក់ទងទៅនឹង ការអនុវត្តសន្តតិកម្មរបស់សន្តតិជន ក៏ដូចជាការស្នងមត៌កតាមច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជាមានលក្ខណៈបែបណា និងអនុវត្តនៅពេលណា ? ហើយសន្តតិជនម្នាក់ៗមានសិទ្ធិបែបណាខ្លះនៅក្នុងសន្តតិកម្មដែលខ្លួនមានចំណែក ?

ដើម្បីពន្យល់ឱ្យកាន់តែច្បាស់ ក៏ដូចជាស៊ីជម្រៅទៅលើប្រធានបទ "ការស្នងមត៌កតាមច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា" និងខ្លឹមសារពាក់ព័ន្ធនៃក្រមរដ្ឋប្បវេណីឱ្យមានភាពច្បាស់លាស់ យើងខ្ញុំបានកំណត់ការសិក្សាស្រាជ្រាវដូចខាងក្រោម ៖

**ជំពូកទី១៖ សញ្ញាណទូទៅនៃសន្តតិកម្មតាមច្បាប់**

**ជំពូកទី២៖ ការអនុវត្តនៃសន្តតិកម្មតាមច្បាប់**

# ជំពូកទី១

# សញ្ញាណទូទៅនៃសន្តតិកម្មតាមច្បាប់

# ជំពូកទី១

# សញ្ញាណទូទៅនៃសន្តតិកម្មតាមច្បាប់

សន្តតិកម្ម គឺជាការផ្ទេរនូវបេតិកភណ្ឌ សិទ្ធិ និងករណីយកិច្ច ទ្រព្យសម្បត្តិ និងបំណុល។ ប៉ុន្តែចំពោះសិទ្ធិ និងករណីយកិច្ចណាដែលមានលក្ខណៈផ្តាច់មុខ គឺមិនអាចជាកម្មវត្ថុនៃកិច្ចសន្យាបានឡើយ។ ជាក់ស្តែងសិទ្ធិទាំងឡាយណាដែលទាក់ទងទៅនឹងជនាភាព ឬជីវិតនៃមតកជន មិនអាចបន្តតាមសន្តតិកម្មបានទេ ដូចជាប្រាក់សោធននិវត្ត និងផលុបភោគជាដើម។ ដូចគ្នានេះដែរ ចំពោះទ្រព្យសម្បត្តិទាំងឡាយណាដែលត្រូវបានចាត់ទុកជារតនសម្បត្តិរបស់គ្រួសារ ចេតិយ ឬវត្ថុសម្រាប់ជំនឿសាសនាជាដើម មិនស្ថិតនៅក្រោយវិធាន ឬបទប្បញ្ញត្តិទូទៅនៃការផ្ទេរសន្តតិកម្មនោះទេ ដោយហេតុថាទ្រព្យសម្បត្តិ ឬវត្ថុទាំងនេះ មានលក្ខណៈពិសេសរបស់ខ្លួន ។ ហេតុនេះ ការបែងចែករបស់ទាំងនេះតាមសន្តតិកម្មអាចផ្អែកទៅលើការពិចារណាថាតើបុគ្គលនោះមានចំណងខ្លាំងជាមួយនឹងទ្រព្យនោះ ឬមានលក្ខណៈសម្បត្តិ ល្អជាងគេក្នុងការទទួលទ្រព្យទាំងនេះ។ ជាក់ស្តែងបើយោងទៅតាមក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មាត្រា ១១៤៧ បានបញ្ញត្តិថា "ចំពោះកម្មសិទ្ធិលើវត្ថុសម្រាប់ជំនឿសាសនា និងចេតិយ ឬចលនវត្ថុដែលជារតនសម្បត្តិគ្រួសារនៃបុព្វជន បើមានជនដែលត្រូវទទួលបន្តកម្មសិទ្ធិទាំងនោះ ដូចជាជនដែលត្រូវដឹកនាំពិធីបុណ្យនៃបុព្វជន ដោយយោងទៅតាមការកំណត់របស់មតកជន ជននោះត្រូវទទួលបន្ត។ បើមតកជនពុំបានកំណត់ទេ ជនដែលត្រូវដឹកនាំពិធីបុណ្យនៃបុព្វជនត្រូវទទួលបន្តនូវកម្មសិទ្ធិទាំងនោះ ដោយយោងតាមទំនៀមទម្លាប់។ ប្រសិនបើទំនៀមទម្លាប់មិនច្បាស់លាស់ទេតុលាការត្រូវកំណត់ជនដែលត្រូវទទួលបន្តនោះ"។

នៅពេលណាដែលមតកជនមិនបានបន្សល់ទុកនូវបណ្តាំ (មតកសាសន៍) ឬក៏មិនបានផ្តែផ្តាំដល់កូនចៅទេនោះ ការអនុវត្ត ក៏ដូចជាចាត់ចែងនូវទ្រព្យសម្បត្តិរបស់ជនដែលបានទទួលមរណភាពនោះត្រូវបានគោរពទៅតាមការបញ្ញត្តិរបស់ច្បាប់។

- កាលបរិច្ឆេទធ្វើសន្តតិកម្ម៖ គឺជាកាលបរិច្ឆេទនៃការស្លាប់របស់មតកជន ជាគោលការណ៍ដែលផ្អែកទៅលើលិខិតមរណភាពរបស់មតកជន ។ អនុលោមតាមមាត្រា២ នៃអនុក្រឹត្យលេខ ១០៣ អនក្រ បកចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន ដែលជាសំបុត្រអត្រានុកូលដ្ឋានរួមមានសំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រមរណភាព។ [1]
- ការកំណត់កាលបរិច្ឆេទ៖ កាលបរិច្ឆេទនៃមរណភាពជាក់លាក់របស់មតកជន គឺយកតាមលិខិតមរណភាពដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានជាថ្ងៃដែលអាចចាប់ផ្តើមបើកសន្តតិកម្មរបស់មតកជន។

[1] សៀវភៅ លក្ខខណ្ឌទូទៅនៃសន្តតិកម្ម និងសន្តតិកម្មតាមច្បាប់ រៀបរៀងដោយ លោក ជ័យ រិទ្ធី ដោយ បណ្ណាល័យច្បាប់

ចំពោះករណីបាត់ខ្លួន សន្តតិកម្មរបស់ជនដែលបាត់ខ្លួនត្រូវចាប់ផ្តើមបើកនៅក្រោយថ្ងៃប្រកាសសាលក្រមស្ថាពរពីបុគ្គលបាត់ខ្លួនដែលសាលក្រមនេះមានតម្លៃស្មើសំបុត្រមរណភាព។ ចំពោះករណីអវត្តមានដីកាប្រកាសពីការបាត់ខ្លួនជាស្ថាពរ ។ ករណីពិសេសចំពោះអ្នកនាវានិកនៅស្ថួតនិក (យានអវកាសគោចរ) នៅពេលដែលយានអវកាសបានបាត់ដំណឹង ការអវត្តមានរបស់នាវានិកទាំងនោះត្រូវសន្មត់បីខែក្រោយពេលនៃកាលបរិច្ឆេទផ្តល់ដំណឹងចុងក្រោយពីយានអវកាសបានចាក់ចេញផុតពីភពផែនដី ។[2]

- ទីកន្លែងបើកសន្តតិកម្មៈ ទីកន្លែងដែលមរណភាពរបស់មតកជន គឺជាទីកន្លែងដែលសន្តតិកម្មត្រូវកំណត់បើកដែលមានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ។ វិធាននេះមានតម្លៃអនុវត្តមិនថាមរណភាពទេ អវត្តមាន និងការបាត់ខ្លួនផងដែរ ។ ក្រៅពីលំនៅដ្ឋានខាងឆន្ទៈ គឺមានលំនៅដ្ឋានតាមច្បាប់កំណត់ផងដែរ។[3]

## ផ្នែកទី១៖ ការកំណត់ខ្លឹមសារនៃការស្នងមត៌កតាមច្បាប់

### ១.១. និយមន័យ

សន្តតិកម្ម ត្រូវបានឱ្យនិយមន័យថាជា ការផ្ទេរទ្រព្យសម្បត្តិទាំងឡាយណារបស់បុគ្គលណាម្នាក់ ដែលបានទទួលមរណភាព ទៅឱ្យបុគ្គលម្នាក់ ឬច្រើននាក់ ក្នុងឋានៈជាសន្តតិជន ឬអ្នកស្នងពីបុគ្គលដែលទទួលមរណភាពនោះ ដែលអាចជាការផ្ទេរតាមឆន្ទៈរបស់មតកជន (បុគ្គលដែលបានទទួលមរណភាព) ឬតាមផ្លូវច្បាប់ ។ ពោលគឺ សន្តតិកម្ម ត្រូវចាប់ផ្តើមដោយមរណភាពរបស់មតកជន ហើយត្រូវធ្វើតាមដោយផ្អែកទៅតាមបញ្ញត្តិនៃច្បាប់ ឬដោយផ្អែកតាមឆន្ទៈរបស់មតកជន។ ក្នុងន័យនេះពាក្យថា "ទ្រព្យសម្បត្តិ" របស់មតកជនសំដៅទៅលើទ្រព្យទាំងស្រុង ទាំងទ្រព្យសកម្ម និងទ្រព្យអកម្ម (បំណុល)។

សន្តតិកម្មតាមច្បាប់ (ការស្នងមត៌កតាមច្បាប់) គឺជាទម្រង់នៃសន្តតិកម្មដែលត្រូវអនុវត្តទៅតាមការកំណត់របស់បញ្ញត្តិនៃច្បាប់ពាក់ព័ន្ធនឹងសន្តតិជន នៅក្នុងករណីដែលមត៌កជនមិនបានធ្វើបណ្តាំមត៌ក (មត៌កសាសន៍) ហើយសហសន្តតិជនមិនអាចព្រមព្រៀងគ្នាតាមការពិភាក្សា ។ សន្តតិកម្មតាមច្បាប់ត្រូវបានតាក់តែងឡើង ដោយគតិទៅដល់យុត្តិធម៌រវាងញាតិដែលត្រូវបានកំណត់ថាជា "សន្តតិជន" ។

រាល់ការបែងចែកចំណែកមត៌កទាំងអស់របស់មតកជន គឺត្រូវអនុវត្តទៅតាមការបញ្ញត្តិរបស់ច្បាប់ជាកំហិតមួយវិញទៀតមូលហេតុដែលនាំឱ្យមានការបែងចែកមត៌កទៅតាមការកំណត់របស់ច្បាប់នោះ បណ្តាលមកពីមតកជនពុំបានធ្វើបណ្តាំ និងក្នុងករណីដែលមតកជនបានធ្វើនូវបណ្តាំមត៌ក (មតកសាសន៍) ប៉ុន្តែវាគ្មាន

[2] សៀវភៅ នីតិបេតិកភណ្ឌគ្រួសារ អ្នកនិពន្ធ សាស្ត្រាចារ្យ ស្រី វណ្ណធី ទំព័រ ១៣៥

[3] សៀវភៅ នីតិបេតិកភណ្ឌគ្រួសារ អ្នកនិពន្ធ សាស្ត្រាចារ្យ ស្រី វណ្ណធី ទំព័រ ១៣៦

សុពលភាពគតិយុត្តនោះទេ ដែលមកពីមិនត្រឹមត្រូវ ឬមិនស្របទៅតាមច្បាប់ នោះការបែងចែកមត៌កត្រូវប្រើវិធីនៃការបែងចែកមត៌ក ដូចជាការកំណត់នូវចំណែកមត៌ក វិធីក្នុងការសម្រួលចំណែកមត៌ក កំណត់អំពីជនដែលត្រូវទទួលមត៌ក កំណត់ពីចំណែកមត៌កដែលត្រូវបានទទួលរបស់សន្តតិជននីមួយៗ និងព្រមទាំងរបៀបនៃការបែងចែកមត៌កនៅក្នុងក្រមនេះ។

### ១.២. ចរិតលក្ខណៈនៃការស្នងមត៌កតាមច្បាប់

ចរិតលក្ខណៈនៃការស្នងមត៌កតាមច្បាប់ ឬសន្តតិកម្មតាមច្បាប់ គឺវាមានលក្ខណៈចាប់បង្ខំដោយហេតុថា គ្រប់បញ្ញត្តិដែលបានកំណត់នៅក្នុងច្បាប់ទាំងអស់ ត្រូវតែគោរព និងអនុវត្តជាចាំបាច់ ពោលគឺមានន័យថាសន្តតិជនទាំងអស់មិនអាចកែប្រែលំដាប់នៃសន្តតិជនដែលច្បាប់បានកំណត់រួចហើយនោះទេ។ លើសពីនេះទៅទៀត ច្បាប់មានលក្ខណៈចាប់បង្ខំឱ្យអនុវត្ត ប៉ុន្តែក្នុងលក្ខខណ្ឌមួយចំនួន ដូចជាច្បាប់ស្តីពីសន្តតិកម្ម និងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ក៏បានទុកនូវចន្លោះមួយផ្អែកទៅឱ្យសន្តតិជនផងដែរ ។ ពោលគឺ មានសន្តតិកម្ម មានការស្នងនូវសន្តតិកម្មនេះ ជាក់ស្តែងដូចគ្នាទៅនឹងមតកជនបានធ្វើនូវការផ្ទេរមត៌ក ទៅឱ្យទាយាទ ឬអ្នកស្នងបន្តដែលជាសន្តតិជន ។ ការផ្ទេរនេះ អាចជាឆន្ទៈរបស់មតកជន ប៉ុន្តែក្នុងន័យនេះ គឺមតកជនមិនបានបង្ហាញឆន្ទៈឡើយ ច្បាប់វិញទេដែលជាអ្នកកំណត់នូវការបែងចែកទាំងចំនួនមត៌ក និងបុគ្គលដែលមានសិទ្ធិអាចធ្វើការឡើងស្នងនូវមត៌ក ។ ទន្ទឹមនឹងនេះផងដែរ សន្តតិជនក៏ទទួលបានសិទ្ធិពីសន្តតិកម្មតាមច្បាប់នេះ ដោយសន្តតិជនមានសិទ្ធិទទួលយក ឬយល់ព្រមឡើងស្នងសន្តតិកម្ម ឬបោះបង់ចោលនូវសន្តតិកម្មដោយផ្អែកទៅលើការយល់ឃើញរបស់សន្តតិជន ឬមូលហេតុផ្សេងទៀតណាមួយ ។ ហេតុនេះហើយដែលសន្តតិកម្មតាមច្បាប់មានការគោរពនូវឆន្ទៈរបស់សន្តតិជន មួយវិញទៀត សន្តតិកម្មតាមច្បាប់នេះមានផលវិជ្ជមានជាច្រើន បើទោះបីជាមតកជនមិនបានបង្ហាញឆន្ទៈរបស់ខ្លួនក៏ដោយ ដោយច្បាប់បានកំណត់ពីលំដាប់នៃសន្តតិជន របៀបនៃការបែងចែក ការសម្រួលនូវចំណែកមត៌កដើម្បីសមាមាត្រគ្នាចំពោះសហសន្តតិជន និងបង្ការករណីមានវិវាទមត៌ក ។

## ផ្នែកទី២៖ អំពីអ្នកស្នង

បុគ្គលដែលត្រូវទទួលបន្តនូវមត៌ក ហៅថា សន្តតិជន ជាជនដែលត្រូវទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនតាមរយៈសន្តតិកម្ម។ សន្តតិជនត្រូវទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចទាំងអស់ ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជន ចាប់ពីពេលដែលចាប់ផ្តើមសន្តតិកម្មលើកលែងតែសិទ្ធិ និងករណីយកិច្ចផ្តាច់មុខរបស់មតកជន។ ក្នុងនោះសន្តតិជន ក៏មានសិទ្ធិក្នុងការបោះបង់នូវមត៌កនោះចោលផងដែរ

ទៅតាមលក្ខខណ្ឌ និងពេលវេលាដែលបានកំណត់ដោយច្បាប់។ តាមច្បាប់បើក្នុងករណីដែលគ្មានសន្តតិជន និងជនដែលមាននិស្ស័យពិសេសនោះទេ មត៌កទាំងអស់ត្រូវក្លាយទៅជាទ្រព្យសម្បត្តិរបស់រដ្ឋ។

## ២.១. លក្ខខណ្ឌនៃការទទួលសិទ្ធិជាសន្តតិជន

មិនមែនគ្រប់បុគ្គលទាំងអស់សុទ្ធតែអាចក្លាយជាសន្តតិជននោះទេ យោងតាមច្បាប់ដើម្បីអាចមានលក្ខណៈសម្បត្តិជាសន្តតិជនបានត្រូវតែជាជនមានជីវិតរស់នៅនាពេលចាប់ផ្តើមសន្តតិកម្ម ក្រៅពីអភ័ព្វបុគ្គល និងបុគ្គលដែលត្រូវបានកាត់ផ្តាច់ចេញពីមត៌ក ឬជាទារកក្នុងគ៌ក ប្រសិនបើទារកនោះមានជីវិតនៅពេលកើតមាននៅពេលក្រោយ។

ចំពោះសន្តតិជនដែលពុំមានសញ្ញាតិខ្មែរ ក៏ជាបុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាសន្តតិជនផងដែរ ប៉ុន្តែពុំអាចទទួលដីធ្លីតាមរយៈសន្តតិកម្ម ឬអច្ច័យទានបានទេ ដោយហេតុថាជនបរទេសដែលពុំមានសញ្ញាតិខ្មែរ ត្រូវបានកម្រិតសិទ្ធិទទួល ឬកាន់កាប់ដីធ្លី ។

### ២.១.១. ករណីសន្តតិជនស្ថិតក្នុងស្ថានភាពជាទារកក្នុងគភ៌

ទារកនៅគភ៌ គឺសំដៅទៅលើទារកដែលនៅក្នុងគភ៌នាពេលដែលចាប់ផ្តើមសន្តតិកម្ម បើទារកនោះមានកំណើតនៅពេលក្រោយ អាចទទួលមត៌ក ដោយសន្តតិកម្មនោះបាន មួយវិញទៀតបើទារកដែលនៅក្នុងគភ៌នាពេលដែលម្ចាស់បណ្តាំ បានទទួលមរណភាព បើទារកនោះមានកំណើតនៅពេលក្រោយ អាចទទួលអានុភាពនៃបណ្តាំនោះបាន។[4]

នៅក្នុងបញ្ញត្តិច្បាប់នៃក្រមរដ្ឋប្បវេណីបារាំង មាត្រា ៧២៥ ចំណុចទី១ បានចែងថាកូនដែលមិនទាន់មកចាប់កំណើតគ្មានសមត្ថភាពឡើងស្នងមត៌កទេ គឺមិនអាចប្រព្រឹត្តិទៅបានទេចំពោះដែលមិនមានអត្ថិភាពនៃកំណើតឡើងមកទទួលមត៌ក ។[5] ដោយឡែកមានតែកូនដែលបានមកចាប់កំណើតហើយមិនទាន់កើត ដែលនៅក្នុងផ្ទៃម្តាយជាគភ៌ នៅក្នុងអំឡុងពេលនោះសន្តតិកម្មរបស់មតកជនដែលជាឪពុកនៃកូននោះត្រូវបានបើកគភ៌នោះត្រូវបានចាត់ទុកជាសន្តតិជនគ្រប់គ្រាន់ក្នុងការស្នង ។ ទារកមានជីវិតនៅក្នុងផ្ទៃម្តាយ មុនពេលកើតចេញត្រូវបានចាត់ទុកដូចជាក្មេងនោះបានកើតចេញមកហើយ ដើម្បីមកទទួលយកផលប្រយោជន៍ដែលខ្លួនមានសិទ្ធិនឹងទទួល ។ ដូច្នេះមានការទទួលស្គាល់ដោយច្បាប់នូវសម្បទារបស់ទារកក្នុងគភ៌មានសិទ្ធិឡើងមកស្នងមត៌កជាសច្ចាធារណ៍មួយស្របទៅនឹងផលប្រយោជន៍របស់ទារកនោះ ។

សច្ចធារណ៍ជាកូនរបស់បុរសជាប្តីនៃម្តាយលុះត្រាតែ កូនដែលបានកើតនៅក្រោយអំឡុងពេល ១៨០ (មួយរយប៉ែតសិប) ថ្ងៃ គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍ត្រូវបានបង្កើតឡើង ឬអំឡុងពេល ៣០០ (បីរយ) ថ្ងៃ

---

[4] មាត្រា៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[5] សៀវភៅ នីតិបេតិកភណ្ឌគ្រួសារ អ្នកនិពន្ធ សាស្ត្រាចារ្យ ស្រី វណ្ណធី ទំព័រ ១៤៤ និង ១៤៥

គិតចាប់ពីដែលបានរំលាយ ឬលុបចោលអាពាហ៍ពិពាហ៍ត្រូវសន្មតថាមានគភ៌នៅក្នុងពេលដែលមានចំណង អាពាហ៍ពិពាហ៍នោះ ។[6] ដូច្នេះហើយកូននេះមានសិទ្ធិឡើងស្នងមត៌កពីមតកជនដែលជាឪពុកខ្លួន។

ក្នុងករណីដែលទារកបានស្លាប់នៅក្នុងផ្ទៃម្ដាយ ឬកើតពីផ្ទៃម្ដាយហើយតែគ្មានជីវិតមុនពេលបើកសន្តតិកម្មនោះមានន័យថាកូននោះអសមត្ថភាពក្នុងការឡើងស្នងមត៌ក និងទទួលផលប្រយោជន៍ដែលពាក់ព័ន្ធនឹងខ្លួនឡើយ ។

**ឧទាហរណ៍ ៖** លោក X ជាឪពុក (មតកជន) និងនាង Y ជាម្ដាយបានពរពោះកូន Z ក្នុងផ្ទៃ ដោយក្នុងថ្ងៃទី១ ខែមិថុនា ឆ្នាំ ២០២០ លោក X បានទទួលមរណភាព ។ Z បានកើតនៅក្នុងថ្ងៃ ២២ ខែ តុលា ឆ្នាំ ២០២០ ដោយទារក Z បានកើតមកដោយសុវត្ថិភាព ដូច្នេះ Z មានសិទ្ធិទទួលបាននូវសន្តតិកម្មតាមចំណែករបស់ខ្លួនក្រោមការមើលថៃ និងគ្រប់គ្រងរបស់ Y ដែលជាម្ដាយរហូតណា Z បានចម្រើនវ័យគ្រប់នីតិភាព ។ ប៉ុន្តែផ្ទុយទៅវិញ បើ Z បានបាត់បង់ជីវិតនាពេលកើតមកនោះសិទ្ធិរបស់ Z ដែលជាសន្តតិជនត្រូវបានបាត់បង់។

### ២.១.២. ករណីសន្តតិជនជារូបវ័ន្តបុគ្គល

រូបវ័ន្តបុគ្គល គឺសំដៅទៅលើបុគ្គលដែលមានសម្ថតភាពតាមផ្លូវច្បាប់ ដែលអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច ហើយប្រធាននៃសិទ្ធិ និងកាតព្វកិច្ចកើតឡើងនៅពេលដែលបុគ្គលនោះចាប់កំណើត និងរលត់ទៅវិញនៅពេលដែលបុគ្គលនោះបានស្លាប់បាត់បង់ជីវិត។ រូបវ័ន្តបុគ្គលដែលមានសិទ្ធិជាសន្តតិជន គឺរូបវ័ន្តបុគ្គលដែលមានអាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ និងបុគ្គលដែលទទួលបាននូវអត្តាធិនភាព។ ដោយសារតែរូបវ័ន្តបុគ្គលដែលមានអាយុចាប់ពី១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ គឺគាត់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងនូវទ្រព្យសម្បត្តិរបស់ខ្លួន ដោយឡែកក្នុងករណីបុគ្គលដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំក៏មានសិទ្ធិក្នុងការគ្រប់គ្រង មើលថែនូវទ្រព្យសម្បត្តិខ្លួនឯងផងដែរ ប៉ុន្តែក្នុងករណីនេះលុះត្រាតែបុគ្គលនោះទទួលបាននូវអត្តាធិនភាព ជាក់ស្ដែងបុគ្គលនោះទើបតែមានអាយុ ១៦ (ដប់ប្រាំមួយ) ឆ្នាំ ប៉ុន្តែគាត់មានមុខរបររកស៊ីមានម្ចាស់ការលើខ្លួនឯង អាចមើលថៃ និងទុកដាក់នូវទ្រព្យសម្បត្តិខ្លួនឯងបាន ហេតុផលនេះហើយច្បាប់បានអនុញ្ញាត្តិឱ្យគាត់ ក្លាយជាសន្តតិជនលើចំណែកមត៌កដែលគាត់ទទួលបាន។

មួយវិញទៀតក្នុងករណីដែលសន្តតិជនជាអនីតិជន៖ បើទោះបីជាសន្តតិជនជាអនីតិជន នៅតែមានសិទ្ធិទទួលនូវផលប្រយោជន៍របស់ខ្លួនតាមរយៈសន្តតិកម្ម ប៉ុន្តែទ្រព្យសម្បត្តិទាំងអស់ត្រូវមានការគ្រប់គ្រងមើលថៃពីបុគ្គលដែលមានអំណាចមេបា ដែលអាចជាម្ដាយ ឬឪពុក ឬក៏ជាអ្នកតំណាងតាមផ្លូវច្បាប់ ក្នុងករណីគ្មានទាំងម្ដាយ និងឪពុក អាចជាអ្នកតំណាងទូទៅដែលច្បាប់បានកំណត់ ។ មិនតែប៉ុណ្ណោះបើករណីមត៌កនៃសន្តតិ

[6] មាត្រា ៩៨៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

កម្មជា លុយកាកនោះអ្នកដែលគ្រប់គ្រងមើលថែនូវទ្រព្យសម្បត្តិអនីតិជននោះ គ្មានសិទ្ធិយកលុយនោះទៅចាយវាយបានទេ បើមត៌កជាផ្ទះ ឬដីធ្លីវិញនោះក៏មិនមានសិទ្ធិអាចលក់ ឬចាត់ចែងបានទេលុះត្រាតែមានការយល់ព្រមពីតុលាការ ។

ហេតុដូចនេះនៅក្នុងរបបសន្តតិកម្ម មានតែជនដែលមានជីវិតរស់នៅនាពេលចាប់ផ្ដើតសន្តតិកម្មទេទើបអាចទទួលមត៌កបាន ។[7] ប៉ុន្តែក្នុងករណីដែលសន្តតិជនបានបាត់ខ្លួន នៅពេលដែលគាត់ត្រឡប់មកវិញគាត់អាចទាមទារសិទ្ធិដើម្បីក្លាយជាសន្តតិជនវិញបាន ។ យោងតាមមាត្រា ៤៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ បានបញ្ញត្តិថា ប្រសិនបើមានការបញ្ជាក់ថា បុគ្គលដែលបានបាត់ខ្លួននៅរស់ ឬមានការបញ្ជាក់ថាទទួលមរណភាពនៅពេលខុសពីពេលដែលបានកំណត់នៅក្នុងមាត្រា ៤៣ (អានុភាពនៃការប្រកាសអំពីការបាត់ខ្លួន) ខាងលើនេះ តុលាការត្រូវលុបចោលការប្រកាសអំពីការបាត់ខ្លួន តាមពាក្យសុំរបស់សាមីខ្លួន ឬបុគ្គលដែលមានផលប្រយោជន៍។ បុគ្គលដែលទទួលបានទ្រព្យសម្បត្តិដោយចំពោះ ដោយសារអានុភាពនៃប្រកាសអំពីការបាត់ខ្លួន ត្រូវបាត់បង់សិទ្ធិ ដោយសារការលុបចោលនូវប្រកាសអំពីការបាត់ខ្លួននោះ ។ ពោលគឺ ប្រសិនបើបុគ្គលនោះបានបាត់ខ្លួនដោយពុំដឹងច្បាស់លាស់ថានៅមានជីវិត ឬទទួលមរណភាពតុលាការបានប្រកាសអំពីការបាត់ខ្លួនទៅតាមបណ្ដឹង ឬពាក្យស្នើសុំរបស់ជនដែលទទួលផលប្រយោជន៍ បន្ទាប់មកស្រាប់តែបុគ្គលនោះបានត្រឡប់មកវិញ គាត់ត្រូវទទួលបានសិទ្ធិដោយទទួលបានមត៌កនៅក្នុងសន្តតិកម្មនៃចំណែករបស់គាត់ ហើយបុគ្គលដែលទទួលទ្រព្យសម្បត្តិដោយសារអានុភាពនៃការប្រកាសអំពីការបាត់ខ្លួនមានកាតព្វកិច្ចសងត្រឡប់ទៅម្ចាស់ចំណែកនោះវិញ។

ក្នុងករណីសន្តតិជនជាជនបរទេស៖

មត៌កត្រូវបានបែងចែកដោយពិចារណាទៅលើកត្តាថា ៖ សន្តតិជន ឬបុគ្គលដែលទទួលទ្រព្យសម្បត្តិដែលពុំមែនជាសញ្ជាតិខ្មែរ ពុំអាចទទួលមត៌កជាដីធ្លីតាមសន្តតិកម្មបានឡើយ ។ បើសហសន្តតិជនដែលមានលំដាប់មុនទាំងអស់ ពុំមានសញ្ជាតិខ្មែរទេមត៌កត្រូវបែងចែកដីធ្លីនៅក្នុងចំណោមមត៌កទាំងអស់ ត្រូវក្លាយជានីតិបុគ្គល ហើយការគ្រប់គ្រង និងចាត់ចែងដីធ្លីនោះត្រូវធ្វើឡើងដោយសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់នោះ ។ ក្នុងនោះផងដែរសន្តតិជន ទាំងអស់នោះអាចលក់ដីធ្លីក្នុងនាមជាម្ចាស់សិទ្ធិចាត់ចែងមត៌ក ក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីថ្ងៃដែលសន្តតិជនទាំងអស់នោះយល់ព្រមគ្នាជាឯកច្ឆ័ន្ទ (ជាការយល់ព្រមទាំងស្រុង ឬមានកម្រិត) ហើយថ្លៃដែលលក់ដីបាននោះ ក្លាយជាមត៌ក នាំឱ្យនីតិបុគ្គលមត៌កត្រូវបានរលត់ ។ ពោលគឺ បើសន្តតិជនដែលគ្មានសញ្ជាតិជាខ្មែរ បានទទួលចំណែកមត៌កជាដីធ្លីនៅលើទឹដីនៃប្រទេសកម្ពុជាសន្តតិជននោះគ្មានសិទ្ធិធ្វើជាម្ចាស់កម្មសិទ្ធិ ដោយមានឈ្មោះជាម្ចាស់កម្មសិទ្ធិករលើដីធ្លីក្នុងមត៌កនោះបានទេ

[7] មាត្រា១១៤៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ប៉ុន្តែសន្តតិជនអាចមានសិទ្ធិលក់ដីធ្លីដែលជាចំណែកមត៌កនោះបាន ក្នុងអំឡុងពេល ៣ (បី) ខែ ដើម្បីយកលុយដែលលក់បានពីដីធ្វើជាចំណែកមត៌ករបស់ខ្លួន ។ ទន្ទឹមនឹងនេះផងដែរ បើសន្តតិជនមិនបានចាត់ចែងដីធ្លីនោះនៅក្នុងអំឡុងពេល ៣ (បី) ខែនោះទេ កម្មសិទ្ធិចំពោះដីធ្លីនោះ នឹងត្រូវបានធ្វើសន្តតិកម្មដោយសន្តតិជនដែលមានលំដាប់បន្ទាប់ជាសញ្ជាតិខ្មែរ ។ បើសន្តតិជនបន្ទាប់គ្មានសញ្ជាតិខ្មែរនោះទេ នាំឱ្យនត្ថិភាពនៃសន្តតិជនបានធ្វើឱ្យដីធ្លីនោះគ្មានម្ចាស់ ចុងក្រោយដីធ្លីនោះធ្លាក់ទៅជាទ្រព្យសម្បត្តិរដ្ឋ ។ ប៉ុន្តែប្រសិនបើការកាន់កាប់មត៌កជាអភព្វបុគ្គល ឬបុគ្គលដែលផ្តាច់មត៌កច្បាប់ចាត់ទុកថា ការកាន់កាប់នោះជាការកាន់កាប់ដោយទុច្ចរិត គិតចាប់ពីថ្ងៃដែលបើកសន្តតិកម្ម ។

ដោយយោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ មាត្រា ៤៤ កថាខណ្ឌទី១ ក៏ដូចជាច្បាប់ភូមិបាល ឆ្នាំ ២០០១ មាត្រា ៨ កថាខណ្ឌទី១ បានបញ្ញត្តិថា ជនណាក៏ដោយទោះជាបុគ្គលក្តី សមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី ។

### ២.២. លំដាប់នៃសន្តតិជន

ក្នុងរបបស្តីពីសន្តតិកម្ម ក៏ដូចជាក្រមរដ្ឋប្បវេណីបានបញ្ញត្តិយ៉ាងច្បាស់លាស់អំពីលំដាប់នៃសន្តតិជនដែលក្នុងករណីមតកជនមិនបានបន្សល់ទុកនូវចំណែកមត៌កទៅឱ្យសន្តតិជនណាម្នាក់ដោយភាពមត់ចត់ ទើបច្បាប់ដើរតួនាទីជាអ្នកចាត់ចែងយ៉ាងត្រឹមត្រូវលើគ្រប់ករណីដែលបានកើតឡើងទៅលើសន្តតិកម្ម ។ ក្នុងនោះផងដែរច្បាប់បានកំណត់សន្តតិជនជាបីលំដាប់ និងពីរករណីពិសេសផងដែរ ដែលរួមមានសន្តតិជនលំដាប់ទី១ សន្តតិជនលំដាប់ទី២ សន្តតិជនលំដាប់ទី៣ សន្តតិជនជានិច្ច និងសន្តតិកម្មជំនួស។

- សន្តតិជនលំដាប់ទី១ ៖ គឺសំដៅទៅលើកូនរបស់មតកជន កូនរបស់មតកជនត្រូវក្លាយជាសន្តតិជនលំដាប់ទី១ ទោះបីជាកូនបង្កើតក្តី កូនសុំក្តី ត្រូវទទួលបានចំណែកមត៌កស្មើៗគ្នា ។ ឱ្យតែជាកូនមានសិទ្ធិក្លាយជាសន្តតិជន ទោះបីជាកូនពាក់កណ្តាលបង្កើតក្តី កូនក្រៅចំណងអាពាហ៍ពិពាហ៍ក្តី ក្នុងករណីដែលកូននោះមានបុត្តភាពដែលទទួលស្គាល់តាមផ្លូវច្បាប់ ។ តួយ៉ាងកូនដែលក្រៅចំណងអាពាហ៍ពិពាហ៍ បើកូននោះពុំបានទទួលស្គាល់ជាបុត្តភាពតាមផ្លូវច្បាប់ក៏មិនអាចទទួលស្គាល់បានដែរ បើទោះបីជាមានទំនាក់ទំនងបិតុភាពបង្កើតក៏ដោយ ដូច្នេះកូននោះមិនអាចក្លាយជាសន្តតិជនរបស់មតកជនបានទេ ។ ចំពោះកូនសុំតាមស្មុំកូនពេញលេញទទួលសន្តតិកម្មតែពីឪពុកម្តាយចិញ្ចឹមតែប៉ុណ្ណោះ តែបើកូនសុំតាមស្មុំធម្មតា មានសិទ្ធិទទួលសន្តតិកម្មពីឪពុកម្តាយបង្កើតផង និងឪពុកម្តាយចិញ្ចឹមផង ។

- សន្តតិជនលំដាប់ទី២ ៖ គឺសំដៅទៅលើបុព្វញាតិរបស់មតកជន ពោលគឺ ឪពុក ម្តាយរបស់មតកជន ។ បុព្វញាតិផ្ទាល់របស់មតកជននោះ ត្រូវក្លាយជាសន្តតិជនបើមតកជននោះគ្មានបច្ឆាញាតិផ្ទាល់ទេ។ បុព្វញាតិផ្ទាល់ដែលមានថ្នាក់ញាតិខុសគ្នា ត្រូវយកបុព្វញាតិដែលនៅជិតជាងគេជាមុន ។ បុព្វញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនមានច្រើននាក់បុព្វញាតិផ្ទាល់នីមួយៗត្រូវទទួលចំណែកស្មើគ្នា ។ ម៉្យាងទៀត ក្នុងករណីដែលឪពុករបស់មតកជនបានទទួលមរណភាព ហើយទោះបីជាជីដូនជីតាខាងឪពុកនោះនៅរស់ក៏ដោយ ប្រសិនបើម្តាយរបស់មតកជននៅរស់ ម្តាយនោះជាអ្នកជិតជាងគេក្នុងថ្នាក់ញាតិដូចនេះម្តាយរបស់មតកជនជាសន្តតិជនលំដាប់ទីពីរតែម្នាក់ឯង ហេតុដូចនេះជីដូនជីតាមិនអាចឡើងស្នងសន្តតិកម្មជំនួសបានឡើយ ។ ប៉ុន្តែក្នុងករណីដែលម្តាយក៏ត្រូវទទួលមរណភាពដែរនោះ ជីដូនជីតាខាងម្តាយ និងជីដូនជីតាខាងឪពុក ឡើងស្នងសន្តតិកម្មជំនួសដោយទទួលបានចំណែកស្មើៗគ្នា ។

  **ឧទាហរណ៍៖** លោក A បានទទួលមរណភាពដោយគាត់គ្មានកូន និងប្រពន្ធឡើយ តែគាត់បានបន្សល់ទុកនូវទ្រព្យសម្បត្តិមួយចំនួនដែលគាត់បានខិតខំប្រឹងប្រែងនាពេលមានជីវិត ។ ដោយលោក A ជាមតកជននេះមានទាំងឪពុក ម្តាយ និងជីដូនជីតា ។ ដូច្នេះទ្រព្យសម្បត្តិរបស់គាត់ត្រូវធ្លាក់ទៅលើម្តាយឪពុកគាត់ស្មើៗគ្នា ពោលគឺ យកទ្រព្យសម្បត្តិនោះចែកនឹងពីរ ។ ប៉ុន្តែបើករណីដែលថា គាត់គ្មានម្តាយតែមានឪពុក នោះឪពុករបស់គាត់មានសិទ្ធិទៅលើទ្រព្យសម្បត្តិនោះតែម្នាក់ឯង រីឯ ជីដូនជីតារបស់មតកជន មានសិទ្ធិទទួលនូវចំណែកមត៌កនោះ លុះត្រាតែទាំងឪពុក និងម្តាយរបស់មតកជននោះបានទទួលមរណភាពដែល ដោយការទទួលមត៌កនេះ គឺធ្វើឡើងតាមរយៈសន្តតិកម្មជំនួសពីឪពុកម្តាយមតកជន ដែលជាសន្តតិជនលំដាប់ទីពីរ ។

- សន្តតិជនលំដាប់ទី៣ ៖ គឺសំដៅទៅលើបងប្អូនបង្កើតរបស់មតកជន ។ បងប្អូនបង្កើតរបស់មតកជនត្រូវក្លាយជាសន្តតិជន បើពុំមានទាំងបច្ឆាញាតិផ្ទាល់ ទាំងបុព្វញាតិផ្ទាល់ ហើយបងប្អូនបង្កើតដែលកើតរួមឪពុកម្តាយ ត្រូវបានចំណែកមត៌កស្មើៗគ្នា ប៉ុន្តែបងប្អូនបង្កើតដែលមានឪពុក ឬម្តាយតែម្ខាងដូចគ្នាត្រូវមាន ១ភាគ២ (មួយភាគពីរ) នៃចំណែកមត៌ករបស់បងប្អូនដែលមានឪពុក និងម្តាយទាំងសងខាងរួមគ្នា ។[8] ហើយប្រសិនបើបងប្អូនបង្កើតរបស់មតកជនបានទទួលមរណភាពនោះ សន្តតិកម្មជំនួសត្រូវបានទទួលស្គាល់ត្រឹមមួយតំណតែប៉ុណ្ណោះ មានន័យថាកូនរបស់បងប្អូនបង្កើតនោះ (ដែលត្រូវជាក្មួយប្រុស ក្មួយស្រីរបស់មតកជន) ត្រូវទទួលសន្តតិកម្មជំនួស ។

[8] មាត្រា១១៦០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

- សន្តតិជនជានិច្ច ៖ គឺសំដៅទៅលើសហព័ទ្ធរបស់មតកជន ដែលអាចជាប្ដី ឬប្រពន្ធ ។ ជាធម្មតា សហព័ទ្ធ មិនបានជាប់ចំណងខ្សែលោហិតជាមួយមតកជនក៏ពិតមែន ក៏ប៉ុន្តែសហព័ទ្ធបានផ្សារភ្ជាប់ចំណងខ្លួនតាមរយៈអាពាហ៍ពិពាហ៍ ឬតាមច្បាប់ដូច្នេះហើយសហព័ទ្ធជាសន្តតិជនជានិច្ច ។ ចំពោះពាក្យថាជានិច្ចក្នុងន័យនេះ គឺសំដៅលើការឡើងស្នងសន្តតិកម្មតាមច្បាប់ដែលសន្តតិជនដែលជាសហព័ទ្ធមានសិទ្ធិឡើងស្នងគ្រប់ករណីបើទោះបីជាមាន ឬគ្មានសន្តតិជនលំដាប់ផ្សេងទៀត ។ ពោលគឺ បើមានបុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធ ត្រូវជាសន្តតិជនដែរ សហព័ទ្ធនោះត្រូវមានលំដាប់ស្មើគ្នានឹងបុគ្គលនោះ ។[9] ប៉ុន្តែក្នុងន័យនេះមិនត្រូវបានយកមកអនុវត្តឡើយនៅក្នុងករណីដែលសន្តតិជនជានិច្ចនោះ ជាអភ័ព្វបុគ្គល ឬបុគ្គលដែលត្រូវបានផ្ដាច់ចេញពីសន្តតិកម្ម ។
- សន្តតិកម្មជំនួស ៖ ក្នុងករណីដែលសន្តតិជនលំដាប់ទី១ (កូនរបស់មតកជន) ទទួលមរណភាពនៅមុនពេល ឬព្រមគ្នានឹងពេលចាប់ផ្ដើមសន្តតិកម្ម ឬបុគ្គលនោះបានក្លាយជាអភ័ព្វបុគ្គល ឬជាបុគ្គលដែលបានផ្ដាច់មត៌ក កូនរបស់កូនមតកជន (ចៅមតកជន) នឹងទទួលនូវសន្តតិកម្មជំនួស ។

## ២.៣. ការសម្រួលចំណែករបស់សន្តតិជនតាមច្បាប់

ការសម្រួលចំណែកសន្តតិកម្ម គឺធ្វើឡើងក្នុងគោលបំណងដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃសន្តតិកម្ម ក៏ដូចជាភាពស្មើភាពគ្នាតាមរយៈការបញ្ញត្តិរបស់ច្បាប់ចំពោះសហសន្តតិជនទាំងឡាយដែលមានសិទ្ធិគ្រប់គ្រាន់ក្នុងការឡើងស្នងមត៌ក ។

### ២.៣.១. អ្នកទទួលផលប្រយោជន៍ពិសេស

បុគ្គលដែលទទួលផលប្រយោជន៍ពិសេសក្នុងន័យនេះ គឺសំដៅទៅលើអ្នកដែលបានទទួលនូវប្រទានកម្មពីមតកជននៅមុនពេលដែលមតកជនទទួលមរណភាព ។ ពោលគឺ សន្តតិជន ឬសហសន្តតិជនដែលទទួលបាននូវផលប្រយោជន៍ពិសេសមួយចំនួន ក្នុងឱកាសពិសេសណាមួយដែលមតកជនបានផ្ដល់អោយតាមរយៈប្រទានកម្ម ដែលអាចជាលុយកាក់ ផ្ទះសំបែង ដីធ្លីជាអាទិ៍ ។

នៅក្នុងចំណោមសហសន្តតិជនទាំងអស់ បើមានបុគ្គលណាម្នាក់បានទទួលប្រទានកម្ម នៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬហេតុការណ៍ផ្សេងទៀត ឬដើម្បីមូលធននៃជីវភាពរស់នៅ ឬដែលបានទទួលអច្ច័យទានពីមតកជននោះ តម្លៃសរុបនៃមត៌កដែលមតកជនមាននៅពេលចាប់ផ្ដើមសន្តតិកម្ម ដោយបូកបញ្ចូលនូវតម្លៃនៃប្រទានកម្ម ត្រូវបានចាត់ជាមត៌ក ហើយចំនួនទឹកប្រាក់ដែលនៅសល់ ក្រោយពីដកតម្លៃនៃប្រទានកម្ម ឬអច្ច័យទាននោះ

[9] មាត្រា១១៦១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ចេញពីចំណែកមត៌កដែលត្រូវបានគណនាតាមបញ្ញត្តិនៃផ្នែក១ សន្តតិជន និង សន្តតិកម្មរបស់សហព័ទ្ធ គឺជាចំណែកមត៌ករបស់បុគ្គលនោះ។

បើតម្លៃនៃប្រទានកម្ម ឬអច្ច័យទាន ស្មើគ្នានឹងតម្លៃនៃចំណែកមត៌ក ឬលើសពីតម្លៃនៃចំណែកមត៌កសហសន្តតិជននោះពុំអាចទទួលចំណែកមត៌កនោះបានឡើយ ។

ជាគោលការណ៍សន្តតិជនត្រូវទទួលបាននូវចំណែកមត៌កស្មើៗគ្នា ប៉ុន្តែប្រសិនបើមានបុគ្គលណាម្នាក់បានទទួលផលប្រយោជន៍ពិសេសណាមួយនៅក្នុងឱកាសពិសេសផ្សេងៗរបស់បុគ្គលណាម្នាក់នោះ ហើយមតកជនបានធ្វើនូវប្រទានកម្មទៅឱ្យបុគ្គលនោះ ការបែងចែកនូវចំណែកមត៌កក៏មិនអាចបែងចែកទៅតាមទ្រព្យសម្បត្តិជាក់ស្តែងដែលមាននាពេលចាប់ផ្តើមសន្តតិកម្មនោះដែរ ។ ដោយឡែកយើងមិនអាចយកចំណែកមត៌កជាក់ស្តែងទៅចែកឱ្យសន្តតិជនទាំងអស់ ដោយមិនសម្រួលចំណែកមត៌កនោះទេ ព្រោះបំពានទៅនឹងខ្លឹមសារនៃការទទួលបានចំណែកមត៌កជាក់ស្តែងដែលបានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណី អំពីចំណែកមត៌កនៃជនដែលទទួលផលប្រយោជន៍ពិសេស រួមជាមួយនឹងការសម្រួលចំណែក ។

មួយវិញទៀតចំពោះតម្លៃនៃផលប្រយោជន៍ពិសេសគឺ មានការប្រែប្រួលទៅតាមរយៈពេលនៃទ្រព្យសម្បត្តិដែលអាចជាចលនទ្រព្យ និងអចលនទ្រព្យ ។ យ៉ាងណាមិញទ្រព្យសម្បត្តិដែលសន្តតិជនទទួលបានតាមរយៈប្រទានកម្មនោះ គឺជាសិទ្ធិរបស់សន្តតិជននោះ ប៉ុន្តែក្នុងករណីនេះអាចមានការផ្លាស់ប្តូរមួយចំនួន ក្នុងលក្ខខណ្ឌតម្លៃនៃផលប្រយោជន៍ពិសេសមានការប្រែប្រួល ពោលគឺ ការបែងចែកមត៌កត្រូវធ្វើឡើង ដោយសម្រួលនូវចំណែកមត៌កជាមុនសិន តម្រូវឱ្យមានការបូកបញ្ចូលនូវមត៌កជាក់ស្តែង និងទ្រព្យសម្បត្តិដែលសន្តតិជនទទួលបានផលប្រយោជន៍ពិសេស ។ ដោយហេតុនេះក្នុងករណីបើទ្រព្យសម្បត្តិនៃផលប្រយោជន៍ពិសេសនោះមានការប្រែប្រួលដោយមានការកើនឡើង ឬអាចនឹងមានការបាត់បង់ វិនាសនាមុនពេលចាប់ផ្តើមសន្តតិកម្ម តើគេតម្រូវដោយធ្វើការសម្រួលបែបណា ?

ករណីបាត់បង់ ឬវិនាសមុនពេលចាប់ផ្តើមសន្តតិកម្ម ៖

ជាទូទៅទ្រព្យសម្បត្តិដែលសន្តតិជនទទួលបានតាមរយៈប្រទានកម្មដែលធ្វើឡើងតាមរយៈមតកជនមិនអាចមានសភាពដូចដើមដោយគ្មានការប្រែប្រួលនោះទេ ជាក់ស្តែងសន្តតិជនតែងធ្វើការចាត់ចែង បំលែងវត្ថុនោះទៅតាមតម្រូវការរបស់ខ្លួនជាធម្មតា ។ ប៉ុន្តែប្រសិនបើ ក្នុងករណីដែលវត្ថុនោះត្រូវបានបាត់បង់ ឬវិនាសមុនពេលចាប់ផ្តើមសន្តតិកម្មដោយឯកឯង នោះតម្លៃនៃផលប្រយោជន៍ពិសេសត្រូវគណនាដោយយកតម្លៃនៅពេលចាត់ចែង ឬនៅពេលបាត់បង់ ។[10] មួយវិញទៀត ប្រសិនបើអ្នកដែលទទួលបានផលប្រយោជន៍ពិសេស ជាអ្នកចាត់ចែងផលប្រយោជន៍ពិសេសនោះ ធ្វើឱ្យមានការបាត់បង់ ឬវិនាសនូវតម្លៃប្រទានកម្ម ឬមានការផ្លាស់ប្តូរនូវ

[10] មាត្រា១១៦៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ទ្រព្យសម្បត្តិមួយផ្នែកណាមួយ នោះតម្លៃនៃផលប្រយោជន៍ពិសេសត្រូវគណនាដោយចាត់ទុកថាមានស្ថានភាពដើម ។

ករណីកើនឡើងនៃតម្លៃផលប្រយោជន៍ពិសេស (ប្រទានកម្ម) ៖

ប្រទានកម្មអាចជាលុយកាក់ ផ្ទះសំប្បែង ដីធ្លី ឬអាចជាចលនវត្ថុ ដូចជាឡាន ម៉ូតូ ក្នុងន័យនេះប្រទានកម្មទាំងនេះមានទាំងការកើនឡើង ក៏ដូចជាថយចុះទៅតាមពេលវេលាផងដែរ ។ ប្រសិនបើតម្លៃនៃផលប្រយោជន៍ពិសេសនោះ បានកើនឡើង ដោយមានការប្រាក់ ផលចំណេញ ដោយឯកឯង ឬដោយបុគ្គលនោះផ្ទាល់ គេគណនាតម្លៃនៃប្រទានកម្មនោះដោយចាត់ទុកថា មានស្ថានភាពដើម នៅពេលចាប់ផ្តើមសន្តតិកម្ម ។

– **<u>វិធីនៃការសម្រួលចំណែកមត៌ករបស់សន្តតិជន ៖</u>**

វិធីនៃការសម្រួលចំណែកមត៌ក គឺធ្វើឡើងដើម្បីបង្កើតនូវភាពត្រឹមត្រូវ ក៏ដូចជាស្មើភាពគ្នាចំពោះសន្តតិជនដែលទទួលផលប្រយោជន៍ពិសេស និងសន្តតិជនដែលមិនទទួលបាននូវផលប្រយោជន៍ពិសេស ។

តម្លៃមត៌កសរុបត្រូវគណនាដូចខាងក្រោម ៖

តម្លៃមត៌កសរុប = តម្លៃមត៌កជាក់ស្តែងនាពេលចាប់ផ្តើមសន្តតិកម្ម + តម្លៃប្រទានកម្មដែលជាផលប្រយោជន៍ពិសេស ។

**<u>ឧទាហរណ៍</u>** ៖ មតកជន A មានកូនចំនួន បីនាក់គឺ X Y Z ។ ដោយ Z បានទទួលនូវផលប្រយោជន៍ពិសេសពីមតកជ A ក្នុងឱកាសអាពាហ៍ពិពាហ៍ នូវទឹកប្រាក់ចំនួន ១៥០០០ ដុល្លារ ។ ហើយទ្រព្យសម្បត្តិដែលបានបន្សល់ទុកក្រោយពេលទទួលមរណភាពនោះចំនួន ៤៥០០០ ដុល្លារ ។

ដូច្នេះតម្លៃមត៌កសរុប = ១៥០០០ ដុល្លារ + ៤៥០០០ ដុល្លារ =៦០០០០ ដុល្លារ ។

នៅក្នុងសិទ្ធិឡើងស្នងមត៌ករបស់សន្តតិជនម្នាក់ៗមានសិទ្ធិទទួលបាននូវចំណែកមត៌កស្មើៗគ្នា ប៉ុន្តែប្រសិនបើមានសន្តតិជនណាម្នាក់បានទទួលផលប្រយោជន៍ពិសេស ហើយផលប្រយោជន៍ពិសេសនោះតិចជាង ឬស្មើតម្លៃនៃចំណែកមត៌កនៃសហសន្តតិជន នោះចំណែកមត៌ករបស់សន្តតិជនត្រូវគណនាដូចខាងក្រោម ៖

– ករណីមានសន្តតិជនទទួលបានផលប្រយោជន៍ពិសេស ៖

ប្រសិនបើផលប្រយោជន៍ពិសេស < (តិចជាង) ចំណែកមត៌ករបស់សហសន្តតិជន ⇨ មត៌កដែលសន្តតិជនដែលទទួលផលប្រយោជន៍ពិសេសទទួលបាន = ចំណែកសិទ្ធិដែលនៅសល់ ។

**<u>ឧទាហរណ៍</u>** ៖ មតកជន A មានកូនចំនួន បីនាក់គឺ X Y Z ។ ដោយ Z បានទទួលនូវផលប្រយោជន៍ពិសេសពីមតកជន A ក្នុងឱកាសអាពាហ៍ពិពាហ៍ នូវទឹកប្រាក់ចំនួន ១៥០០០ ដុល្លារ ។ ហើយទ្រព្យសម្បត្តិដែលបានបន្សល់ទុកក្រោយពេលទទួលមរណភាពនោះចំនួន ៤៥០០០ ដុល្លារ ។

ដោយ មត៌កសរុបរួមទាំងផលប្រយោជន៍ពិសេសរបស់ Z = ៦០០០០ ដុល្លារ , Z បានទទួលនូវផលប្រយោជន៍ពិសេស = ១៥០០០ ដុល្លារ

តាមរូបមន្ត ៖ អ្នកទទួលផលប្រយោជន៍ពិសេស = មត៌កសរុប / ចំនួនសន្តតិជនមានលំដាប់ស្មើ - តម្លៃប្រទានកម្ម

⇨ Z = ៦០០០០ ដុល្លារ ៖ ៣ = ២០០០០ ដុល្លារ - ១៥០០០ ដុល្លារ

= ៥០០០ ដុល្លារ ( នេះជាចំនួនដែល Z ត្រូវទទួលបន្ថែម)

ដូច្នេះ X ទទួលបាន = ២០០០០ ដុល្លារ

Y ទទួលបាន = ២០០០០ ដុល្លារ និង Z ទទួលបាន ៥០០០ ដុល្លារបន្ថែម ។

- ករណីទទួលបានផលប្រយោជន៍ពិសេសលើសពីតម្លៃនៃចំណែកមត៌ក ៖

ទោះបីជាតម្លៃនៃប្រទានកម្ម ឬអច្ច័យទាន ដែលសហសន្តតិជនបានទទួលមានចំនួនលើសពីតម្លៃនៃចំណែកមត៌កក៏ដោយ សហសន្តតិជននោះពុំចាំបាច់បង្វិលមកវិញ នូវទ្រព្យសម្បត្តិដែលទាក់ទងនឹងប្រទានកម្មដើម្បីសហសន្តតិជនផ្សេងទៀតឡើយ លើកលែងតែត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ។ ចំណែកមត៌ករបស់សហសន្តតិជនផ្សេងទៀត ត្រូវមានចំនួនទឹកប្រាក់តាមការគណនាដោយយកមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ទៅបែងចែកតាមសមាមាត្រនៃចំណែកមត៌ករបស់សហសន្តតិជននីមួយៗដែលត្រូវបានកំណត់ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស)។[11]

ដោយក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា (ក្រមរដ្ឋប្បវេណីថ្មី) មាត្រា១១៦៥ ខាងលើនេះបានផ្ទុយទៅនឹងក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ត្រង់មាត្រា ៦០០ ដែលបានបញ្ញត្តិថា ប្រសិនបើចំណែកមត៌កតិចជាងតម្លៃនៃប្រទានកម្ម (ផលប្រយោជន៍ពិសេស) បុគ្គលដែលទទួលនូវផលប្រយោជន៍ពិសេសនោះត្រូវបង្វិលមកវិញទៅលើចំណែកដែលលើស ។ ប៉ុន្តែដោយហេតុថាក្រមថ្មីមានការវិសោធនកម្មទៅលើចំណុចនេះដោយយល់ថាវាមិនសមស្របទៅនឹងអ្នកទទួលផលប្រយោជន៍ពិសេស ព្រោះថារាល់ទ្រព្យសម្បត្តិដែលទទួលបានតាមរយៈប្រទានកម្មនោះគឺ មានការប្រែប្រួលទៅតាមពេលវេលា ឬវត្ថុ ។ មួយវិញទៀត ការបង្វិលនូវចំណែកលើសនៃក្រមថ្មី ត្រូវប្រគល់លុះត្រាតែដើម្បីបង្គ្រប់ភាពបម្រុងដោះស្រាយតែប៉ុណ្ណោះ និងមានការគោរពតាមឆន្ទៈរបស់មតកជនកាលនៅរស់ ឬឆន្ទៈរបស់សហសន្តតិជននោះ ។

**<u>ឧទាហរណ៍</u>** ៖ A ជាឪពុកដែលជាមតកជន ដោយមានកូនចំនួនបីនាក់ ដែលជាសន្តតិជនX Y Z ដោយកាលនៅរស់ A បានធ្វើប្រទានកម្មទៅឱ្យ X ជាកូនបងក្នុងឱកាសអាពាហ៍ពិពាហ៍ជាមួយនឹងដីមួយកន្លែង

[11] មាត្រា១១៦៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

មានតម្លៃ ៧០០០ ដុល្លា និងឱ្យលុយសុទ្ធទៅ Y ចំនួន ៤០០០ ដុល្លា ។ មត៌កដែលបន្សល់ទុកមានចំនួន ៦០០០ ដុល្លា ។

ផ្អែកតាមអង្គហេតុខាងលើនេះ

មត៌កសរុប = ៦០០០ + ៧០០០ + ៤០០០ = ១៧០០០

នាំឱ្យសន្តតិជនម្នាក់ៗទទួលបានចំណែករបស់ខ្លួនគឺ

X = (១៧០០០ ៖ ៣) - ៧០០០ = - ១៣៣៣,៣

Y = (១៧០០០ ៖ ៣) - ៤០០០ = ១៦៦៦,៦

Z = (១៧០០០៖ ៣) = ៥៦៦៦,៦

ដោយ X មិនចាំបាច់បង្វិលសងមកវិញនោះទេ ។

ដូច្នេះ X ទទួលបាន 0 , Y ទទួលបាន = ១៦៦៦,៦ , Z ទទួលបាន = ៥៦៦៦,៦ ។

### ២.៣.២. ករណីភាគនៃវិភាគទាន

- **<u>និយមន័យ</u>** ៖ វិភាគទានពិសេសដើម្បីថែរក្សា ឬបង្កើនទ្រព្យរបស់មតកជនដោយការផ្តល់សេវាកម្មលើកិច្ចការរបស់មតកជន ឬដោយការផ្តល់នូវតាវកាលិកលើទ្រព្យសម្បត្តិ ឬដោយមើលថែទាំព្យាបាលមតកជន ឬតាមរយៈសកម្មភាពផ្សេងៗ ។

ជាធម្មតាការយកចិត្តទុកដាក់ មើលថែ ព្រួយបារម្ភពីសំណាក់សន្តតិជន ទៅកាន់មតកជនតែងតែមាន ដោយហេតុថាមិនថានៅក្នុងសម័យកាលណា ប្រទេសណាការស្រឡាញ់ ការថែទាំពីកូនចៅទៅកាន់ឪពុកម្តាយ យាយតា គឺត្រូវតែមាន ។ ដូច្នេះហើយទើបក្នុងច្បាប់មានចែងពីចំណុចនេះ ក៏ដូចជាបង្ការវិវាទ និងឱ្យតម្លៃទៅលើសកម្មភាពទាំងអស់នេះ។

ក្នុងចំណោមសហសន្តតិជនទាំងឡាយ បើមានបុគ្គលណាបានធ្វើវិភាគទានពិសេស ដើម្បីថែរក្សា ឬបង្កើនទ្រព្យសម្បត្តិរបស់មតកជន ដោយការផ្តល់សេវាកម្មលើកិច្ចការរបស់មតកជន ឬដោយការផ្តល់តាមវតាលិកលើទ្រព្យសម្បត្តិ ឬដោយការថែរទាំព្យាបាលមតកជន ឬ ដោយវិធីផ្សេងទៀត តម្លៃដែលដកភាគនៃវិភាគទានរបស់បុគ្គលនោះដែលបានកំណត់តាមការពិភាក្សារបស់សហសន្តតិជន ចេញពីតម្លៃមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ត្រូវចាត់ទុកថាជាមត៌ក ហើយចំនួនទឹកប្រាក់នៃភាគនៅក្នុងសន្តតិកម្មដែលបានគណនាតាមបញ្ញត្តិនៃផ្នែកទី១ (សន្តតិជន) និង ផ្នែកទី២ (សន្តតិកម្មរបស់សហព័ទ្ធ) បូកនឹងភាគនៃវិភាគទានត្រូវជាចំណែកមត៌ករបស់ជននោះ ។[12]

[12] មាត្រា១១៦៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ក្នុងករណីបើការពិភាក្សាពុំបានសម្រេច ឬបើពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់ភាគនៃវិភាគទាន តាមពាក្យសុំរបស់បុគ្គលដែលបានធ្វើវិភាគទានដែលបានកំណត់ខាងលើ ដោយពិចារណាទៅលើពេលវេលា វិធី និងកម្រិតនៃវិភាគទាននោះ ចំនួនទឹកប្រាក់នៃមត៌ក និងស្ថានភាពទាំងអស់ផ្សេងៗទៀត ។ ពាក្យសុំនេះអាចធ្វើបានក្នុងករណីដែលមានពាក្យសុំ ដោយយោងតាមកថាខណ្ឌទី១ នៃមាត្រា ១២៧០ (ការបែងចែកដោយតុលាការ) ឬមានពាក្យបណ្តឹង ដោយយោងតាមមាត្រា ១២៧៤ (ការទាមទាររបស់ជនដែលត្រូវបានទទួលស្គាល់ក្រោយការបែងចែកមត៌ក) ។[13]

ភាគនៃវិភាគទាន ក៏ជាប្រភេទនៃការសម្រួលចំណែកមត៌ក ដោយក្នុងចំណោមសន្តតិជន មានបុគ្គលណាម្នាក់ ឬច្រើននាក់បានធ្វើសកម្មភាពដូចជា ថែទាំព្យាបាលមតកជន ចេញលុយជួលអ្នកថែទាំ និងចំណាយផ្សេងៗទៅលើថ្នាំសង្កូវ ថ្លៃព្យាបាលទៅលើមតកជន ឬ បង្កើនទ្រព្យដល់មតកជន ឬធ្វើសកម្មភាពនានាដែលជះជាផលល្អដល់មតកជន ។

**<u>ឧទាហរណ៍</u>** ៖ A ជាឪពុកដែលជាមតកជន ដោយមានកូនចំនួនបីនាក់ ដែលជាសន្តតិជន X Y Z ។ X បានធ្វើភាគនៃវិភាគទាន ចំនួន ១៥០០ ដុល្លា និងមត៌កមានចំនួន ៣០០០ ដុល្លា ។

ដោយមត៌កជាក់ស្តែង = ៣០០០ - ១៥០០ = ១៥០០

នាំឱ្យ X =១៥០០ ៖ ៣ + ១៥០០ = ២០០០

Y, Z = ១៥០០ ៖ ៣ = ៥០០

ដូច្នេះ X ទទួលបាន ២០០០ Y, Z ទទួលបាន ៥០០ ម្នាក់ ។

## ២.៤. ការផ្តាច់សិទ្ធិជាសន្តតិជន

### ២.៤.១. ករណីអភ័ព្វបុគ្គល

អភ័ព្វបុគ្គល ជាបុគ្គលដែលគ្មានលក្ខណៈសម្បត្តិក្នុងការទទួលបាននូវសន្តតិកម្ម ដោយមានហេតុណាមួយក្នុងចំណោមហេតុដូចខាងក្រោម៖

- ទទួលទោស ដោយមានចេតនាធ្វើឃាត ឬប៉ុនប៉ងធ្វើឃាតមតកជន ឬអ្នកមានលំដាប់សន្តតិកម្មមុន ឬស្មើ ទោះបីដោយប្រយោល ឬដោយផ្ទាល់ក្តី
- បុគ្គលដែលបានដឹងមុនពីការសម្លាប់មតកជន ប៉ុន្តែមិនរាយការណ៍ ឬមិនប្តឹង លើកលែងតែបុគ្គលនោះមិនអាចវិនិច្ឆ័យល្អ ឬអាក្រក់ ឬអ្នកសម្លាប់ជាសហព័ន្ធ ឬញាតិលោហិតខ្សែផ្ទាល់

[13] មាត្រា១១៦៦ កថាខណ្ឌទី៤ និង៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

- បុគ្គលដែលបានរារាំងពីមតកជន ក្នុងការលុបចោល ឬកែប្រែមរតកសាសន៍ដោយឆបោក ឬគម្រាមកំហែង
- បុគ្គលដែលបានឱ្យមតកជនធ្វើ ឬលុបចោល ឬកែប្រែមរតកសាសន៍ ដោយឆបោក ឬគម្រាមកំហែង
- បុគ្គលដែលបានក្លែង កែបន្លំ បំផ្លាញ់ ឬលាក់ទុកនូវមរតកសាសន៍របស់មតកជន ។[14]

ប៉ុន្តែទោះបីជាយ៉ាងណាកូនរបស់អភ័ព្វបុគ្គលនៅតែអាចឡើងស្នងមត៌កជំនួសឪពុកបាន ដោយហេតុថាកូនគ្មានកំហុស និងមិនបានដឹងលឺពីសកម្មភាពរបស់ឪពុក ឬម្តាយរបស់ខ្លួនដែលបានប្រព្រឹត្តិនោះ ដូច្នេះកូនរបស់អភ័ព្វបុគ្គលអាចធ្វើការទទួលសន្តតិកម្មបាន តាមរយៈសន្តតិជំនួស ។

**<u>ឧទាហរណ៍</u>៖** លោក X ជាមតកជន មានកូន ៣ (បី) នាក់ គឺ A Y និងZ ដោយគាត់បានទទួលមរណភាពដោយសារតែ A បានដឹងពីមូលហេតុនៃការស្លាប់របស់មតកជន ដែលជាលោក X តែធ្វើមិនខ្វល់រវល់ពីបញ្ហានេះ ។

យោងតាមអង្គហេតុខាងលើ លោក A ត្រូវបានក្លាយខ្លួនជាអភ័ព្វបុគ្គលដែលគ្មានសិទ្ធិឡើងស្នងនូវសន្តតិកម្មរបស់មតកជន X បាន ប៉ុន្តែដោយលោក A មានកូន ៥ (ប្រាំ)នាក់ ហើយកូន៥ (ប្រាំ)នាក់ របស់លោកA គឺត្រូវជាចៅរបស់ លោក X ។ ដោយហេតុថា លោក Aជាកូនមានកំហុស ប៉ុន្តែក្មេង ៥(ប្រាំ)នាក់ ដែលជាចៅគ្មានកំហុស គ្មានការដឹងលឺពីបញ្ហារបស់ឪពុក នាំឱ្យចៅទាំង ៥(ប្រាំ) នាក់របស់លោក X មានសិទ្ធិឡើងស្នងសន្តតិកម្មពីមតកជន X ជំនួសឪពុកខ្លួនដែលជាអភ័ព្វបុគ្គល ។ មិនតែប៉ុណ្ណោះបើឪពុក ឬម្តាយមានទោសដាក់ពន្ធនាគារតាមរយៈការប្រព្រឹតត្តិរបស់ខ្លួននោះកូនជននោះក៏មានសិទ្ធិលើសន្តតិកម្មរបស់ឪពុក ឬម្តាយបានដែរ ។ ពោលគឺ ចៅអាចស្នងសន្តតិកម្មជំនួសបានដូចទៅនឹងសន្តតិជនដែលបានទទួលចំណែកតាមលំដាប់ ។

### ២.៤.២. ករណីបុគ្គលដែលត្រូវផ្តាច់ចេញពីសន្តតិកម្ម

ការណ៍បើមតកជនបានដឹងពីការប្រព្រឹត្តរបស់សន្តតិជនណាខ្លះដែលបានប្រព្រឹត្តអំពើដែលមិនគប្បីទៅលើរូបខ្លួននោះ មតកជននឹងធ្វើការផ្តាច់សន្តតិកម្មពីបុគ្គលនោះភ្លាម ។ ដោយមតកជនកាលនៅរស់ បានដាក់ពាក្យសុំទៅតុលាការ ឱ្យផ្តាច់មត៌កពីជនដែលត្រូវបានក្លាយជាសន្តតិជនមិនឱ្យទទួលសន្តតិកម្ម ។ ដោយផ្អែកទៅលើឆន្ទៈរបស់មតកជនដែលខ្លួនមានសិទ្ធិពេញលេញក្នុងការប្រគល់ ដកហូត និងចាត់ចែងនូវទ្រព្យសម្បត្តិរបស់ខ្លួន ។ ជាការពិតណាស់មតកជនដែលជាឪពុក ឬម្តាយបានយល់យ៉ាងច្បាស់ពីបុគ្គលិកលក្ខណៈរបស់កូន ចៅ ដូច្នេះគាត់មានការសម្រេចចិត្តបែងចែកទ្រព្យសម្បត្តិរបស់គាត់តាមការពេញចិត្ត និងសមស្របទៅនឹង

[14] មាត្រា១១៥០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ការប្រព្រឹត្តិរបស់បុគ្គលម្នាក់ៗដែលជាសន្តតិជន ។ មិនតែប៉ុណ្ណោះមតកជនមិនត្រឹមតែផ្តាច់សិទ្ធិពីសន្តតិកម្មទេ សូម្បីតែភាគបម្រុងក៏នឹងមិនបានទទួលនោះដែរ ។

ដូច្នេះជនដែល សន្មត់ថាជាសន្តតិជន ដែលត្រូវបានកាត់ផ្តាច់ចេញពីសន្តតិកម្មដោយមតកជន គឺជនដែលបានប្រព្រឹត្តិសកម្មភាពដូចខាងក្រោម ៖

- ជនដែលធ្វើបាបមតកជន
- ជនដែលបានប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ
- ជនដែលមានសម្ថតភាពគ្រប់គ្រាន់អាចមើលថែទាំមតកជនបាន នៅពេលមានជម្ងឺ ប៉ុន្តែមិនមើលថែទាំ
- ទទួលបានសេចក្តីសម្រេចពីតុលាការ ដាក់ពន្ធនាគារមួយជីវិត
- ប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរ គួរឱ្យកត់សំគាល់ជាអាទិ៍[15] ។

**<u>នីតិវិធីនៃការផ្តាច់មត៌កពីសន្តតិជន</u>**

មតកជន អាចធ្វើបានតាម២ (ពីរ) របៀបដើម្បីផ្តាច់មត៌កពីសន្តតិជនគឺ ៖

**១**. មតកជនអាចដាក់ពាក្យសុំទៅតុលាការ នៅពេលដែលខ្លួននៅមានជីវិត

**២**. មតកជនអាចកំណត់នៅក្នុងមតកសាសន៍ អ្នកប្រតិបត្តិមតកសាសន៍ត្រូវដាក់ពាក្យសុំការអនុញ្ញាតទៅតុលាការ ។[16]

ក្នុងនោះផងដែរលក្ខខណ្ឌនៃការផ្តាច់មត៌កពីសន្តតិកម្មនេះ កើតឡើងតាមរយៈឆន្ទៈរបស់មតកជន និងការពិនិត្យរបស់តុលាការដើម្បីវិនិច្ឆ័យលើបុគ្គលដែលមានលក្ខណៈដូចដែលបានចែងខាងលើ ។ ទោះបីជាយ៉ាងណាក៏ដោយ ការដាក់ពាក្យសុំទៅតាមឆន្ទៈរបស់មតកជនអាចធ្វើទៅបាននៅពេលណាក៏បាន ។

[15] មាត្រា១១៥១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[16] មាត្រា ១១៥៤ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

## ផ្នែកទី៣៖ ការយល់ព្រម និងការបោះបង់ចោលសន្តតិកម្មតាមច្បាប់

### ៣.១. ការយល់ព្រមទទួលយកសន្តតិកម្ម

សន្តតិជនត្រូវធ្វើការយល់ព្រម ឬ បោះបង់សន្តតិកម្មទាំងស្រុង ឬដោយកម្រិត នៅក្នុង អំឡុងពេល ០៣ (បី) ខែ គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើមដោយអំឡុងពេលនេះ អាចពន្យាពេលបាន តាមរយៈពាក្យសុំទៅតុលាការ ដើម្បីទុកលទ្ធភាពឱ្យសន្តតិជនធ្វើការស្រាវជ្រាវមត៌ក នៅមុនពេលបង្ហាញឆន្ទៈ យល់ព្រម ឬបោះបង់ ។ វិធាននេះជាបញ្ញត្តិសម្របសម្រួល ចំពោះសន្តតិជនដែលគ្រាន់តែទទួលសន្តតិកម្ម អាចក្ស័យធនបានដោយសារតែមានកាតព្វកិច្ចធ្ងន់ធ្ងរ ដោយអនុញ្ញាតឱ្យសន្តតិជននោះបោះបង់សន្តតិកម្មបានហើយទោះបីជាមតកជនគ្មានកាតព្វកិច្ចក៏ដោយ ក៏អាចធ្វើបានដែរ ដោយហេតុថា មិនចង់បាន ឬមិនចង់ទទួលមត៌កជាមួយសហសន្តតិជនដទៃទៀតដែលខ្លួនមិនចូលចិត្ត ឬមិនសូវមានទំនាក់ទំនងល្អជាមួយគ្នា ។

លើសពីនេះទៅទៀត ការកំណត់អំឡុងពេល គឺជាការពិចារណាចំពោះទំនាក់ទំនងនៃការអនុវត្តសិទ្ធិលើបំណុលចំពោះមតកជន និងសន្តតិជន ហើយការអនុញ្ញាតឱ្យពន្យាពេលតាមរយៈការដាក់ពាក្យសុំមកតុលាការ គឺជាស្ថានភាពដែលមត៌កច្រើនកន្លែង និងឱ្យតុលាការធ្វើការវិនិច្ឆ័យដោយផ្អែកលើលក្ខខណ្ឌមួយចំនួន ដូចជា គុណភាពនៃមត៌ក កាតព្វកិច្ចដែលទទួលដោយសន្តតិកម្ម ឬការធ្វើបញ្ជីសារពើភ័ណ្ឌ ជាអាទិ៍ ។

**ករណីពិសេសនៃអំឡុងពេល** ៖ បើសន្តតិជនបានទទួលមរណភាពនៅមុនពេលធ្វើការយល់ព្រម ឬបោះបង់ នៅក្នុងអំឡុងពេលដែលបានកំណត់ដោយច្បាប់ ការគណនាអំឡុងពេលត្រូវគិតចាប់ពីពេលវេលាដែលសន្តតិជនរបស់ជននោះ បានដឹងថាសន្តតិកម្មចាប់ផ្តើមចំពោះខ្លួន ។ មួយវិញទៀត បើសន្តតិជន ជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេលកំណត់នេះ គិតចាប់ពីពេលដែលអ្នកតំណាងតាមច្បាប់កំណត់នោះ បានដឹងថា សន្តតិកម្មចំពោះអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅបានចាប់ផ្តើម មានន័យថា ប្រសិនបើ សន្តតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ យល់ព្រម ឬ បោះបង់ សន្តតិកម្មចាំបាច់ត្រូវឱ្យអ្នកតំណាងតាមច្បាប់កំណត់ ធ្វើការសម្រេចដើម្បីសាមីខ្លួន ។

លើសពីនេះទៅទៀត មតកជនមានកាតព្វកិច្ចដែលមានចំនួនទឹកប្រាក់ច្រើន ហើយមិនអាចយកមត៌កទៅសងឱ្យគ្រប់ចំនួន ដោយសន្តតិជនមិនអាចដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចនោះ តាមស្ថានភាពនៃជីវភាពរបស់មតកជន ឬ ស្ថានភាពនៃទ្រព្យរបស់មតកជន ឬស្ថានភាពផ្សេងទៀត អំឡុងពេលដែលបានកំណត់នៅក្នុងច្បាប់សម្រាប់បង្ហាញឆន្ទៈយល់ព្រម ឬបោះបង់ ត្រូវគណនាដោយគិតពីពេលដែលសន្តតិជនបានដឹងអំពីអត្ថិភាពនៃ

កាតព្វកិច្ច ដោយគិតពីស្ថានភាពដែលសន្តតិជនជឿជាក់ថា មតកជនគ្មានមត៌កសកម្មនោះទេ (គោលការណ៍សុចរិត និងស្មោះត្រង់) ។

ម៉្យាងវិញទៀត ជាគោលការណ៍ ការយល់ព្រម ឬការបោះបង់សន្តតិកម្ម មិនអាចលុបចោលបានឡើយ ដោយហេតុថា ការបោះបង់ ឬការយល់ព្រម មានឥទ្ធិពលយ៉ាងខ្លាំងទៅលើផលប្រយោជន៍របស់បុគ្គលពាក់ព័ន្ធ ដូចជា សន្តតិជន ឬម្ចាស់បំណុលរបស់មតកជន ជាអាទិ៍ លើកលែងតែមានអត្ថិភាពនៃវិការៈក្នុងការបង្ហាញឆន្ទៈ ដូចជា ភ័ន្តច្រឡំ ជាអាទិ៍ និងប្រសិនបើមានស្ថានភាពនេះ (វិការៈក្នុងការបង្ហាញឆន្ទៈ) អ្នកមានសិទ្ធិ ត្រូវអនុវត្តសិទ្ធិនេះក្នុងអំឡុងពេល ០៦ (ប្រាំមួយ) ខែ គិតចាប់ពីពេលដែលខ្លួនបានដឹង ឬ ០៥ (ប្រាំ) ឆ្នាំ គិតចាប់ពីសន្តតិកម្មបានចាប់ផ្តើម តាមរយៈពាក្យសុំតុលាការ ។

ក្នុងករណីសន្តតិជនមិនទាន់បានបង្ហាញឆន្ទៈយល់ព្រម ឬបោះបង់សន្តតិកម្ម ឬអ្នកទទួលបន្តសន្តតិកម្មមិនទាន់មានលក្ខណៈច្បាស់លាស់ ប្រសិនបើម្ចាស់បំណុលរបស់មតកជនមានបំណងធ្វើបណ្តឹង ជាបឋមត្រូវទាមទារឱ្យធ្វើការជ្រើសតាំងអ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្ន និងអាចចាប់ផ្តើមធ្វើសកម្មភាពបណ្តឹងបានចំពោះអ្នកគ្រប់គ្រងមត៌កនោះ ឬម្ចាស់ទ្រព្យបានទទួលមរណភាពនៅពេលបណ្តឹងកំពុងត្រូវបានចាត់ការ ហើយនីតិវិធីបណ្តឹងនោះត្រូវផ្អាក រហូតដល់ពេលសន្តតិជនយល់ព្រមចំពោះសន្តតិកម្ម ក៏ត្រូវឱ្យម្ចាស់បំណុលនៃមតកជន នោះទាមទារឱ្យមានអ្នកគ្រប់គ្រងមត៌កបណ្តោះអាសន្ន ផងដែរ ប្រសិនចង់បន្តបណ្តឹងនោះឱ្យមានភាពឆាប់រហ័ស ។

### ៣.១.១. ការយល់ព្រមទទួលយកទាំងស្រុង

ក្នុងករណីដែលសន្តតិជនទទួលយល់ព្រមទាំងស្រុងនូវសន្តតិកម្ម មានន័យថា សន្តតិជនត្រូវទទួលបន្តដោយគ្មានកម្រិតនូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជន ដោយតម្រូវឱ្យបង្ហាញឆន្ទៈជាការគ្រប់គ្រាន់ មានន័យថាមិនចាំបាច់ដាក់ពាក្យសុំទៅតុលាការដូចករណីយល់ព្រមដោយកម្រិត ឬបោះបង់សន្តតិកម្មនោះឡើយ ។ មួយវិញទៀតប្រសិនបើសន្តតិជន បានធ្វើសកម្មភាពណាមួយក្នុងចំណោមសកម្មភាព ខាងក្រោមនេះ ត្រូវចាត់ទុកថា យល់ព្រមទាំងស្រុង (ការយល់ព្រមទាំងស្រុងតាមច្បាប់) ៖

- សន្តតិជនបានចាត់ចែងមត៌កនោះទាំងអស់ ឬមួយភាគ លើកលែងតែសកម្មភាពរក្សា ឬគ្រប់គ្រង
- សន្តតិជនមិនបានបង្ហាញឆន្ទៈយល់ព្រម ឬ បោះបង់ នៅក្នុងអំឡុងពេល ០៣ (បី) ខែ គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើមលើកលែងតែមានពាក្យសុំពន្យាពេលទៅតុលាការ
- ទោះបីជាសន្តតិជនបានបង្ហាញឆន្ទៈយល់ព្រម ឬ បោះបង់ក៏ដោយ ប៉ុន្តែសន្តតិជនបានលាក់មត៌កទាំងអស់ ឬមួយភាគ ឬបានប្រើប្រាស់មត៌កនោះដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន លើកលែងតែនៅក្រោយពេលជនដែលត្រូវបានសន្មត់ជាសន្តតិជនដោយសារការបោះបង់របស់សន្តតិជនលំដាប់មុនបានយល់

ព្រម ដោយហេតុថា ក្នុងករណីសន្តតិជននៃលំដាប់បន្ទាប់បានយល់ព្រម សន្តតិកម្មនេះត្រូវឱ្យទៅសន្តតិជនលំដាប់បន្ទាប់នោះ ដើម្បីមានសន្ទនាភាព និងសង្គតិភាពតាមផ្លូវច្បាប់ ហេតុនេះ ប្រសិនបើសន្តតិជនលំដាប់មុនបានធ្វើសកម្មភាពបែបនេះ សន្តតិជនលំដាប់ បន្ទាប់អាចធ្វើការទាមទារឱ្យសន្តតិជនលំដាប់មុនប្រគល់មត៌កវិញ ឬទាមទារឱ្យសងសំណងនៃការខូចខាត ។

### ៣.១.២. ការយល់ព្រមទទួលយកដោយមានកម្រិត

ការយល់ព្រមដោយមានកម្រិតមានខ្លឹមសារថា ជាការធ្វើសកម្មភាពនៃសន្តតិកម្មដែលបម្រុងសម្រាប់សងកាតព្វកិច្ច និងទទួលដោយសន្តតិកម្ម ត្រឹមកម្រិតទទួលដោយសន្តតិកម្ម មានន័យថា សន្តតិជនក្លាយទៅជាកូនបំណុល ដោយទទួលនូវសន្តតិកម្មនៃកាតព្វកិច្ចទាំងអស់របស់មតកជន ប៉ុន្តែសន្តតិជនអាចកម្រិតការទទួលខុសត្រូវបានត្រឹមកម្រិតនៃចំណែកមត៌ក លើកលែងសន្តតិជនសងកាតព្វកិច្ចដោយស្ម័គ្រចិត្ត ។ មួយវិញទៀត ករណីកាតព្វកិច្ចលើសពីមត៌កសកម្ម ប្រសិនបើសន្តតិជនយល់ព្រមដោយកម្រិត ចាំបាច់ត្រូវធ្វើនីតិវិធីជម្រះបញ្ជី ដើម្បីសងម្ចាស់បំណុល ហើយបើសល់ទើបចែក ប៉ុន្តែបើមិនសល់ មិនចាំបាច់ទទួលខុសត្រូវនោះទេ។

- វិធី ៖ ដើម្បីធ្វើការយល់ព្រមដោយមានកម្រិត សន្តតិជនត្រូវដាក់ពាក្យសុំមកតុលាការក្នុងអំឡុងពេល ០៣ (បី) ខែ គិតចាប់ពីពេលដឹងថាសន្តតិកម្មបានចាប់ផ្តើមចំពោះខ្លួន ប៉ុន្តែអំឡុងពេលនេះអាចពន្យាពេលបាន បើមានការអនុញ្ញាតពីតុលាការ តាមពាក្យសុំរបស់សាមីខ្លួន ។ មួយវិញទៀត នៅពេលដែលដាក់ពាក្យសុំទៅតុលាការ សន្តតិជនត្រូវដាក់បញ្ជីសារពើភ័ណ្ឌនៃមត៌ក ដោយបញ្ជាក់អំពីមត៌កសកម្ម និងមត៌កអកម្ម ដែលសន្តតិជនបានទទួល នៅពេលចាប់ផ្តើមសន្តតិកម្ម ក្នុងកម្រិតលទ្ធភាពដែលខ្លួនបានដឹង និងប្រសិនបើមិនបានបញ្ជាក់ឱ្យច្បាស់លាស់ដោយចេតនា ត្រូវចាត់ទុកថាយល់ព្រមទាំងស្រុង ។
- អានុភាព ៖ អានុភាពនៃការយល់ព្រមដោយកម្រិត ដែលមានខ្លឹមសារថាម្ចាស់បំណុលរបស់មតកជនមិនអាចទាមទារឱ្យសន្តតិជនទទួលខុសត្រូវចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជន ប៉ុន្តែជាលក្ខណៈសារធាតុ ទ្រព្យសម្បត្តិជាមត៌កត្រូវធ្វើការជម្រះបញ្ជីផ្សេងៗពីទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជន ហេតុនេះសិទ្ធិលើបំណុល និងកាតព្វកិច្ចរបស់សន្តតិជន និងមតកជន មិនអាចរលត់ដោយព្យាកុលនោះទេ ។
- ការយល់ព្រមដោយកម្រិត កើតឡើងមុនការយល់ព្រមតាមច្បាប់៖ សន្តតិជនយល់ព្រមដោយកម្រិត បើមានមូលហេតុដែលជាការទទួលខុសត្រូវទាំងស្រុងតាមផ្លូវច្បាប់ ផលប្រយោជន៍នៃការយល់ព្រមដោយកម្រិតត្រូវបានបាត់បង់ ។ សន្តតិជនត្រូវទទួលខុសត្រូវដូចគ្នានឹងអ្នកយល់ព្រមទាំងស្រុង ។ ករណី

សន្តតិជនច្រើននាក់ សន្តតិជនម្នាក់ ឬ ច្រើននាក់ក្នុងចំណោមសហសន្តតិជនទាំងនោះ មានមូលហេតុនៃការយល់ព្រមទាំងស្រុង នាំឱ្យធ្វើការជម្រះបញ្ជីមត៌ក បន្ទាប់មកបើខ្វះខាត អាចយកទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជនដែលមានមូលហេតុនៃការយល់ព្រមទាំងស្រុងតាមច្បាប់មកសងបន្ថែម ។ កម្រិតនៃការទទួលខុសត្រូវនេះ ទោះបីជាការយល់ព្រមដោយកម្រិតក៏ដោយ សហសន្តតិជនត្រូវទទួលបន្តនូវកាតព្វកិច្ចរបស់មតកជនទៅតាមចំណែកមត៌ក ប៉ុន្តែការទទួលខុសត្រូវមានកម្រិត ត្រឹមកម្រិតមត៌កប៉ុណ្ណោះ ។ ម្ចាស់បំណុលរបស់មតកជនអាចអនុវត្តសិទ្ធិរបស់ខ្លួនទៅលើសហសន្តតិជនម្នាក់ ឬច្រើននាក់ចំពោះចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលតាមចំណែកមត៌កនីមួយៗបាន ។

### ៣.២. ការបោះបង់ចោលសន្តតិកម្មតាមច្បាប់

បុគ្គលដែលមានបំណងបោះបង់សន្តតិកម្ម ត្រូវដាក់ពាក្យសុំទៅតុលាការនៅក្នុងអំឡុងពេល ០៣ (បី) ខែ គិតចាប់ពីពេលដឹងថាសន្តតិកម្មចាប់ផ្តើមចំពោះខ្លួនលើកលែងតែមានពាក្យសុំពន្យាពេលទៅតុលាការហើយតុលាការអនុញ្ញាត[17] ។ ប្រសិនបើ សន្តតិជនបានសម្រេចចិត្តបោះបង់សន្តតិកម្ម ច្បាប់ចាត់ទុកថា បុគ្គលនោះមិនមែនជាសន្តតិជនតាំងពីដំបូងមក [18]។

**ឧទាហរណ៍**៖ ឪពុកឈ្មោះ A និង ម្តាយឈ្មោះ B បានទទួលមរណភាព មានកូនពីរនាក់ គឺ **លោក** X និង **លោក** Y ។ ក្នុងករណីនេះ កូនរបស់លោកទាំងពីរអាចបោះបង់សន្តតិកម្មក៏បាន ហេតុនេះដើម្បីឱ្យការបោះបង់សន្តតិកម្មមានអានុភាព សន្តតិជនដែលជាអ្នកបោះបង់ ត្រូវដាក់ពាក្យសុំទៅកាន់តុលាការ ។

## ផ្នែកទី៤៖ អំពីស្ថានភាពពិសេសនៃសន្តតិកម្មតាមច្បាប់

ដោយសារតែមានករណីមួយចំនួនដែលសន្តតិកម្មខ្វះគ្មានសន្តតិជនឡើងស្នងនូវមត៌កដែលបន្សល់ទុកពីមតកជនឡើយ ជាហេតុនាំឱ្យមានការស្វែងរកនូវសន្តតិជនដើម្បីមកធ្វើការស្នងមត៌កពីមតកជននោះ ប៉ុន្តែបើក្នុងករណីដែលគ្មានសន្តតិជនតែម្តង មត៌កនឹងត្រូវធ្លាក់ទៅលើជនដែលមាននិស្ស័យពិសេស (នត្ថិភាពនៃសន្តតិជន) ។ ផ្ទុយទៅវិញ បើក្នុងករណីដែលមានជនមកទទួលមត៌កក្នុងនាមខ្លួនជាសន្តតិជន ដោយគ្មានមូលហេតុគតិយុត្តណាមួយក្នុងការទទួយសន្តតិកម្មនោះទេ ។ ពោលគឺ ខុសនឹងវិធានច្បាប់នោះជាហេតុដែលសន្តតិជនត្រូវធ្វើការទាមទារបដិទានត្រឡប់មកវិញ ។

[17] សៀវភៅ ការបែងចែកមត៌ក នៅថ្ងៃទី១៥ ខែមករា ឆ្នាំ ២០១៨ របស់មេធាវី អ៊ីវ ប៉ូលី
[18] មាត្រា ១២៦១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

## ៤.១. អំពីនត្ថិភាពនៃសន្តតិជន

### ៤.១.១. នីតិបុគ្គលមត៌ក

ប្រសិនបើពុំច្បាស់ ឬពុំមានសន្តតិជន មត៌កត្រូវក្លាយជានីតិបុគ្គល ។[19] ដោយសារតែគ្មាននូវសន្តតិជនមកស្នងមត៌ក ទើបតុលាការត្រូវជ្រើសតាំងអ្នកគ្រប់គ្រងមត៌ក តាមរយៈពាក្យសុំរបស់បុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍( ឧ. ម្ចាស់បំណុល អច្ច័យលាភី បុគ្គលដែលមាននិស្ស័យពិសេស ) មេឃុំ ឬចៅសង្កាត់នៃលំនៅដ្ឋានចុងក្រោយរបស់មតកជន ឬតំណាងអយ្យការ ។[20] បើបានជ្រើសតាំងអ្នកគ្រប់គ្រងមត៌កហើយ តុលាការត្រូវធ្វើការជូនដំណឹងជាសាធារណៈអំពីការណ៍នេះគ្មានការយឺតយ៉ាវ ។[21] តុលាការជ្រើសតាំងអ្នកគ្រប់គ្រង តាមដីកាសម្រេច ។ បន្ទាប់ពីការជូនដំណឹងរយៈពេល ២(ពីរ) ខែ អ្នកគ្រប់គ្រងត្រូវជូនដំណឹងជាសាធារណៈចំពោះម្ចាស់បំណុល និងអច្ច័យលាភីទាំងអស់ ដើម្បីឱ្យមានការទាមទារក្នុងអំឡុងពេលកំណត់នេះមិនត្រូវឱ្យតិចជាង ២(ពីរ) ខែ ឡើយ ។[22] ដោយសរសេរបញ្ជាក់ថា បើមិនបានស្នើសុំក្នុងអំឡុងពេលកំនត់ទេ សិទ្ធិលើបំណុលនឹងត្រូវដកចេញពីការជម្រះ ។[23] អ្នកគ្រប់គ្រងត្រូវដាស់តឿនដោយឡែក ចំពោះម្ចាស់បំណុល ឬអច្ច័យលាភីដែលខ្លួនបានដឹង ដើម្បីឱ្យធ្វើការស្នើសុំ ។[24] ក្រោយពីអំឡុងពេលដែលបានកំណត់ មានរយៈពេល ២(ពីរ) ខែនោះ បានកន្លងផុតទៅ ដោយនៅតែមិនទាន់ដឹងច្បាស់ថាមានសន្តតិជននៅឡើយតាមពាក្យសុំរបស់អ្នកគ្រប់គ្រង ឬ តំណាងអយ្យការ តុលាការត្រូវធ្វើការជូនដំណឹងជាសាធារណៈថា ប្រសិនបើមានសន្តតិជន សន្តតិជននោះត្រូវធ្វើការស្នើសុំអំពីការណ៍នោះ ក្នុងអំឡុងពេលដែលកំណត់ ។ ដោយអំឡុងពេលនៃការប្រកាសស្វែងរកនេះមិនត្រូវឱ្យតិចជាងរយៈពេល ៦ (ប្រាំមួយ) ខែ ឡើយ ។ ប៉ុន្តែបើផុតរយៈពេល ៦(ប្រាំមួយ) ខែ នៅតែមិនមានសន្តតិជនបង្ហាញខ្លួន សន្តតិជនទាំងអស់នោះនឹងបាត់បង់សិទ្ធិ ហើយអ្នកគ្រប់គ្រងមត៌ក មានកាតព្វកិច្ចសងបំណុល និងបែងចែកមត៌កទៅឱ្យជនដែលមាននិស្ស័យពិសេស ឬធ្លាក់ទៅជាសម្បត្តិរដ្ឋ ។ ប្រសិនបើករណីរកឃើញនូវសន្តតិជនមកធ្វើការស្នងវិញនោះ អ្នកគ្រប់គ្រងក៏ត្រូវអស់សិទ្ធិចាប់ពីពេលនោះផងដែរ ។

[19] មាត្រា១២៩០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[20] មាត្រា១២៩១ នៃកថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[21] មាត្រា១២៩១ នៃកថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[22] មាត្រា១២៩៦ នៃកថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[23] មាត្រា១២៨១ នៃកថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[24] មាត្រា១២៨១ នៃកថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ៤.១.២. ចំណែកចំពោះជនដែលមាននិស្ស័យពិសេស

ជនដែលមាននិស្ស័យពិសេស គឺជាបុគ្គលដែលមិនមែនជាសន្តតិជនតែមានជីវភាពរស់នៅជាមួយគ្នានឹងមតកជន ឬជាបុគ្គលដែលបានខិតខំមើលថែព្យាបាលមតកជននៅពេលដែលមតកជននៅមានជីវិត ។

ក្នុងករណីដែលគ្មានសន្តតិជនចេញបង្ហាញខ្លួនតាមការប្រកាសជាសាធារណៈ ដើម្បីស្វែងរកសន្តតិជន ដូច្នេះច្បាប់បានកំណត់នូវភាពចាំបាច់ដែលត្រូវដកហូតសិទ្ធិពីសន្តតិជន ដើម្បីធ្វើការបែងចែកមត៌កទៅឱ្យជនដែលមាននិស្ស័យពិសេស ។ ការដកហូតសិទ្ធិរបស់សន្តតិជន ចាំបាច់ត្រូវឆ្លងកាត់ការប្រកាសជាសាធារណៈ ៣ ដង មានន័យថាយ៉ាងតិច ៨ខែ ។ ម៉្យាងទៀត ចំពោះម្ចាស់បំណុល ឬ អច្ច័យលាភីដែលអ្នកគ្រប់គ្រងមិនបានដឹងទេនោះ ដោយសារតែមិនបានស្នើសុំអំពីការទាមទារសិទ្ធិក្នុងអំឡុងពេលនៃការប្រកាសជាសាធារណៈដែលបានកំណត់ក្នុងរយៈពេល ២ខែ ជាបឋម អាចទទួលការសងពីទ្រព្យសម្បត្តិដែលនៅសេសសល់តែប៉ុណ្ណោះ លើសពីនេះទៅទៀត ប្រសិនបើមិនបានស្នើសុំសិទ្ធិនៅក្នុងអំឡុងពេលប្រកាសជាសាធារណៈដែលបានកំណត់នៅក្នុងរយៈពេល ៦ខែ ថែមទៀតទេ ត្រូវដកហូតសិទ្ធិដោយយោងតាមមាត្រា ១២៩៨ ។[25]

ជនដែលមាននិស្ស័យពិសេសមិនអាចទទួលមត៌កលើសពីចំនួនពាក់កណ្ដាលនៃចំណែកមត៌កទាំងអស់ដែលសល់ក្រោយការជម្រះ ។ ការដាក់ពាក្យសុំរបស់ជនដែលមាននិស្ស័យពិសេស ត្រូវធ្វើក្នុងអំឡុងពេល ៣(បី) ខែ ក្រោយអំឡុងពេលនៃការប្រកាសស្វែងរកសន្តតិជន ដោយជននោះត្រូវបញ្ជាក់ពីហេតុនៃនិស្ស័យពិសេសរវាងខ្លួន និងមតកជនឱ្យបានច្បាស់លាស់ទៅកាន់តុលាការ ។ ជាមួយគ្នានេះដែរ ការចែកទ្រព្យទៅឱ្យជនដែលមាននិស្ស័យពិសេសត្រូវឆ្លងកាត់ការស្រាវជ្រាវអំពីអង្គហេតុ និងមានការសាក់សួរយោបល់ពីតុលាការទៅកាន់មេឃុំ ឬចៅសង្កាត់ ។[26]

### ៤.១.៣. មត៌កដែលក្លាយជារដ្ឋ

ចំពោះមត៌កដែលគ្មានសន្តិជន មត៌កនោះត្រូវក្លាយជានីតិបុគ្គល មួយវិញទៀតបើមត៌កនោះគ្មានទាំងជនដែលមាននិស្ស័យពិសេសទេទ្រព្យដែលនៅសេសសល់ក្រោយការជម្រះនោះ នឹងត្រូវធ្លាក់ទៅជាទ្រព្យសម្បត្តិរដ្ឋ ។ ហេតុដែលនាំឱ្យទ្រព្យក្លាយទៅជាទ្រព្យរដ្ឋ ព្រោះទ្រព្យនោះមិនមានអ្នកគ្រប់គ្រង និងគ្មានអ្នកណាអាចធ្វើជាម្ចាស់កម្មសិទ្ធិករ ។ ចំពោះអចលនទ្រព្យដែលគ្មានម្ចាស់កម្មសិទ្ធិករ អចលនទ្រព្យនោះធ្លាក់ទៅជាទ្រព្យរដ្ឋដោយរដ្ឋជាកម្មសិទ្ធិករ ។ មួយវិញទៀត បើចលនទ្រព្យវិញ អ្នកដែលធ្វើការកាន់កាប់ចុងក្រោយនឹងក្លាយជាម្ចាស់កម្មសិទ្ធិលើចលនទ្រព្យនោះ ប៉ុន្តែបើមិនមានទេចលនទ្រព្យនោះនឹងធ្លាក់ទៅជាទ្រព្យរដ្ឋផងដែរ ។

[25] មាត្រា ១២៩៨ នៃសេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ៤ គន្ថីទី៨ រៀបរៀងដោយ ក្រសួងយុត្តិធម៌ ឆ្នាំ២០១០

[26] មាត្រា១២៩៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

## ៤.២. អំពីបដិទាននៃសន្តតិកម្ម

– **និយមន័យ** ៖ បដិទាន គឺជាការស្ដាឡើងវិញនូវស្ថានភាពដើម ឬការប្រគល់ត្រឡប់វិញ ។ ឧទាហរណ៍ ៖ ការបង្វិលសងវត្ថុដែលម្ចាស់បំណុលបានប្រគល់ ឬសងប្រាក់ដែលកូនបំណុលបានបង់ ឬបង្វិលសងវត្ថុដែលម្ចាស់បំណុលកំពុងប្រើប្រាស់ ឬថែរក្សាគ្រប់គ្រងទៅកូនបំណុលវិញ ឬការបង្វិលសងវិញនូវទ្រព្យមត៌កដែលអ្នកដែលគ្មានសិទ្ធិខាងសន្តតិកម្មបានទទួលជាដើម ។[27]

គោលបំណងនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម ដោយសារតែសន្តតិជនដែលត្រូវបានដកហូតសិទ្ធិសន្តតិកម្ម អាចទាមទារឱ្យធ្វើបដិទានសន្តតិកម្មដើម្បីទទួលបដិទាននៃមត៌កទាំងអស់ ឬមួយផ្នែកបាន ។[28] មួយវិញទៀតការទាមទារធ្វើបដិទាន គឺធ្វើឡើងតាមរយៈសន្តតិជនដែលមិនបានចូលរួមក្នុងការបែងចែកមត៌ក និងសន្តតិជនដែលមានសិទ្ធិពេញលេញ ក្នុងការទទួលនូវចំណែកមត៌ករបស់ខ្លួនប៉ុន្តែបែរជាមិនបានទទួលដោយមានមូលហេតុផ្សេងៗ ដូច្នេះសន្តតិជននោះមានសិទ្ធិធ្វើការទាមទារចំណែករបស់ខ្លួនពីជនដែលគេយល់ថាជាសន្តតិជនតាមសភាពខាងក្រៅ ដែលកំពុងកាន់កាប់មត៌កដែលទទួលតាមរយៈសន្តតិកម្មឱ្យប្រគល់មកវិញនូវទ្រព្យនោះ ។ ក្នុងករណីនេះគឺ មានន័យថាមានបញ្ហាគតិយុត្តមួយចំនួនបានកើតឡើងដូចជាការច្រឡំសំបុត្រកំណើតដែលជននោះមានឈ្មោះជាកូនមតកជនដែលធាតុពិតជននោះមិនបានជាប់ខ្សែលោហិតនឹងមតកជនឡើយ ។ លើសពីនេះ ក្នុងពេលដែលមតកជននៅរស់បានទទួលស្គាល់បុគ្គលម្នាក់ជាកូន ប៉ុន្តែមិនបានប្រាប់ទៅគ្រួសារខ្លួន នៅពេលដែលបើកសន្តតិកម្ម សហព័ទ្ធ កូន ក៏ដូចជាគ្រួសាររបស់មតកជនគិតថាសហសន្តតិជនគឺជាសាមីខ្លួនគេ ដោយធ្វើការបែងចែកមត៌កទៅតាមចំណែករបស់ខ្លួន ។ ចំពោះករណីនេះជនដែលមតកជនទទួលស្គាល់ថាជាកូនមានសិទ្ធិទារទាមធ្វើបដិទាន ដោយធ្វើការបែងចែកមត៌កសាជាថ្មី ។ ការបែងចែកមត៌កដែលបានធ្វើឡើងដោយអវត្តមានរបស់សន្តតិជននោះ គឺជាការបែងចែកដែលទុកជាមោឃៈដោយសារសន្តតិជនមិនគ្រប់ចំនួន ។[29] មិនតែប៉ុណ្ណោះ ចំពោះការប្រគល់មកវិញនៅទ្រព្យ ភាគីដែលបានកាន់កាប់ត្រូវប្រគល់មត៌កមកឱ្យសន្តតិជនដែលបានទាមទារ ។ ប៉ុន្តែបើភាគីនោះមានភាពសុចរិត ជននោះមានសិទ្ធិរក្សាទុកនូវផល និងការប្រាក់ដែលបានទទួល សិទ្ធិទាមទារឱ្យសងនូវសោហ៊ុយដែលបានបង្កើនតម្លៃចំពោះទ្រព្យនោះ ហើយមានសិទ្ធិទាមទារសំណងចំពោះកាតព្វកិច្ចដែលត្រូវបានទទួលតាមរយៈសន្តតិកម្មដែលបានសងរួចហើយនោះ ។ ផ្ទុយទៅវិញ បើភាគីនោះមានភាពទុច្ចរិត ជននោះត្រូវសងមកវិញគ្រប់ចំនួន បូករួមទាំងផល ការប្រាក់ដែលបាន

[27] សទ្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី និង នីតិរដ្ឋប្បវេណី រៀបចំដោយ គណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះពុម្ព ដោយទីស្ដីការគណៈរដ្ឋមន្ត្រី នៅឆ្នាំ២០០៧

[28] មាត្រា១៣០១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[29] មាត្រា ១៣០២ នៃសេចក្ដីពន្យល់ក្រមរដ្ឋប្បវេណី ភាគ៤ គន្ថីទី៨ រៀបរៀងដោយ ក្រសួងយុត្តិធម៌ ឆ្នាំ២០១០

ទទួល ហើយមិនត្រឹមតែប៉ុណ្ណោះជននោះក៏គ្មានសិទ្ធិទាមទារសំណងចំពោះកាតព្វកិច្ច និងថែមទាំងគ្មានសិទ្ធិទាមទារឱ្យសងវិញនូវសោហ៊ុយដែលបានបង្កើនតម្លៃចំពោះទ្រព្យនោះផង ។[30]

អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យធ្វើបដិទានសន្តតិកម្ម នៅក្នុងករណីដែលមត៌កត្រូវបានផ្ទេរទៅភាគីម្ខាងទៀតនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម តាមមតកសាសន៍ ឬការបែងចែក មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំគិតចាប់ពីពេលដែលធ្វើការផ្ទេរ ។ ប៉ុន្តែបើក្នុងករណីដែលជនគ្មានសិទ្ធិតែម្នាក់ទទួលសន្តតិកម្មក្នុងនាមជាសន្តតិជនវិញ អំឡុងពេលនៃការទាមទារនេះ ក៏មានអំឡុងពេល ៥(ប្រាំ) ឆ្នាំដែរ តែរាប់គិតពីថ្ងៃដែលមតកជនបានទទួលមរណភាពវិញ ។[31]

[30]មាត្រា១៣០១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[31] មាត្រា ១៣០៤ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

# ជំពូកទី២

# ការបែងចែកមត៌កតាមច្បាប់

# ជំពូកទី២

# ការអនុវត្តនៃសន្តតិកម្មតាមច្បាប់

ជាការពិតណាស់ បន្ទាប់ពីមតកជនទទួលមរណភាពទៅ មតកជនមិនបានធ្វើបណ្តាំ ឬផ្តាំកូនចៅនោះ ការបែងចែកមត៌កត្រូវប្រព្រឹត្តទៅតាមច្បាប់ ពោលគឺយើងនឹងធ្វើការបកស្រាយនៅផ្នែកទី១(របបនៃការគ្រប់គ្រង និងការបែងចែកសន្តតិកម្មតាមច្បាប់)ផ្នែកទី២ (បកស្រាយពីសិទ្ធិរបស់សន្តតិជន និងអត្រានៃពន្ធ) និងផ្នែក៣ (នីតិវិធីនៃការប្តឹងទាមទារមត៌ក) ខាងក្រោមនេះ ៖

## ផ្នែកទី១៖ របបនៃការគ្រប់គ្រង និងការបែងចែកសន្តតិកម្មតាមច្បាប់

### ១.១. របបនៃការគ្រប់គ្រង

គ្មានបុគ្គលណាម្នាក់មានសិទ្ធិកាន់កាប់ ចាត់ចែង ទ្រព្យសម្បត្តិអ្នកដទៃណាម្នាក់ផ្សេងទៀតនោះទេ បើទោះបីជាបុគ្គលនោះ ជាសាច់ញាតិ ខ្សែរលោហិត ឬឪពុកម្តាយ ជាបងជាប្អូន ក៏គ្មានសិទ្ធិគ្រប់គ្រង កាន់កាប់ទ្រព្យរបស់បុគ្គលទាំងអស់នោះបានដែរ ដោយហេតុថាបុគ្គលម្នាក់ៗមានសិទ្ធិផ្តាច់មុខទៅលើទ្រព្យរបស់ខ្លួនរៀងៗខ្លួន ។ ក៏ប៉ុន្តែក្នុងករណីដែលម្ចាស់ទ្រព្យបានទទួលមរណភាពដោយមិនបានបន្សល់ទុកនូវបណ្តាំ ដើម្បីបែងចែកទ្រព្យសម្បត្តិរបស់ខ្លួន បុគ្គលក្រៅពីម្ចាស់ទ្រព្យអាចគ្រប់គ្រងទ្រព្យសម្បត្តិនោះបណ្តោះអាសន្នបាន ដោយយោងតាមក្រមរដ្ឋប្បវេណី២០០៧ បានបញ្ញតិពីជនដែលគ្រប់គ្រងទ្រព្យសម្បត្តិបណ្តោះអាសន្នរបស់មតកជនមុនពេលការបែងចែកមត៌ករួមមាន ៖

**– សន្តតិជនដែលកាន់កាប់មត៌ក**

នៅពេលមតកជនបានទទួលមរណភាព ត្រូវរក្សាទុក និង គ្រប់គ្រងមត៌កនោះរហូតដល់ពេលធ្វើការបែងចែកមត៌ក [32] ការគ្រប់គ្រងនេះជាការគ្រប់គ្រងស្របច្បាប់[33]។ ទោះបីជាមុនពេលយល់ព្រម ឬបោះបង់សន្តតិកម្មក៏ដោយ សន្តតិជនត្រូវគ្រប់គ្រងមត៌កនោះ ដោយប្រុងប្រយ័ត្នដូចគ្នានឹងទ្រព្យសម្បត្តិផ្ទាល់ខ្លួនផងដែរ។

**ឧទាហរណ៍៖ លោក A** បានស្លាប់ដោយបន្សល់នូវមត៌ក មាន លុយ ៣០០០ ដុល្លារ និងខ្សែកមាស១ខ្សែតម្លៃ ៣០០០០ ដុល្លារ ។ **លោក A** គ្មានភរិយា ប៉ុន្តែមានកូន ២ នាក់ គឺ **លោក ក** និង **លោក ខ** ។ **លោក ក** បានគ្រប់គ្រងមត៌ករបស់ឪពុកតាំងពីគាត់ជរា រហូតមកដល់ពេលឪពុកទទួលមរណភាពទៅទ្រព្យសម្បត្តិដែល **លោក ក** គ្រប់គ្រងពីមុនត្រូវរក្សាទុក ទ្រព្យនោះឱ្យដូចជាទ្រព្យរបស់ខ្លួន រហូតដល់មានការបែងចែកមត៌ក ព្រោះ **លោក A** មានសន្តតិជន ២ នាក់ដែលត្រូវមកទទួលទ្រព្យរបស់ខ្លួន ។

[32] មាត្រា១២៦២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រឆ្នាំ ២០០៧

[33] មាត្រា១២៦២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រឆ្នាំ ២០០៧

- **អ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្ន**

គ្រប់គ្រងដោយ អ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្ន ត្រូវបានជ្រើសតាំងដោយតុលាការ ។ ប៉ុន្តែ តុលាការហាមឃាត់មិនឱ្យដាក់ពាក្យបណ្តឹងចំពោះសន្តតិជននៅមុនពេលយល់ព្រមនោះទេ លើកលែងតែគ្មាន អ្នកគ្រប់គ្រងមត៌ក និង អ្នកគ្រប់គ្រងមតកសាស៍ទើប សន្តតិជន អច្ច័យលាភីឬ ម្ចាស់បំណុលរបស់មតកជន អាចដាក់ពាក្យឱ្យតុលាការមានឆន្ទានុសិទ្ធិ ក្នុងការកំណត់យកអ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្ន ។ រាល់ សោហ៊ុយដែលទាក់ទងនឹងមត៌ក ត្រូវកាត់ចេញពីមត៌ករបស់មតកជន ប៉ុន្តែសោហ៊ុយដែលកើតចេញពីកំហុស របស់សន្តតិជន គឺជាបន្ទុករបស់សន្តតិជននោះ។

**ឧទាហរណ៍៖** លោក B បានស្លាប់បានបន្សល់ទុកលុយនៅធនាគារ ២០០០ ដុល្លារ និងផ្ទះតម្លៃ ៣០០០០ ដុល្លារ និងមានពាណិជ្ជកិច្ចនាំចូលខោអាវពីបរទេស ក៏ប៉ុន្តែគាត់បានខ្ចីប្រាក់អ្នកចងការ ប្រមាណ ២៥០០០ ដុល្លារ ។ លោក B ពុំបានធ្វើបណ្តាំព្រោះ គ្មានកូន គ្មានប្រពន្ធ ប៉ុន្តែមានបងប្អូន ៣ នាក់ ។ ក្រោយពី លោក B ស្លាប់ ទៅធុរៈកិច្ច និងបំណុលរបស់លោកពុំមានអ្នកគ្រប់គ្រងទទួលបន្តនោះទេ ។ ដូច្នេះសន្តតិជន ដែលជាបុព្វញាតិ និងម្ចាស់បំណុលអាចដាក់ពាក្យសុំឱ្យតុលាការ ចាត់តាំងអ្នកគ្រប់គ្រងមត៌ករបស់លោក B ជា បណ្តោះអាសន្ន មុននឹងធ្វើការបែងចែកមត៌កតាមច្បាប់ ។

### ១.២. ការបែងចែកសន្តតិកម្មតាមច្បាប់

ក្រមរដ្ឋប្បវេណីបានបញ្ញត្តិនូវវិធានក្នុងការគណនាចំនួននៃចំណែកមត៌ក ដែលសន្តតិជនគ្រប់រូបមាន សិទ្ធិទទួលបាន ដូច្នេះប្រសិនជាមត៌កនោះ គឺមានតែសាច់ប្រាក់ការបែងចែកទ្រព្យសម្បត្តិឱ្យមានភាពស្មើគ្នា គឺ មានភាពងាយស្រួល ។ ប៉ុន្តែជាទូទៅ មត៌ករួមមានទ្រព្យសម្បត្តិផ្សេងៗ ដូចជា ចលនវត្ថុ អចលនវត្ថុ និងសិទ្ធិ លើបំណុល ។ នៅពេលចាប់ផ្តើមសន្តតិកម្ម សន្តតិជនមិនត្រឹមតែត្រូវកំណត់ចំនួនចំណែកមត៌កដែលនឹងត្រូវ បែងចែកសម្រាប់សន្តតិជនម្នាក់ៗប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវកំណត់ថា សន្តតិជនរូបណានឹងត្រូវទទួលមត៌កណា មួយផងដែរ ។ ការបែងចែកមត៌ក ជាទូទៅត្រូវធ្វើតាមរយៈការព្រមព្រៀងរវាងសហសន្តតិជន និងធ្វើតាមផ្លូវ តុលាការ[34]។

[34] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ ៣ រៀបរៀងដោយក្រុមការងារនៃគ្រូបណ្តុះបណ្តាល នៅសាលាភូមិន្ទនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការទំព័រទី ៧២

### ១.២.១. ការបែងចែកសន្តតិកម្មតាមការព្រមព្រៀង

អនុលោមតាមក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានបញ្ញត្តិថា ៖ ការបែងចែកចំណែកមត៌ក ត្រូវធ្វើឡើងតាមការពិភាក្សា និងការព្រមព្រៀងគ្នារវាងសន្តតិជនទាំងអស់នាពេលណាក៏បានក្រោយពីផុតរយៈពេល ១ (មួយ) ខែគិតចាប់ពីពេលបើកសន្តតិកម្ម[35] ។ ក្នុងអំឡុងពេល ១ (មួយ) ខែ សហសន្តតិជនមិនអាចធ្វើការបែងចែកនោះទេ ដោយសារតែ ត្រូវចាំបាច់គោរពវិញ្ញាណក្ខ័ន្ធរបស់មតកជន និងត្រូវស្វែងរកសន្តតិជនដែលនៅសល់ ( កូននៅក្រៅចំណងអាពាហ៍ពិពាហ៍ ឬ ករណីមានកូនដែលមកពីចំណងអាពាហ៍ពិពាហ៍មុន ) ដើម្បីមកទទួលមត៌កតាមចំណែករបស់ខ្លួនបានទទួល ។ ទោះបីជាក្នុងករណីសហសន្តតិជនមានការព្រមព្រៀងគ្នាពិតមែន ប៉ុន្តែការផ្ទេរសិទ្ធិរបស់មតកជនទៅឱ្យសន្តតិជនពុំមានប្រសិទ្ធិភាពឡើង លុះត្រាតែផុតអំឡុងពេល ៣ (បី) ខែនៃការយល់ព្រម ឬបោះបង់សន្តតិកម្ម[36]។

ក្នុងករណីដែលសហព័ទ្ធជាសន្តតិជន បើទ្រព្យសម្បត្តិដែលទទួលបានជាកម្មសិទ្ធិអវិភាគជាមួយមតកជន ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ក្នុងការបែងចែកមត៌ក សហព័ទ្ធមានអាទិភាពជាងសហសន្តតិជនផ្សេងទៀត ក្នុងការទទួលយកចំណែកកម្មសិទ្ធិអវិភាគដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិនោះ រហូតដល់គ្រប់ចំនួននៃចំណែកមត៌កនោះ[37]។ ដោយហេតុថា ជាទូទៅទ្រព្យសម្បត្តិរបស់ ប្ដីនិងប្រពន្ធ គឺជាទ្រព្យសម្បត្តិរួម( អាពាហ៍ពិពាហ៍ស្របច្បាប់) ដូច្នេះប្រសិនបើ ប្ដី ឬ ប្រពន្ធណាម្នាក់ទទួលមរណភាព ពាក់កណ្ដាលនៃទ្រព្យនោះជារបស់សហព័ទ្ធដែលនៅរស់ ហើយទ្រព្យសម្បត្តិពាក់កណ្ដាលទៀតជាកម្មវត្ថុនៃមត៌ក។ ហេតុនេះសហព័ទ្ធមានអាទិភាពជាសន្តតិជនផ្សេងទៀត ក្នុងការទទួលចំណែកកម្មសិទ្ធិអវិភាគរបស់មតកជន ចំពោះទ្រព្យសម្បត្តិរួម រហូតដល់បានទទួលគ្រប់ចំនួននូវចំណែកមត៌របស់ខ្លួន។ ក្នុងការបែងចែក ត្រូវពិចារណាទៅលើប្រភេទ និងលក្ខណៈនៃវត្ថុ ឬសិទ្ធិដែលមាននៅក្នុងមត៌ក ឬ អាយុ មុខរបរ ស្ថានភាពផ្លូវកាយ ឬ ស្ថានភាពជីវភាពរបស់សហសន្តតិជននីមួយៗ[38] ។ ពេលដែលពិភាក្សា សន្តតិជនទាំងអស់ត្រូវគោរពតាមសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អ ទើបការព្រមព្រៀងរបស់សន្តតិជនទាំងអស់មានអានុភាពកើតឡើងទៅលើការបែងចែកនេះ ។ ករណីដែលការបែងចែកបណ្ដាលឱ្យមានការខូចខាតធ្ងន់ធ្ងរ ដល់តម្លៃ បើយល់ឃើញថាសមរម្យ សហសន្តតិជនអាចឱ្យសន្តតិជនណាម្នាក់ ធ្វើលទ្ធកម្មទ្រព្យសម្បត្តិនោះបាន ដោយលក្ខខណ្ឌឱ្យបង់ប្រាក់សម្រួល

[35] មាត្រា ១២៦៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
[36] មាត្រា ១២៦៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
[37] មាត្រា ១២៦៨ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
[38] មាត្រា ១២៦៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ចំពោះសហសន្តតិជនផ្សេងទៀត តាមការពិភាក្សា[39] ។ មានន័យថា ក្នុងការបែងចែកវត្ថុជាកម្មសិទ្ធិអវិភាគ ដំណោះស្រាយអាចបង់ប្រាក់សម្រួលទៅឱ្យសន្តតិជនដទៃទៀត ដើម្បីឱ្យជនណាម្នាក់ទទួលមត៌កតែឯង ។

**ឧទាហរណ៍ ៖** មតកជន A មានដី ១កន្លែង តម្លៃ ៣០០០ ដុល្លារ ។ មតកជន A មានកូនបីនាក់គឺ C Dនិង E ។

ផ្អែកលើអង្គហេតុខាងលើ កម្មវត្ថុនៃមត៌ក គឺដី១ កន្លែងជា កម្មសិទ្ធិអវិភាគរបស់សន្តតិជនទាំងបី C D E ។ សន្តតិជនទាំងបី អាចព្រមព្រៀងគ្នា ដោយឱ្យសន្តតិជនណាម្នាក់ជាម្ចាស់កម្មសិទ្ធិលើវត្ថុនោះតែម្នាក់ឯង ប៉ុន្តែត្រូវផ្តល់ប្រាក់សម្រួលទៅឱ្យសន្តតិជនផ្សេងទៀត ។

ដូច្នេះ ទោះបីជាការពិភាក្សាធ្វើឡើងដោយផ្ទាល់មាត់ក៏ពិតមែន ក៏ត្រូវធ្វើលិខិតយថាភូត ដើម្បីវាយតម្លៃថាការពិភាក្សាបែងចែកមត៌កបានធ្វើឡើងរវាងសហសន្តតិជនពិតប្រាដកមែន ។

ជាការពិតណាស់ សន្តតិជនមិនត្រឹមតែទទួលបន្តនូវទ្រព្យសម្បត្តិពីមតកជនប៉ុណ្ណោះទេ គឺរួមទាំងទទួលបន្តពីករណីយកិច្ច ក៏ដូចជាបំណុលផងដែរ ។ វិធីនៃការបែងចែកមត៌កក្នុងករណីដែលសន្តតិជនមានកាតព្វកិច្ច គឺយកគោលការណ៍ជម្រះបញ្ជី ពោលមានន័យថា សន្តតិជនទទួលមត៌កដែលនៅសល់ពីការជម្រះបញ្ជីនៃកាតព្វកិច្ចនោះ រួចទើបធ្វើការបែងចែកទ្រព្យសកម្មដែលនៅសល់នោះ ឬករណីមួយទៀតគឺធ្វើការបែងចែកទាំងទ្រព្យសកម្ម ឬ អកម្មរបស់មតកជន ទៅឱ្យសន្តតិជនម្នាក់ៗដោយខ្លួនឯង ។ ប៉ុន្តែ ការទទួលកាតព្វកិច្ចពាក់ព័ន្ធនឹងអាជីវកម្ម ជំនួសឱ្យការបន្តអាជីវកម្ម នោះទាល់តែមានការយល់ព្រមពីម្ចាស់បំណុលផងដែរ ថាម្ចាស់បំណុល ជឿជាក់ ទុកចិត្ត ឱ្យសន្តតិជននោះទទួលបន្ទុកអាជីវកម្មនោះ ពិតជាមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបន្ត ឬទេ ឬមូលហេតុដទៃទៀត[40]។

### ១.២.២. ការបែងចែកសន្តតិកម្មតាមផ្លូវតុលាការ

ក្នុងករណីសហសន្តតិជនមិនបានព្រមព្រៀង ឬពុំអាចពិភាក្សាគ្នា ពីការបែងចែកមត៌កបានទេ សហសន្តតិជនណាម្នាក់ អាចដាក់ពាក្យសុំទៅតុលាការឱ្យធ្វើការបែងចែកមត៌កនោះបាន[41] ។ តុលាការធ្វើការបែងចែកមត៌កដោយឆន្ទានុសិទ្ធិ ក្នុងការលក់មត៌កនោះតាមវិធីលក់ឡាយឡុង ហើយធ្វើការបែងចែកទៅឱ្យសហសន្តតិជនតាមចំណែកដែលខ្លួនទទួល ។ ឯករណីមួយទៀត គឺសន្តតិជនណាមួយចង់ធ្វើជាម្ចាស់នៃអចលនវត្ថុដែលជាកម្មវត្ថុនៃមត៌កតែម្នាក់ឯង សន្តតិជននោះមានលទ្ធភាពដើម្បីបង់ប្រាក់សម្រួលទៅឱ្យសន្តតិជនផ្សេងទៀតបាន។

[39] មាត្រា ១២៦៧ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[40] មាត្រា ១២៦៩ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[41] មាត្រា ១២៧០ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

**ឧទាហរណ៍៖** មត៌កមានដីមួយឡូត៍ និងប្រាក់បញ្ញើក្នុងធនាគារ ក៏ប៉ុន្តែមាន ករណីដែលសន្តតិជនបានខ្វែងគំនិតគ្នាដោយទាមទារដីឡូត៍នេះ ឬ ខ្វែងគំនិតគ្នាអំពីវិធីបែងចែក ឬប្រសិនបើការបែងចែកទៅ តម្លៃនៃដីនោះធ្លាក់ជាដើម ។ ក្នុងករណីនេះ តុលាការសម្រេចឱ្យដីនោះទៅឱ្យសន្តតិជនណាម្នាក់ ហើយឱ្យជននោះបង់ប្រាក់សម្រួលទៅឱ្យសន្តតិជនផ្សេងទៀត ។

## ផ្នែកទី២ ៖ នីតិវិធីនៃការប្តឹងទាមទារមត៌ក

នៅពេលដែលសន្តតិជនទាំងអស់ពុំបានព្រមព្រៀងគ្នា ឬ ខ្វែងគំនិតគ្នាក្នុងការបែងចែកមត៌ក ។ សន្តតិជនអាចដាក់ពាក្យសុំឱ្យតុលាការបែងចែកមត៌កបាន ។ ការសុំឱ្យបែងចែកសន្តតិកម្ម ត្រូវបានកំណត់នៅក្នុងច្បាប់ស្តីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ហេតុនេះនីតិវិធីនៃការសុំឱ្យបែងចែកមត៌កត្រូវអនុលោមតាមច្បាប់នេះ។

ការសុំឱ្យបែងចែកមត៌កត្រូវធ្វើឡើង ដោយពាក្យសុំ ហើយតុលាការសម្រេចសេចក្តីក្រោមរូបភាពជាដីកាសម្រេច តាមមាត្រា៣ នៃកថាខណ្ឌទី២ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ។

### ២.១. របៀបនៃការដាក់ពាក្យសុំ

ការដាក់ពាក្យត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬ ធ្វើដោយផ្ទាល់មាត់[42]។ គូភាគីអាចដាក់ពាក្យសុំតាមរបៀបណាមួយក៏បាន ។ ការដាក់ពាក្យជាលាយលក្ខណ៍អក្សរ គូភាគីត្រូវអនុលោមតាមមាត្រា ២៦ កថាខណ្ឌទី២ នៃច្បាបស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ។ ចំពោះការដាក់ពាក្យដោយផ្ទាល់មាត់ អ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្តីថ្លែងការណ៍នូវចំណុចនីមួយៗដូចបានរៀបរាប់ខាងលើ ចំពោះមុខក្រឡាបញ្ជី ក្នុងចំណុចនេះក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុ ចុះហត្ថលេខា ហើយកំណត់ហេតុនេះត្រូវចាត់ទុកជា ពាក្យសុំ [43]។ អ្នកដាក់ពាក្យសុំឱ្យបែងចែកមត៌ក អាចពាក្យសុំនៅតុលាការសាលាដំបូងនៃកន្លែងចាប់ផ្តើមសន្តតិកម្ម ពោលគឺជាសមត្ថកិច្ចតុលាការនៅលំនៅដ្ឋានរបស់មតកជន[44] ។

#### ២.១.១. ចំណុចដែលត្រូវសរសេរក្នុងពាក្យសុំបែងចែកមត៌ក

ការដាក់ពាក្យសុំបែកចែកមត៌ក គឺតម្រូវឱ្យអ្នកដាក់ពាក្យសុំរៀបរាប់ឱ្យលំអិត ដោយអនុលោមតាមមាត្រា ២៦ កថាខណ្ឌទី២ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងចែងថា៖

[42] មាត្រា ២៦ កថាខណ្ឌទី១ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

[43] មាត្រា ២៦ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

[44] មាត្រា ៤ កថាខណ្ឌទី១ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

➤ ត្រូវសរសេរអំពីឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់[45] ។ ការសរសេរឈ្មោះ និងអាសយដ្ឋានរបស់ភាគីឱ្យបានច្បាស់លាស់ គឺជាការចាំបាច់សម្រាប់បញ្ជាក់អត្តសញ្ញាណរបស់ភាគី ព្រមទាំងសម្រាប់ធ្វើការបញ្ជូនពាក្យបណ្ដឹង និងឯកសារផ្សេងៗទៀតទៅចុងចម្លើយ ។ ជាទូទៅ ការសុំបែងចែកមត៌ក ដើមបណ្ដឹង គឺសំដៅទៅលើសន្តតិជនដែលដាក់ពាក្យសុំ ឯចុងចម្លើយគឺសំដៅទៅលើ សន្តតិជនដែលកាន់កាប់មត៌ករបស់មតកជន ។ ម្យ៉ាងទៀត ប្រសិនបើ ភាគីមានអ្នកតំណាងដែលច្បាប់បានកំណត់នោះ នៅក្នុងពាក្យសុំត្រូវសរសេរបញ្ជាក់អំពី ឈ្មោះ និង អាសយដ្ឋាន ងាយស្រួលដល់តុលាការ ក្នុងការបញ្ជូន និងផ្ញើពាក្យបណ្ដឹង និងឯកសារ ផ្សេងៗដូចជា ដីកាកោះ ឬលិខិតអញ្ជើញសម្រាប់អ្នកតំណាងដោយអាណត្តិរបស់ភាគីនៃវិវាទជាមេធាវី ។ ហេតុដូចនេះ ក៏ព្រោះតែក្នុងករណីខ្លះ ដែលភាគីម្ខាងជាអ្នកអសមត្ថភាក្នុងបណ្ដឹង ឬជានីតិបុគ្គល ដែលគប្បីគួរតែបញ្ជាក់ឱ្យបានច្បាស់លាស់អំពីអ្នកដែលធ្វើសកម្មភាពនៃបណ្ដឹងផ្ទាល់ ។

**ឧទាហរណ៍៖ លោក** A ជាដើមចោទ បានប្ដឹង **លោក** B ពាក់ព័ន្ធនឹងការកាន់កាប់មត៌របស់មតកជន ដោយពុំបានគោរពតាមបញ្ញត្តិច្បាប់ ។ ដូច្នេះ **លោក** A ត្រូវសរសេរពាក្យបណ្ដឹងដោយបញ្ជាក់ អំពីឈ្មោះ និង អាសយដ្ឋានខ្លួនឯង និង **លោក ខ** ឱ្យបានច្បាស់លាស់ ហើយប្រសិនបើ **លោក** A និង **លោក** B មានអ្នកដំណាងដែលច្បាប់បានកំណត់ ដូចនេះ នៅក្នុងពាក្យសុំត្រូវសរសេរបញ្ជាក់បន្ថែម អំពី ឈ្មោះ និងអាសយដ្ឋានអ្នកដំណាងឱ្យបានច្បាស់លាស់ ។ ដោយឡែក នៅក្នុងករណីពាក្យសុំ ដែលដើមចោទមិនបានសរសេរលម្អិតអំពីអាសយដ្ឋានរបស់ចុងចម្លើយ ប៉ុន្តែអាសយដ្ឋានដែលដើមចោទបានសរសេរមានចំណុចជាក់លាក់មួយ ដែលតុលាការអាចធ្វើការបញ្ជូនទៅចុងចម្លើយបានងាយស្រួលនោះ ដូចនេះពាក្យសុំនៅតែអាចទទួលយកបានដែរ ។

➤ ត្រូវសរសេរបញ្ជាក់ឱ្យបានច្បាស់អំពី ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ[46] ។ ជាការពិតណាស់ នៅក្នុងពាក្យបណ្ដឹង គឺត្រូវសរសេរបញ្ជាក់អំពីខ្លឹមសារនៃសាលក្រមដែលទាមទារឱ្យតុលាការចេញ និងត្រូវសរសេរបញ្ជាក់អំពីអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ ។ យ៉ាងណាមិញ ចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ គឺជាអត្ថន័យនៃសាលក្រមដើមចោទចង់ឱ្យតុលាការសម្រេចសេចក្ដីដូចអ្វីដែលមានសរសេរនៅក្នុងពាក្យបណ្ដឹងរបស់ខ្លួន ។ អនុលោមតាមចំណុចដែលជាមូលហេតុនៃការដាក់ពាក្យសុំ ខាងដើមចោទត្រូវសរសេរត្រង់នេះថា៖ ទី១ សុំឱ្យតុលាការបញ្ជាក់អត្ថិភាពជាសន្តតិជនលើមត៌ករបស់មតកជនឈ្មោះ ....... និងទី២ សុំឱ្យតុលាការបែងចែក

[45] មាត្រា ២៦ កថាខណ្ឌទី២ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង
[46] មាត្រា ៧៥ កថាខណ្ឌ៣ ចំណុចខ ក្រមនីតិវិធីរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៦

ចំណែក របស់មតកជននោះឈ្មោះ ....... តាមច្បាប់ រវាងដើមចោទ និងចុងចម្លើយ ។ គួរបញ្ជាក់ផងដែរថា បើចំណុចទី១ គ្មានវិវាទទេ មិនចាំបាច់ស្នើសុំទេ ។

➤ អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ៖ ចំណុចនេះ គឺជាមូលដ្ឋានគតិយុត្ត ដែលជាមូលដ្ឋាននៃការទាមទាររបស់ដើមចោទ ហើយក្នុងករណីបណ្ដឹងពាក់ព័ន្ធនឹងសន្តតិកម្ម ចំណុចនេះ ត្រូវរំលេចឱ្យឃើញថា ដើមចោទជាសន្តតិជនដែលមានអត្ថិភាពជាមួយគ្នានៅលើមត៌ករបស់មតកជននោះ ។

➤ ភស្តុតាង ៖ នេះជាការចង្អុលបញ្ជាក់ថា ការអះអាងរបស់ដើមចោទមិនមែន ចេះតែនិយាយចេញពីមាត់នោះទេ គឺមានការបញ្ជាក់ច្បាស់លាស់ដោយភស្តុតាង ជាឯកសារ សាក្សី រូបថត វីដេអូ ជាដើម ។ ការសរសេរបញ្ជាក់ភស្តុតាងក៏មិនសូវសំខាន់ដែលនៅក្នុងនីតិវិធីដាក់ពាក្យបណ្ដឹង ពីព្រោះនៅក្នុងនីតិវិធីទាញរកហេតុផល ក្រោយពេលកំណត់ចំណុចវិវាទរួចរាល់ តុលាការនឹងរៀបចំភស្តុតាងបំភ្លឺចំណុចវិវាទម្ដងទៀត ។ នៅក្នុងរឿងក្ដីសន្តតិកម្ម ភស្តុតាង ដែលគួរភ្ជាប់ជាមួយក្នុងពាក្យបណ្ដឹងរួមមាន ៖

- ឯកសារបញ្ជាក់អត្តសញ្ញាណសន្តតិជន និងមតកជន ៖ អត្តសញ្ញាណប័ណ្ណ សំបុត្រកំណើត សៀវភៅគ្រួសារ និងសៀវភៅស្នាក់នៅជាអាទិ៍ ។
- ឯកសារបញ្ជាក់អត្តសញ្ញាណទ្រព្យដែលជាកម្មវត្ថុនៃមត៌ក ៖ លិខិតបញ្ជាក់ទ្រព្យទាំងឡាយដែលជាកម្មសិទ្ធិរបស់មតកជន ។
- សំបុត្រមរណភាពរបស់មតកជន ៖ លិខិតដែលបញ្ជាក់អំពីមតកជនស្លាប់ ។
- ឯកសារបញ្ជាក់អំពីសិទ្ធិលើបំណុល ឬកាតព្វកិច្ចជាអាទិ៍ ៖ កិច្ចសន្យា ។

### ២.១.២. ភាគី និង អ្នកតំណាង

#### ក. ភាគី

ភាគីសំដៅទៅលើជនទាំងឡាយណាដែលមានវត្តមានក្នុងសាលក្រម ឬសាលដីកា ចេញដោយតុលាការ ។ ភាគី អាចជាបុគ្គលដែលបានដាក់ពាក្យប្ដឹង ហើយភាគីម្ខាងទៀតអាចជាអ្នកដែលត្រូវបានគេប្ដឹង មិនតែប៉ុណ្ណោះក៏អាចជាជនទាំងឡាយណាដែលពាក់ព័ន្ធលើបណ្ដឹង ក៏ដូចជាមានផលប្រយោជន៍ក្នុងបណ្ដឹងនេះ ដូចជា ម្ចាស់បំណុល អច្ច័យលាភី ។ល។ យ៉ាងណាក៏ដោយច្បាប់បានកំណត់សមត្ថភាពភាគី ត្រូវតែជាជនដែលមានសមត្ថភាពធ្វើសកម្មភាពពេញលេញ ពោលគឺជានីតិជន ឬ អនីតិជនដែលមានអត្តាធីនភាព ។ ដូច្នេះនៅក្នុងពាក្យសុំដីកាសម្រេចនៃការបែងចែកមត៌ក ត្រូវបញ្ជាក់អោយច្បាស់លាស់ ថានរណាជាដើមចោទ ហើយនរណាជាចុងចម្លើយ ដើម្បីងាយស្រួលយល់នៅក្នុងការបញ្ជូនឯកសារ ជៀសវាងមានការភាន់ច្រឡំនឹងអ្នកផ្សេង ប្រសិនបើភាគីជារូបវន្តបុគ្គលត្រូវត្រួតពិនិត្យមើលអំពីឈ្មោះ (នាម និងគោត្តនាម) អាយុ និងអាសយដ្ឋាន (លេខផ្ទះ លេខផ្លូវ ក្រុមមណ្ឌល ភូមិ ឃុំ/សង្កាត់ ស្រុក/ខណ្ឌ ខេត្ត/ក្រុង/រាជធានីភ្នំពេញ) បើជានីតិបុគ្គលនោះវិញ ត្រូវ

ត្រួតពិនិត្យ នាមករណ៍ ឈ្មោះ ទីតាំងស្នាក់នៅការចុះបញ្ជីនីតិបុគ្គលនោះរួមទាំងឈ្មោះ ឬនាមករណ៍ និង អាសយដ្ឋានរបស់រូបវន្តបុគ្គល ដែលជាអ្នកតំណាងស្របច្បាប់របស់នីតិបុគ្គលនោះ។ ចំពោះភាគីមួយ ដែលត្រូវបានចាត់ទុកថាភាគីនោះជានីតិបុគ្គល លុះត្រាតែបំពេញនូវលក្ខខណ្ឌនៃការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម។

នៅក្នុងការអនុវត្តជាក់ស្តែង ប្រសិនបើភាគីបញ្ជាក់បន្ថែមនូវអាសយដ្ឋានរបស់ខ្លួន តាមរយៈសារអេឡិចត្រូនិចសម្រាប់ទំនាក់ទំនងនោះ វាជាការប្រសើរណាស់ ប៉ុន្តែស្ថាប័ននៅប្រទេសកម្ពុជាបច្ចុប្បន្ន ការប្រាស្រ័យទាក់ទងតាមរយៈការផ្ញើសារអេឡិចត្រូនិចនៅមានកម្រិត ដូចនេះភាគីអាចបញ្ជាក់ត្រឹមលេខទូរស័ព្ទ ជាការគ្រប់គ្រាន់ហើយ។

ក្នុងសកម្មភាពដាក់ពាក្យសុំ ប្រសិនបើជនដែលដាក់ពាក្យសុំ ជាអនីតិជន និងជននៅក្រោមអាណាព្យាបាលទូទៅ ច្បាប់ពុំអនុញ្ញាតិឱ្យធ្វើសកម្មភាពបណ្តឹងនោះទេ ទាល់តែអនីតិជន និងជននៅក្រោមអាណាព្យាបាលទូទៅ ធ្វើសកម្មភាពបណ្តឹងឱ្យមានសុពលភាពបាន លុះត្រាតែត្រូវបានធ្វើដោយអ្នកតំណាងដែលច្បាប់បានកំណត់[47] ។

### ខ. អ្នកតំណាង

អ្នកតំណាងតាមផ្លូវបណ្តឹង សំដៅទៅលើអ្នកធ្វើសកម្មភាពបណ្តឹង ឬ ទទួលនូវសកម្មភាពបណ្តឹងរបស់តុលាការ ឬ ភាគីម្ខាងទៀតដោយផ្អែកតាមឆន្ទៈរបស់ខ្លួន ក្នុងនាមជាភាគី ហើយជំនួសភាគី សកម្មភាពនៃការធ្វើបណ្តឹង ឬ ទទួលនូវសកម្មភាពបណ្តឹងនោះនឹងមានទៅលើភាគី ។ ចំពោះអានុភាពនៃសកម្មភាពរបស់អ្នកតំណាង មានទៅលើសាមីខ្លួន ដោយសារតែអ្នកតំណាងនោះមានសិទ្ធិជាអ្នកតំណាង ។ អ្នកតំណាងតាមផ្លូវបណ្តឹង មានអ្នកតំណាងដែលច្បាប់បានកំណត់ និង អ្នកតំណាងដោយអាណត្តិ ។

អ្នកតំណាងដែលច្បាប់បានកំណត់ សំដៅទៅលើជនដែលទទួលបានសិទ្ធិស្របច្បាប់នៅក្នុងការធ្វើសកម្មភាពការពារផលប្រយោជន៍របស់ជនដែលត្រូវបានកម្រិតសមត្ថភាព ក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់ នៃសកម្មភាពរបស់ខ្លួន ដូចជាអនីតិជន ជនក្រោមអាណាព្យាបាលទូទៅ ជនក្រោមហិតូបត្ថម្ភ ។

អត្តសញ្ញាណរបស់អ្នកតំណាងដែលច្បាប់បានកំណត់ គឺសំខាន់ជាងអ្នកតំណាងដោយអាណត្តិដោយហេតុថា អ្នកតំណាងដែលច្បាប់បានកំណត់ គឺតំណាងឱ្យផលប្រយោជន៍របស់អសមត្ថជនដោយមិនអាចធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯងបាន ហើយអានុភាពនៃដីកាសម្រេច គឺមានទៅលើអ្នកតំណាងដែលច្បាប់បាន

[47] មាត្រា ១៧ កថាខណ្ឌទី២ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

កំណត់ មានន័យថានៅពេលដែលតុលាការចេញដីកាសម្រេចឱ្យអនុវត្ត អ្នកតំណាងដែលច្បាប់បានកំណត់ទទួលបន្ទុកអនុវត្តដីកាសម្រេចជំនួសអសមត្ថជន។

មួយវិញទៀត អ្នកតំណាងដោយអាណត្តិវិញ គឺធ្វើនៅក្នុងនាមជនដែលមានសមត្ថភាព ក្នុងការយល់ដឹង វិនិច្ឆ័យអំពីលទ្ធផលរបស់ខ្លួនទៅតាមផ្លូវច្បាប់បាន ហើយអាចធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯងបាន តែជននោះមិនចង់ចំណាយពេលធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯង ឬការយល់ដឹងអំពីច្បាប់នៅមានកម្រិត។ អានុភាពនៃដីកាសម្រេច មិនមានទៅលើអ្នកតំណាងដោយអាណត្តិនោះទេ គឺមានទៅលើតែភាគីជាដើមចោទ និងចុងចម្លើយប៉ុណ្ណោះ។ ដូចនេះ បើអ្នកដាក់ពាក្យសុំអះអាងថាខ្លួន គឺជាអ្នកតំណាងដែលច្បាប់បានកំណត់ ភស្តុតាងចំបងដែលចៅក្រមបានត្រួតពិនិត្យ គឺសេចក្តីសម្រេចរបស់តុលាការ ដែលទទួលស្គាល់ជននោះ ជាអ្នកតំណាងដែលច្បាប់បានកំណត់របស់អសមត្ថជន បើគ្មានទេ ចៅក្រមត្រូវបង្គាប់អោយកែតម្រូវ ក្នុងអំឡុងពេលសមរម្យ ។ ករណីផុតអំឡុងពេលកែតម្រូវហើយនៅតែមានកំហុសដដែលចៅក្រមត្រូវលើកពាក្យសុំនោះចោល។

ក្នុងករណីដែលគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ ឬករណីដែលអ្នកតំណាងដែលច្បាប់បានកំណត់ ពុំអាចប្រតិបត្តិនូវសិទ្ធិតំណាងនោះបុគ្គលដែលមានបំណងធ្វើសកម្មភាពបណ្តឹងចំពោះបុគ្គល ដែលគ្មានសមត្ថភាពនៅក្នុងការធ្វើបណ្តឹង អាចដាក់ពាក្យសុំទៅតុលាការ ដែលបានទទួលបណ្តឹងអោយជ្រើសរើសអ្នកតំណាងពិសេស ដោយធ្វើសេចក្តីបញ្ជាក់ដំបូងថា ការខូចខាតអាចនឹងកើតឡើងដោយសារការយឺតយ៉ាវនោះ។ អ្នកតំណាងពិសេសត្រូវមានការប្រគល់សិទ្ធិដូច អាណាព្យាបាល ដើម្បីធ្វើសកម្មភាពបណ្តឹង។[48] ប្រសិនបើអ្នកដាក់ពាក្យសុំ គឺជាអនីតិជន ដែលគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ តុលាការអាចចាត់តាំងតំណាងអយ្យការមួយរូបអោយធ្វើអ្នកតំណាងពិសេសបាន ពីព្រោះក្នុងករណីដែលយល់ឃើញថាចាំបាច់ ដើម្បីការពារផលប្រយោជន៍សាធារណៈ តុលាការត្រូវជូនដំណឹងដល់តំណាងអយ្យការថា ពាក្យបណ្តឹងត្រូវបានទទួល។ ទោះបីជាគ្មានការជូនដំណឹងក៏ដោយ ក៏តំណាងអយ្យការអាចចូលរួមក្នុងនីតិវិធីនៃបណ្តឹងរដ្ឋប្បវេណី និងបញ្ចេញយោបល់បានដែរ ប្រសិនបើខ្លួនយល់ឃើញថា ការចូលរួមនោះជាការចាំបាច់ដើម្បីការពារផលប្រយោជន៍សាធារណៈ។

[48] មាត្រា៣៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៦

## ២.២. សមត្ថកិច្ចសាលាជម្រះក្តី

### ២.២.១. តុលាការដែលមានសមត្ថកិច្ចចំពោះការបែងចែកមត៌ក

តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី ឬសាលាដំបូងដែលមានសមត្ថកិច្ចលើរឿងក្តីបែងចែកមត៌ក គឺជាតុលាការនៃលំនៅឋានរបស់មតកជន ឬជាកន្លែងចាប់ផ្តើមសន្តតិកម្ម ហើយជាកន្លែងដែលចាប់ផ្តើមធ្វើការបែងចែកមត៌កទៅឱ្យសន្តតិជន សមត្ថកិច្ចនេះ គឺជាសមត្ថកិច្ចផ្តាច់មុខ[49] ។ នៅក្នុងពាក្យសុំឱ្យបែងចែកមត៌កត្រូវបញ្ជាក់អំពីអត្តសញ្ញាណនៃវត្ថុដែលជាកម្មវត្ថុនៃមត៌ក និងត្រូវបញ្ជាក់ពីទីកន្លែងដែលអចលនវត្ថុនោះស្ថិតនៅគឺងាយស្រួលដល់ក្រឡាបញ្ជី ពិនិត្យពីសមត្ថកិច្ចតុលាការជម្រះក្តី សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមលំនៅឋានរបស់មតកជន ឬ ជាកន្លែងចាប់ផ្តើមសន្តតិកម្ម ។ ក្នុងករណីដែលតុលាការមានសមត្ថកិច្ចមិនអាចអនុវត្តសិទ្ធិសម្រេចសេចក្តីបាន ដោយសារច្បាប់ ឬហេតុការណ៍ពិត ឬ ករណីដែលសមត្ថកិច្ចសាលាជម្រះក្តីមិនអាចកំណត់បាន ដោយសារដែនសមត្ថកិច្ចនៃតុលាការមិនពិតប្រាកដ តុលាការកំពូលត្រូវកំណត់តុលាការដែលមានសមត្ថកិច្ចដោយដីការសម្រេចតាមពាក្យសុំ[50] ។

### ២.២.២. ពន្ធដាក់ពាក្យសុំ

នៅពេលដាក់ពាក្យសុំឱ្យបែងចែកសន្តតិកម្ម សាមីខ្លួនដែលដាក់ពាក្យសុំត្រូវតម្រូវឱ្យបង់ពន្ធដាក់ពាក្យសុំចំនួន ៥.០០០ រៀល ហើយក្រឡាបញ្ជីដែលទទួលពាក្យសុំ ត្រូវចេញបង្កាន់ដៃពន្ធមួយដល់អ្នកដាក់ពាក្យសុំ ។ ក្នុងករណីដែលពុំទាន់បានបង់ពន្ធនោះទេ តុលាការត្រូវកំណត់អំឡុងពេលសមរម្យ និងបង្គាប់ឱ្យបង់ពន្ធនោះ ហើយប្រសិនបើអ្នកដាក់ពាក្យសុំនៅតែមិនបង់ពន្ធ តុលាការត្រូវលើកលិខិតពាក្យសុំចោល ដោយដីកាសម្រេច[51] ។

### ២.២.៣. ការទទួល និងពិនិត្យពាក្យសុំ

បុគ្គលដែលមានភារៈទទួលពាក្យបណ្តឹងគឺ ក្រឡាបញ្ជី ក៏ប៉ុន្តែពេលដែលមានការដាក់ពាក្យសុំនៅតុលាការ ជាក់ស្តែងការអនុវត្តប្រចាំថ្ងៃនៅសាលាដំបូងរាជធានីភ្នំពេញ លេខាធិការដ្ឋានមានភារៈទទួលពាក្យបណ្តឹងអនុវត្តតាមជំហានដូចខាងក្រោម ៖

- ជាអ្នកវាយលើពាក្យសុំដែលបានទទួល និង ចុះកាលបរិច្ឆេទនៃការទទួល ។
- ចុះលេខរៀងនៅក្នុងសៀវភៅទទួលពាក្យសុំ និង លើពាក្យសុំ ។
- យកពាក្យសុំ និង ឯកសារដែលពាក់ព័ន្ធមកដាក់បញ្ចូលក្នុងសំណុំរឿង ។

[49] មាត្រា ៥៣៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[50] មាត្រា ៥ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង
[51] មាត្រា ២២ កថាខណ្ឌទី៦ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

➤ បញ្ជូនសំណុំរឿងក្តីនោះទៅឱ្យចៅក្រមដែលទទួលបន្ទុកទៅតាមដីកាសម្រេចប្រចាំឆ្នាំ ។

យ៉ាងណាមិញ នៅមុនពេលដែលទទួលពាក្យសុំមកធ្វើចំណាត់ការ អ្នកទទួលពាក្យបណ្តឹង (សំដៅទៅលើក្រឡាបញ្ជី ឬ មន្ត្រីលេខាធិការដ្ឋាន ) គួរពិនិត្យមើលពាក្យបណ្តឹងជាមុនសិន ហើយប្រសិនបើ មានការខ្វះខាត អ្នកទទួលពាក្យសុំ គួរគប្បីពន្យល់ណែនាំឱ្យអ្នកដាក់ពាក្យបណ្តឹងធ្វើការកែតម្រូវលើចំណុចខ្វះខាត ។ ជាពិសេស ពន្យល់ឱ្យអ្នកដាក់ពាក្យអំពីការសរសេរពាក្យសុំ ដោយយោងតាមមាត្រា ៧២៦ កថាខណ្ឌទី២ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង និង សមត្ថកិច្ចសាលាជំនុំជម្រះក្តីនៃតុលាការដែលទទួលពាក្យសុំ ដោយយោងតាមមាត្រា ៤ និង មាត្រា៥ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ។ បើសិនជា អ្នកដាក់ពាក្យប្តឹង មានអ្នកតំណាងដោយអាណត្តិ ត្រូវពិនិត្យថា មានលិខិតបញ្ជាក់ ឬលិខិតដែលប្រគល់សិទ្ធិតំណាងដោយអាណត្តិ ដែរ ឬទេ?

ទោះបីជាយ៉ាងណាក៏ដោយ អ្នកទទួលពាក្យបណ្តឹង គឺពុំមានសិទ្ធិក្នុងការលើកពាក្យបណ្តឹង ឬ មិនទទួលពាក្យបណ្តឹងដែលសរសេរមិនបានត្រឹមត្រូវនោះទេ ពោលគឺមានតែតុលាការ (សំដៅទៅលើចៅក្រម ឬ ក្រុមប្រឹក្សាជំនុំជម្រះ ដែលទទួលបន្ទុករឿងក្តីនោះ ) ប៉ុណ្ណោះ ដែលមានសិទ្ធិលើកពាក្យបណ្តឹងនោះចោលបានដោយដីកាសម្រេច [52]។ ដូច្នេះអ្នកទទួលពាក្យបណ្តឹង គ្រាន់តែពន្យល់ឱ្យអ្នកដាក់ពាក្យបណ្តឹងកែតម្រូវតែប៉ុណ្ណោះ ហើយសិទ្ធិសម្រេចការកែប្រែ ឬ មិនកែ គឺជាសិទ្ធិរបស់អ្នកដាក់ពាក្យបណ្តឹង ។

យ៉ាងណាមិញ អ្នកដាក់ពាក្យបណ្តឹង ត្រូវភ្ជាប់ជាមួយពាក្យបណ្តឹងនូវលិខិតចម្លងនៃឯកសារភស្តុតាងសំខាន់ៗ ដើម្បីបង្ការកុំឱ្យមានកំហុសនៅក្នុងការសរសេរអំពីអង្គហេតុជាក់លាក់ និងងាយស្រួលដល់តុលាការ ពិនិត្យ និងធ្វើការរៀបចំ ឬកំណត់នូវចំណុចវិវាទឱ្យបានឆាប់រហ័ស និងចំណេញពេលវេលា ។ ឧទាហរណ៍ ៖ វិវាទទាក់ទងទៅនឹងអត្ថិភាព និងនត្ថិភាព នៃមត៌ករបស់មតកជន ...... និងសុំឱ្យបែងចែកមត៌ករបស់មតកជនដែលជាទ្រព្យអវិភាគ ។ ដូចនេះ ដើមចោទគួរគប្បីមកជាមួយនូវឯកសារចម្លង សំបុត្រអត្រានុកូលដ្ឋាន ឬ អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន ឯកសារបញ្ជាក់អត្តសញ្ញាណទ្រព្យដែលជាកម្មវត្ថុនៃមត៌ក លិខិតបញ្ជាក់មរណភាពរបស់មតកជន និង ឯកសារពាក់ព័ន្ធនឹងសិទ្ធិលើបំណុល និងកាតព្វកិច្ច ។ ល។

ប្រសិនបើដើមចោទមានអ្នកតំណាងដោយអាណត្តិ គួរគប្បីភ្ជាប់ជាមួយកុំខាននូវឯកសារ បញ្ជាក់ពីសិទ្ធិអំណាចអ្នកតំណាង[53] ( អ្នកតំណាងដោយអាណត្តិជាមេធាវី)បន្ទាប់ពីភាគីបានដាក់ពាក្យសុំទៅកាន់តុលាការរួចហើយ ក្រឡាបញ្ជីត្រូវពិនិត្យទៅលើពាក្យសុំនោះ ដោយពិនិត្យពីរបៀបនៃការសរសេរពាក្យសុំ និង

[52] មាត្រា ៧៨ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៦

[53] មាត្រា ៥៣ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៦

ចំណុចដែលត្រូវសរសេរក្នុងពាក្យសុំ ដោយអនុលោមតាមមាត្រា២៦ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងហើយឬនៅ ។

### ២.២.៤. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង ការទាញហេតុផលដោយផ្ទាល់មាត់

នៅក្នុងនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង ពុំមាននីតិវិធិត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់នោះទេ ពីព្រោះនៅក្នុងនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹងមិនមានគោលបំណងចំពោះវិវាទស្តីពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ និងកាតព្វកិច្ចដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ពោលគឺមិនមានគោលបំណងឱ្យគូភាគីនៃវិវាទត្រូវមកប្រឈមមុខដាក់គ្នាក្នុងសវនាការ ដើម្បីជាវិធី ឬ ជាដំណោះស្រាយដែលធ្វើឱ្យតុលាការអាចដឹង ឬជាវិធីដោះស្រាយវិវាទអំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត របស់ភាគីទាំងសងខាងនោះទេ ។

នៅក្នុងច្បាប់ស្តីអំពីនីតិវិធីរដ្ឋប្បវេណីមិនមែនជាបណ្តឹង មានបញ្ញត្តិអំពីការផ្តល់សិទ្ធិអំណាចនៅក្នុងការធ្វើការចាត់ចែងចាំបាច់អំពីជីវភាពរវាងបុគ្គលឯកជនដែលគួរឱ្យរដ្ឋត្រូវធ្វើការអន្តរាគមន៍ ដោយសាររដ្ឋមានលក្ខណៈដូចជាអាណាព្យាបាល ឬមានការចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ។ ហេតុនេះ តុលាការសម្រេចសេចក្តីដោយយោងតាមនីតិវិធីដែលបានរៀបរាប់នៅក្នុងច្បាប់នេះ ។ តុលាការអាចកំណត់ ឬមិនកំណត់អំពីកាលបរិច្ឆេទនៃការទាញរកហេតុផលដោយផ្ទាល់មាត់ដោយឆន្ទានុសិទ្ធិ[54]។ តុលាការអាចសួរអ្នកដាក់ពាក្យសុំ ឬភាគីម្ខាងទៀត ឬជនផ្សេងទៀតដែលតុលាការយល់ឃើញថាចាំបាច់ ហើយតុលាការអាចអនុញ្ញាតិឱ្យអ្នកដែលតុលាការយល់ឃើញថាសមរម្យ ចូលស្តាប់ជាអ្នកសង្កេតការណ៍បាន ។

### ២.២.៥. ការចេញដីកាសម្រេច

បន្ទាប់ពីពាក្យសុំត្រូវបានដាក់ តុលាការចាត់នីតិវិធីជាបន្តបន្ទាប់រហូតដល់ចេញសេចក្តីសម្រេចបញ្ចប់តាមរយៈសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ[55] ។ ការសរសេរសំអាងហេតុនេះ គឺដើម្បីធានាភាពមិនលំអៀងក្នុងការវិនិច្ឆ័យរបស់ចៅក្រម ព្រមទាំងដើម្បីបង្ហាញឱ្យបានច្បាស់លាស់នូវមូលហេតុនៃកាវិនិច្ឆ័យនេះចំពោះភាគី ដើម្បីឱ្យភាគីមានភាពងាយស្រួលក្នុងការប្តឹងជំទាស់ ។

ជាងនេះទៅទៀតតុលាការអាចយកអង្គហេតុដែលមិនបានអះអាងដោយអ្នកដាក់ពាក្យសុំ ឬដោយភាគីម្ខាងទៀតមកធ្វើជាមូលដ្ឋាននៃការសម្រេចបាន ឬ ក្នុងករណីចាំបាច់តុលាការធ្វើការស្រាវជ្រាវអង្គហាតុ និងធ្វើ

[54] មាត្រា ២៨ កថាខណ្ឌទី១ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង
[55] មាត្រា ៣៥ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

ការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ[56] ។ គូភាគីអាចធ្វើការប្ដឹងជំទាស់បានក្នុងអំឡុងពេល ២ (ពីរ) សប្ដាហ៍ ដោយគិតចាប់ពីថ្ងៃបានទទួលការជូនដំណឹងអំពីដីកាសម្រេច[57] ។

[56] មាត្រា ២៧ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង

[57] មាត្រា ៤0 កថាខណ្ឌទី១ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ បានបញ្ញត្តិយ៉ាងលម្អិតអំពីសន្តតិកម្ម។ ដោយច្បាប់បានធ្វើការបែងចែកសន្តតិកម្មជាពីរ គឺមានសន្តតិកមម្មតាមច្បាប់ និងសន្តតិកម្មតាមមតកសាសន៍ ។ ដោយឡែកប្រធានបទដែលយើងខ្ញុំលើកយកមកបកស្រាយ និងធ្វើការអធិប្បាយយ៉ាងលម្អិតស្ដីពីសន្តតិកម្មតាមច្បាប់ ឬ ការស្នងមត៌កតាមច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ការស្នងមត៌កតាមច្បាប់ គឺជាការផ្ទេរនូវទ្រព្យរបស់មតកជន រួមទាំងសិទ្ធិ និងករណីយកិច្ច ទៅឱ្យមនុស្សម្នាក់ ឬច្រើននាក់។ ការស្នងមត៌កតាមច្បាប់អាចប្រព្រឹត្តទៅបាន នៅពេលដែលមតកជនពុំបានបន្សល់ទុកនូវមតកសាសន៍ (បណ្តាំ) ឬការផ្តែផ្តាំទៅឱ្យកូនចៅ នោះច្បាប់ចូលខ្លួនមកដោះស្រាយពីការបែងចែកទ្រព្យសម្បត្តិទាំងអស់នេះ ទៅតាមលំដាប់នៃសន្តតិជន។ ប៉ុន្តែមុននឹងឈានដល់ការក្លាយជាសន្តតិជនបានលុះត្រាតែបានបំពេញនូវលក្ខខណ្ឌមួយចំនួនដូចជា ជាបុគ្គលដែលមានជីវិតរស់នៅ មិនមែនជាអភ័ព្វបុគ្គល ឬ មិនមែនជាជនដែលត្រូវបានផ្តាច់ចេញពីមត៌ក។

ម្យ៉ាងវិញទៀត សន្តតិជនត្រូវស្ថិតនៅក្នុងទំនាក់ទំនងញាតិ រួមមាន បច្ឆាញាតិផ្ទាល់ បុព្វញាតិផ្ទាល់ និងបងប្អូនបង្កើត ។ សន្តតិជនមានសិទ្ធិទទួលទ្រព្យដំបូងគេនោះ ជាកូនបង្កើតរបស់មតកជន(សន្តតិជនលំដាប់ទី១) នៅពេលមតកជនពុំមានកូនបង្កើតនោះ អ្នកស្នងមត៌កបន្ទាប់ជា ឪពុក ម្តាយ ឬ ជីដូន ជីតា របស់មតកជន (សន្តតិជនលំដាប់ទី២) ជាងនេះប្រសិនមតកជនពុំមានសន្តតិជនលំដាប់ទាំងពីរនោះទេ ទ្រព្យទាំងអស់ត្រូវធ្លាក់ទៅបងប្អូនបង្កើតរបស់មតកជន (សន្តតិជនលំដាប់ទី៣) ។ ចំណែកសហព័ទ្ធរបស់មតកជន មានសិទ្ធិឡើងស្នងគ្រប់លំដាប់សន្តតិជនទាំងអស់ ពីព្រោះច្បាប់ចាត់ទុកថា សហព័ទ្ធរបស់មតកជននោះជាសន្តតិជនជានិច្ច។ មួយវិញទៀត ក៏អាចមានករណីដែលមតកជនពុំមានសន្តតិជន ឬ រកមិនឃើញសន្តតិជនទេនោះ ទ្រព្យដែលនៅសល់ ត្រូវប្រគល់ឱ្យជនមាននិស្ស័យពិសេសជាមួយនឹងមតកជន ឬ ធ្លាក់ទៅជាទ្រព្យរដ្ឋ។ សន្តតិជនទាំងអស់មានសិទ្ធិព្រមទទួល ឬ បោះបង់សន្តតិកម្ម មិនថាសន្តតិកម្មនោះច្រើនជាង ឬ តិចជាងបំណុលក៏ដោយការសម្តែងឆន្ទៈទទួលយក ឬបោះបង់បាននៅក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលបានដឹងថាសន្តតិកម្មចាប់ផ្តើមចំពោះខ្លួន។

ការសម្រួលចំណែកមត៌ករវាងសហសន្តតិជនជាការសំខាន់សម្រាប់យកមកពិចារណា ក្នុងគោលបំណងដើម្បីឱ្យសន្តតិជនទទួលបាននូវចំណែកស្មើៗគ្នា ដោយសារសន្តតិជន ឬសហសន្តតិជនណាម្នាក់បាន

ទទួលនូវផលប្រយោជន៍ពិសេសនៅក្នុងឱកាសពិសេសណាមួយ អាចជាអាពាហ៍ពិពាហ៍ ពិធីខួបកំណើត ។ល។ ហេតុនេះក្នុងករណីដែលសន្តតិជនទាំងអស់ពិភាក្សាគ្នា ពុំបានសម្រេចពីការបែងចែកទេនោះ សន្តតិជនណាម្នាក់អាចដាក់ពាក្យមកតុលាការដើម្បីឱ្យតុលាការធ្វើការបែងចែកមត៌ករបស់ខ្លួនដោយយុត្តិធម៌ និង ស្មើភាពគ្នា ។

សរុបមកវិញ ប្រធានបទនេះពិតជាមានសារៈសំខាន់សម្រាប់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ ពីព្រោះថាមតកជន មានឆន្ទៈក្នុងការប្រគល់ទ្រព្យរបស់ខ្លួនឲ្យសន្តតិជនណាម្នាក់ដែលខ្លួនស្រឡាញ់ពេញចិត្តច្រើនជាងគេ ដោយបង្ហាញឆន្ទៈតាមរយៈមតកសាសន៍ ហេតុនេះការសរសេរបណ្តាំបែបនេះវាមានភាពអយុត្តិធ៌មដល់សន្តតិជនផ្សេងទៀត ប៉ុន្តែការស្នងមត៌កតាមច្បាប់វិញ នៅពេលមតកជនមិនបានសរសេរបណ្តាំទុកនោះទេ ច្បាប់ចូលខ្លួនមកដោះស្រាយបញ្ហានៃការបែងចែកមត៌ករបស់មតកជនឱ្យមានសមភាព និង អព្យាក្រិត្យ ដល់សន្តតិជនទាំងអស់។

ជាចុងក្រោយយើងខ្ញុំសង្ឃឹមថា ការស្រាវជ្រាវប្រធានបទនេះ ដើម្បីទុកជាចំណេះដឹងដល់ សិស្សនិស្សិត មិត្តអ្នកអាន និង ប្រជាពលរដ្ឋខ្មែរទាំងអស់ឱ្យកាន់តែយល់ដឹងយ៉ាងស៊ីជម្រៅ និងកាត់បន្ថយវិវាទពីការបែងចែកមត៌កនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

# អនុសាសន៍

# អនុសាសន៍

ខ្លឹមសារនៃមាត្រាទាំង ១៣០៥ នៅក្នុងក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ ក៏ដូចជាច្បាប់ទាំងឡាយដែលស្ថាប័ននីតិបញ្ញត្តិ និងក្រសួងយុត្តិធម៌បានតាក់តែងឡើងពិតជាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីយកមកគ្រប់គ្រងនៅរាល់សកម្មភាពរបស់បុគ្គលឯកជន ដូចជា ទំនាក់ទំនងនៃការជួញដូររវាងបុគ្គលឯកជន កម្មសិទ្ធិ កិច្ចសន្យា អាពាហ៍ពិពាហ៍ និងសន្តតិកម្ម ។ ជាក់ស្តែង ក្រោយពីយើងខ្ញុំបានសិក្សាស្រាវជ្រាវប្រធានបទ ការស្នងមត៌កតាមច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា រួចមក យើងខ្ញុំអាចសន្និដ្ឋានបានថា ច្បាប់បានបញ្ញត្តិពីការស្នងមត៌កតាមច្បាប់ដើម្បីឱ្យជនទាំងអស់យកមកអនុវត្តតាម ក៏ប៉ុន្តែក្នុងស្ថានភាពជាក់ស្តែងការបែងចែកមត៌កតាមច្បាប់ពិតជាមានលក្ខណៈថ្មីស្រឡាងសម្រាប់ប្រជាពលរដ្ឋកម្ពុជា ក៏ព្រោះថាការយល់ដឹងផ្នែកច្បាប់របស់ប្រជាពលរដ្ឋនៅមានកម្រិតនៅឡើយ ។ នៅតាមតំបន់ដាច់ស្រយាល ឬ ទីជនបទខ្លះ ប្រជាពលរដ្ឋដែលពុំមានជីវភាពធូរធារក្នុងការទំនុកបំរុងកូន ហេតុនេះគាត់ពុំមានលទ្ធភាពក្នុងការសិក្សា យល់ដឹងអំពីផ្នែកច្បាប់នេះទេ ។ ដូច្នេះយើងខ្ញុំមានមតិយោបល់ខ្លះ សំណូមពរដូចខាងក្រោម ៖

- សូមឱ្យមានការផ្សព្វផ្សាយផ្នែកច្បាប់ទាក់ទងការស្នងមត៌កតាមច្បាប់ ជាសាធារណៈឱ្យកាន់តែមានភាពច្បាស់លាស់ និងមួយវិញទៀត មន្ត្រីថ្នាក់ក្រោមជាតិ ជួយផ្សព្វផ្សាយទៅតាមតំបន់ដាច់ស្រយាល ឬ ខេត្តនីមួយៗឱ្យបានច្រើនឡើង ដើម្បីទុកជាចំណេះដឹងដល់ប្រជាពលរដ្ឋក៏ដូចជាកុំឱ្យមានភាពអយុត្តិធ៌ម ការស្រែកទ្រហោយំរបស់រាស្ត្រដែលមិនសុខចិត្តឱ្យជនផ្សេងយកទ្រព្យរបស់ខ្លួន ។
- កំណត់អំឡុងពេលនៃការដាក់ពាក្យសុំឱ្យបែងចែកមត៌ក ដោយហេតុថានៅពេលតុលាការមានភាពយឺតយ៉ាវក្នុងការជម្រះក្តី គឺធ្វើឱ្យខូចខាតតម្លៃ ឬ ខាតបង់នៅកម្មវត្ថុនៃការទាមទារ និងបាត់បង់ការជឿទុកចិត្តលើតុលាការ។
- ពង្រឹងសមត្ថភាពមន្ត្រីអាត្រានុកូដ្ឋាន ដោយមានការយកចិត្តទុកដាក់ និងពិនិត្យឱ្យលម្អិតទៅលើលិខិតផ្សេងៗដែលចេញដោយមន្ត្រីអាត្រានុកូនដ្ឋាន ដើម្បីបង្ការនូវភាពខុសឆ្គង ការភ័ន្តច្រឡំ និងកំហុសផ្សេងៗដោយយថាហេតុ ពីព្រោះសំបុត្រដែលចេញដោយមន្ត្រីអាត្រានុកូលដ្ឋាន គឺជាចំណងចង់ភ្ជាប់សញ្ជាតិទៅនឹងរដ្ឋ និង ស្ថានភាពជាក់ស្តែង ដែលជននៅក្នុងត្រកូលគ្រួសារខ្លួន ហើយជាផ្នែកមួយនៃសង្គមជាតិដែលបង្កើតឱ្យមានសិទ្ធិ និងករណីយកិច្ចចំពោះបុគ្គលម្នាក់ៗ ។ ប្រសិនបើក្នុងករណីមាន

ជនណាម្នាក់ក្លែងបន្លំសំបុត្រកំណើត ក្នុងគោលបំណងចង់ក្លាយខ្លួនជាទាយាទណានៅក្នុងត្រកូលគ្រួសារមានទ្រព្យស្តុកស្តម្ភនោះ វាធ្វើឱ្យប្រព័ន្ធច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជាមានការចុះខ្សោយដោយហេតុកើតចេញអំពើពុករលួយរបស់មនុស្សមួយក្រុម ។

➢ មួយវិញទៀត គឺទាក់ទងការចុះប័ណ្ណកម្មសិទ្ធិ ការចេញវិញ្ញាប័ណ្ណប័ត្រសំគាល់អចលនវត្ថុឱ្យមានភាពច្បាស់លាស់ ក៏ដូចជាផ្តល់សិទ្ធិអាទិភាពទៅឱ្យម្ចាស់កម្មសិទ្ធិករ កុំឱ្យមានការរំលោភបំពានដោយការក្លែងបំន្លំ បំពាន់ឯកសារច្បាប់ដើម ដើម្បីក្លាយខ្លួនជាម្ចាស់កម្មសិទ្ធិលើអចលនវត្ថុនោះ ។

ថ្វិត្បិតតែ អនុសាសន៍នេះមិនសូវគ្រប់គ្រាន់ និងល្អឥតខ្ចោះក៏ដោយ តែយើងខ្ញុំសង្ឃឹមថាវាជាកត្តាមួយជម្រុញដល់ការចូលរួមកាត់បន្ថយវិវាទទាំងឡាយដែលទាក់ទងនឹងការបែងចែកមត៌ក ហើយវាក៏ជាសំណូមពរពីយើងខ្ញុំក្នុងគោលបំណងចង់ឃើញនូវការអភិវឌ្ឍន៍លើវិស័យច្បាប់ឱ្យកាន់តែល្បីល្បាញ និងលេចធ្លូរលើឆាកអន្តរជាតិ ដើម្បីជាទុនឱ្យនិស្សិតបរទេសចាប់អារម្មណ៍មកសិក្សាស្វែងយល់ពីប្រទេសយើងឱ្យកាន់តែច្រើនឡើង។

# ឯកសារយោង

# ឯកសារយោង

## I. ច្បាប់ និង បទបញ្ញត្ត

- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៦
- ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

## II. សៀវភៅ

- សៀវភៅ នីតិបេតិកភណ្ឌគ្រួសារ អ្នកនិពន្ធ សាស្ត្រាចារ្យ ស្រី វណ្ណធី
- សៀវភៅ ការបែងចែកមត៌ក របស់មេធាវី អ៊ីវ ប៉ុលី នៅថ្ងៃទី១៥ ខែមករា ឆ្នាំ ២០១៨
- សៀវភៅ លក្ខខណ្ឌទូទៅនៃសន្តតិកម្ម និងសន្តតិកម្មតាមច្បាប់ និពន្ធដោយ សាស្ត្រាចារ្យ ជ័យ រិទ្ធី ដោយ បណ្ណាល័យច្បាប់

# ឧបសម្ព័ន្ធ

# លំហូរនៃនីតិវិធី

## លំហូរនៃនីតិវិធី

មតកជនទទួលមរណភាព

⇩

ការចាត់តាំងអ្នកចាត់ចែងគ្រប់គ្រង (មាត្រា១២៩១)

⇩

ការជូនដំណឹងជាសាធារណៈលើកទី១ (មាត្រា១២៩១-២)

⇩ យ៉ាងហោចណាស់ ២ខែ(មាត្រា ១២៩៦-១)

ការជូនដំណឹងជាសាធារណៈលើកទី២ ( មាត្រា១២៩៦-១)

⇩ យ៉ាងហោចណាស់ ២ខែ(មាត្រា ១២៩៦-១)

ការដកចេញពីការជម្រះ(១២៩៦-២ និង ១២៨៨)

⇩

ការចាប់ផ្តើមការជម្រះនៃមត៌ក ( មាត្រា១២៩៦-២ និង ១២៨៣ ដល់ ១២៨៦ )

⇩

ការជូនដំណឹងជាសាធារណៈលើកទី៣ ( មាត្រា១២៩៧)

⇩ យ៉ាងហោចណាស់ ៦ខែ(មាត្រា ១២៩៧-១)

ការរលត់នៃសិទ្ធិ (មាត្រា១២៩៨)

⇩ អំឡុងពេល ៣ខែ(មាត្រា ១២៩៩-២)

ពាក្យសុំនៃការចែកទ្រព្យទៅឲ្យជនដែលមាននិស្ស័យពិសេស(មាត្រា ១២៩៩-២)

ការជម្រះបញ្ជីត្រូវបញ្ចប់មុនពេល ធ្លាក់ទៅជាទ្រព្យរដ្ឋ

⇩

ការបែងចែកទ្រព្យទៅជនដែលមាននិស្ស័យពិសេស ( មាត្រា ១២៩៩-២ )

⇩

ទ្រព្យដែលនៅសល់ត្រូវធ្លាក់ទៅជាទ្រព្យរដ្ឋ (មាត្រា ១៣០០)

# គំរូដាក់ពាក្យសុំឱ្យបែងចែកមត៌ក

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គម្រូពាក្យសុំសម្រាប់ករណីសិក្សាទី១

**ពាក្យស្នើសុំឲ្យបែងចែកមត៌ក**

**អ្នកដាក់ពាក្យសុំ** ៖ ឈ្មោះ A អាយុ ៤០ ឆ្នាំ មុខរបរពាណិជ្ជករ ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ០២ ផ្លូវលេខ ១៧៩ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**អ្នកតំណាងដោយអាណត្តិ** « អ្នកដាក់ពាក់សុំ[58]» ៖ ខ្ញុំ P ជាមេធាវីនៃក្រុមហ៊ុនមេធាវី................................ ដែលមានអាសយដ្ឋានស្ថិតនៅ.............. មហាវិថី............ សង្កាត់......... ខណ្ឌ.......... រាជធានីភ្នំពេញ ដោយមានលេខទូរស័ព្ទ ................ ។

ទីកន្លែងបញ្ជូន ៖ ក្រុមហ៊ុនមេធាវី ...................[59]

**ភាគីម្ខាងទៀតនៃពាក្យសុំ** ៖ ឈ្មោះ B អាយុ ៤២ ឆ្នាំ មុខរបរពាណិជ្ជករ ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ៣៥ ផ្លូវលេខ៦៦ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

**សូមគោរពចូលមក**

**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**[60]

**ក-ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ**

១.អ្នកដាក់ពាក្យសុំធ្វើលទ្ធកម្មនូវអចលនវត្ថុដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ១ស្តីពីមត៌កដែលបានភ្ជាប់ជាមួយនេះ ។

---

[58] មានករណីមួយចំនួនដែលការពិភាក្សាលក្ខណៈសារធាតុរវាងសហសន្តតិជនបានធ្វើឡើងរួចរាល់ ប៉ុន្តែ ចំណុចនេះបង្ហាញតែអំពីឧទាហរណ៍ដែលមេធាវីបានដាក់ពាក្យសុំក្នុងនាមជាអ្នកតំណាងដោយអាណត្តិឲ្យសន្តតិជនតែម្នាក់គត់ក្នុងចំណោមសហសន្តតិជន ។ ប្រសិនបើមេធាវីបានដាក់ពាក្យសុំក្នុងនាមជាតំណាងឲ្យសន្តតិជនច្រើននាក់ក្នុងចំណោមសហសន្តតិជន ( រួមបញ្ចូលទាំងករណីដែលធ្វើការតំណាងឲ្យសន្តតិជនទាំងអស់ផងដែរ ) នឹងធ្វើឲ្យមានការព្រួយបារម្ភណ៍អំពីភាពផ្ទុយគ្នានៃផលប្រយោជន៍ ហេតុនេះមេធាវីចាំបាច់ត្រូវតែពន្យល់ឲ្យបានច្បាស់លាស់អំពីចំណុចនេះទៅកាន់អតិថិជន និងត្រូវទទួលការយល់ព្រមពីអតិថិជនផងដែរ ។ យ៉ាងណាមិញ គេគិតថា វិធីដែលសន្តតិជនណាម្នាក់ក្នុងចំណោមសហសន្និជនតំណាងឲ្យសហសន្តតិជនផ្សេងទៀត ហើយបានដាក់ពាក្យសុំ នឹងធ្វើឲ្យមានការព្រួយបារម្ភថាខ្វះការធានាចំពោះនីតិវិធីសម្រាប់សហសន្តតិជនផ្សេងទៀត ហើយពួកគេនឹងមិនពេញចិត្ត ។

[59] មាត្រា ២៤៩ និងមាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ ការដាក់ពីទីកន្លែងដែលត្រូវបញ្ជូន មិនមែនជាកាតព្វកិច្ចនោះទេ ។ ទោះបីជាមិបដាក់ពីកន្លែងដែលត្រូវបញ្ជូនក៏ដោយ ក៏ជាទូទៅគឺត្រូវធ្វើការបញ្ជូនទៅការិយាល័យមេធាវីនៃបណ្តឹង ។ ប៉ុន្តែ ដើម្បីឲ្យមានភាពច្បាស់ពីទីកន្លែងដែលត្រូវបញ្ជូន វាជាការល្អដែលដាក់ពីទីកន្លែងដែលត្រូវបញ្ជូន ។ ជាពិសេស ក្នុងករណីដែលមានមេធាវីណាមួយ នោះត្រូវដាក់ពីទីកន្លែងដែលត្រូវបញ្ជូន ។

[60] តុលាការដែលមានសមត្ថកិច្ច គឺជាតុលាការនៃទីកន្លែងចាប់ផ្តើមសន្តតិកម្ម ( តារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង) ។ ហើយទីកន្លែងចាប់ផ្តើមសន្តតិកម្ម គឺជាអាសយដ្ឋាននៅពេលមរណភាពរបស់មតកជន ( ក្រមរដ្ឋប្បវេណីមាត្រា១១៤៦) ។

២.ភាគីម្ខាងទៀត........ធ្វើលទ្ធកម្មនូវប្រាក់បញ្ញើដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ២ស្តីពីមត៌ក និងសាច់ប្រាក់ដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ៣ស្តីពីមត៌ក ដែលបានភ្ជាប់ជាមួយនេះ ។

**ខ.អង្គហេតុដែលជាមូលហេតុនៃការទាមទារ**

១.មតកជន........បានទទួលមរណភាពនៅថ្ងៃទី.....ខែ.....ឆ្នាំ......ហើយមត៌កដែលដឹងច្បាស់នាពេលបច្ចុប្បន្ន មានដូចទៅនឹងការសរសេរនៅក្នុងបញ្ជីសារពើភ័ណ្ឌស្តីពីមត៌កដែលបានភ្ជាប់ជាមួយនេះ ( តទៅនេះហៅថា"មត៌កនៃរឿងក្តីនេះ"។)។

២.នៅពេលទទួលមរណភាព មតកជន............មានប្រពន្ធ......ហើយរវាងមតកជន និងប្រពន្ធ....នោះ មានកូន.........១នាក់។ មតកជនមិនមានកូនផ្សេងទៀតទេ។ មតកជន......មិនបានបន្សល់ទុកមតកសាសន៍ឡើយ[61]។

៣.សន្តតិជនរបស់មតកជនដែលជាអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត បានពិភាក្សាគ្នាអំពីការបែងចែកមត៌កនៃរឿងក្តីនេះ។ ជាលទ្ធផលនៃការពិភាក្សា ភាគីម្ខាងទៀតមានផ្ទះដែលជាកម្មសិទ្ធិផ្ទាល់ខ្លួនរួចទៅហើយ ប៉ុន្តែ ដោយសារតែគាត់មានអាយុច្រើន និង មិនមានប្រាក់ចំណូល ដូច្នេះ គាត់ត្រូវការចាំបាច់នូវសាច់ប្រាក់និង ប្រាក់បញ្ញើក្នុងធនាគារ សម្រាប់ជីវភាពរបស់គាត់ក្នុងពេលខាងមុខ។ ចំណែកឯអ្នកដាក់ពាក្យសុំវិញ គឺជាបុគ្គលិកក្រុមហ៊ុនដែលមានប្រាក់ចំណូល ប៉ុន្តែ គាត់មិនទាន់មានផ្ទះដែលជាកម្មសិទ្ធិផ្ទាល់ខ្លួននៅឡើយទេ ដូច្នេះហើយអ្នកដាក់ពាក្យសុំ ត្រូវធ្វើលទ្ធកម្មនូវអចលនវត្ថុដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ១ស្តីពីមត៌កដែលបានភ្ជាប់ជាមួយនេះ ហើយភាគីម្ខាងទៀតត្រូវធ្វើលទ្ធកម្មសាច់ប្រាក់ និងប្រាក់បញ្ញើក្នុងធនាគារដែលបានសរសេរក្នុងបញ្ជីសារពើភណ្ឌ ២ និង ៣ ស្តីពីមត៌កដែលបានភ្ជាប់ជាមួយនេះ។ បន្ថែមពីនេះទៀត តម្លៃទីផ្សារនៃអចលនវត្ថុ ដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ១ ស្តីពីមត៌កដែលបានភ្ជាប់ជាមួយនេះ គឺប្រហែល.......ដុល្លារ ហើយ មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃនៃការបូកសរុបប្រាក់បញ្ញើនៅក្នុងធនាគារ និងសាច់ប្រាក់សុទ្ធដែលបានសរសេរក្នុងបញ្ជីសារពើភ័ណភ័ណ្ឌ ២ និង ៣ ស្តីពីមត៌កដែលបានភ្ជាប់ជាមួយនេះ។ ដូចនេះ នៅថ្ងៃទី......ខែ......ឆ្នាំ២០១៧ ភាគីទាំង២ បានបង្កើត[62]នូវការព្រមព្រៀងដូចមាននៅក្នុងការសរសេរនៃចំណុចទី១ ខ្លឹមសារនៃដីកាសម្រេចទាមទារឲ្យតុលាការចេញ។

---

[61] បើសិនជាមានមតកសាសន៍ ករណីនេះនឹងក្លាយជាសន្តតិកម្មអនុវត្តតាមមតកសាសន៍ ( សន្តតិកម្មតាមមតកសាសន៍ ) (ក្រមរដ្ឋប្បវេណី មាត្រា ១១៤៥ និង ចាប់ពីមាត្រា១១៦៨ ) ។

[62] ដើម្បីឲ្យតុលាការចេញដីកាសម្រេចទៅតាមខ្លឹមសារនៃដីកាសម្រេចដែលទាមទារឲ្យតុលាការចេញ តើរវាងសហសន្តតិជនបានបង្កើតនូវការព្រមព្រៀងពិតប្រាកដដែរឬទេ? ( តើសហសន្តតិជនទាំងអស់បានយល់ព្រមតាមការបែងចែកដូចនៅក្នុងខ្លឹមសារនៃដីកាសម្រេចដែលទាមទារឲ្យតុលាការចេញដែរឬទេ?) គឺជាចំណុចសំខាន់។ ដូច្នេះហើយ ត្រង់ចំណុចនេះ គួតែមានការពន្យល់អំពីមូលហេតុលម្អិត ថាតើហេតុអ្វីបានជាបែងចែកតាមនីតិវិធីបែបនេះ?

៤.អាធ្យាស្រ័យ  អ្នកដាក់ពាក្យសុំសូមឲ្យតុលាការចេញដីកាសម្រេចតាមការសរសេរនៅក្នុងចំណុចទី១ ខ្លឹមសារនៃដីកាសម្រេចដែលទាមទារឲ្យតុលាការចេញ ចំពោះពាក្យសុំនៃរឿងក្ដីនេះ។

**គ.ភស្តុតាងជាឯកសារ**[63]

១.សំបុត្រមរណភាពរបស់មតកជន

២.សំបុត្រកំណើតរបស់អ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត

៣.ច្បាប់ចម្លងនៃសៀវភៅគ្រួសារ

៤.ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ

៥.លិខិតបញ្ជាក់ប្រាក់ដែលនៅសល់នៅក្នុងគណនីប្រាក់បញ្ញើ

សេចក្ដីដូចមានកំណត់ សូម **ឯកឧត្ដមប្រធាន** មេត្ដាអនុញ្ញាតដោយក្ដីអនុគ្រោះ។

សូម ឯកឧត្ដមប្រធាន ទទួលនូវសេចក្ដីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៤

<u>ឯកសារភ្ជាប់</u> **អ្នកតំណាងដោយអាណត្តិ**

១-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ "ច្បាប់ដើម"

២-ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ "ចំនួន ០២ ច្បាប់"

៣-លិខិតបញ្ជាក់អះអាងអំពីតម្លៃដី "ចំនួន ០២ ច្បាប់"

បញ្ជីសារពើភ័ណ្ឌស្ដីពីមត៌ក[64]

១.អចលនវត្ថុ[65]

ទីតាំងស្ថិតនៅ ៖ ភូមិ....... សង្កាត់ ផ្សារកណ្ដាល ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ

លេខវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុះ

លេខក្បាលដី ៖

កម្មសិទ្ធករ ៖ ឈ្មោះ និង អាសយដ្ឋាន

អាគារដែលជាសមាសភាពនៃដីខាងលើ

---

[63] ចំពោះឯកសារបញ្ជាក់ដំបូង ចាំបាច់ត្រូវតែដាក់ឯកសារដែលចាំបាច់ និងគ្រប់គ្រាន់ទៅតុលាការ ដើម្បីឲ្យតុលាការទទួលស្គាល់នូវខ្លឹមសារនៃដីកាសម្រេចដែលទាមទារឲ្យតុលាការចេញ និង អង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ ប៉ុន្តែដំណើរការនៃការព្រមព្រៀងទាក់ទងនឹងវិធីបែងចែកមត៌កជាដើម អំពីចំណុចដែលមិនមានឯកសារត្រឹមត្រូវ នឹងក្លាយជាការពន្យល់នៅក្នុងការសួរជំនួសនៅតុលាការ ( ច្បាប់ស្ដីពីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹងមាត្រា ២៨ កថាខណ្ឌទី២ )។

[64] បញ្ជីសារពើភ័ណ្ឌនៃមត៌ក ត្រូវសរសេរខ្លឹមសារដែលអាចឲ្យតុលាការយកមកប្រើប្រាស់ក្នុងដីកាសម្រេចបានតែម្ដង។

[65] អចលនវត្ថុ ចាំបាច់ត្រូវធ្វើនូវបញ្ជីសារពើភ័ណ្ឌដែលមានទម្រង់ ឬ ខ្លឹមសារដែលអាចយកទៅធ្វើការចុះបញ្ជីបាន។

២.ប្រាក់បញ្ញើក្នុងធនាគារ[66]

ធនាគារ ៖ ប្រទេសកម្ពុជា ធានាគារពាណិជ្ជទី១

សាខា ៖ សាខាតាមដងមហាវិថីព្រះមុន្នីវង្ស

លេខគណនីធនាគារ ៖

ឈ្មោះម្ចាស់គណនី ៖

៣.សាច់ប្រាក់ ៖ ( អ្នកថែរក្សាគ្រប់គ្រង )[67]

ប្រាក់..........រៀល

---

[66] ប្រាក់បញ្ញើក្នុងធនាគារ ចាំបាច់ត្រូវកំណត់ឲ្យបានច្បាស់លាស់អំពីខ្លឹមសារនៃប្រាក់បញ្ញើ ដើម្បីអាចតតាំងដោយភាពត្រឹមត្រូវជាមួយនឹងធនាគារ (ក្រមរដ្ឋប្បវេណី ១២៧៥ កថាខណ្ឌទី១ )។

[67] សាច់ប្រាក់ភាគច្រើនត្រូវកំណត់ដោយដាក់ឈ្មោះរបស់អ្នកថែរក្សាគ្រប់គ្រង ដោយសារតែវាមានភាពពិបាកក្នុងការកំណត់។

# ច្បាប់

# ស្តីពី

# នីតិវិធីនៃរឿងក្តីដែលមិនមែនជាបណ្តឹង

# ព្រះរាជក្រម

នស/រកម/០៧១០/០១៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៧ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.- គោលដៅនៃច្បាប់នេះ**

ច្បាប់នេះមានគោលដៅបញ្ញត្តនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ។

**មាត្រា ២.- គោលបំណងនៃច្បាប់នេះ**

ច្បាប់នេះមានគោលបំណងធានាការអនុវត្តឲ្យបានត្រឹមត្រូវនូវនីតិវិធីក្នុងការដោះស្រាយរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ។

**មាត្រា ៣.- វិសាលភាពនៃច្បាប់នេះ**

១- ក្នុងចំណោមចំណុចដែលស្ថិតនៅក្រោមសិទ្ធិអំណាចរបស់តុលាការ ដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ចំពោះចំណុចដែលកំណត់ក្នុងផ្នែកនីមួយៗ នៃតារាងឧបសម្ព័ន្ធ តុលាការត្រូវសម្រេចសេចក្តីតាមបញ្ញត្តិនៃច្បាប់នេះ លើកលែងតែករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ផ្សេង ។

២- ការសម្រេចសេចក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើឡើងដោយដីកាសម្រេច ។

៣- ក្រៅពីករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់នេះ បញ្ញត្តិស្តីពីដីកាសម្រេច ដូចមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ ។

## ជំពូកទី ២
## តុលាការ
## ផ្នែកទី ១
## សមត្ថកិច្ចសាលាជម្រះក្តី

**មាត្រា ៤.- តុលាការដែលមានសមត្ថកិច្ច**

១- រឿងក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) ខាងលើនេះ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ ។

២- សមត្ថកិច្ចសាលាជម្រះក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវកំណត់ដោយយកពេលដាក់ពាក្យសុំ ។

## មាត្រា ៥.- ការកំណត់តុលាការដែលមានសមត្ថកិច្ច

១- ក្នុងករណីដែលតុលាការមានសមត្ថកិច្ច មិនអាចអនុវត្តសិទ្ធិសម្រេចសេចក្តីបាន ដោយសារច្បាប់ ឬ ហេតុការណ៍ពិត ឬ ករណីដែលសមត្ថកិច្ចសាលាជម្រះក្តីមិនអាចកំណត់បាន ដោយសារដែនសមត្ថកិច្ចនៃតុលាការមិនពិតប្រាកដ តុលាការកំពូលត្រូវកំណត់តុលាការដែលមានសមត្ថកិច្ច ដោយដីកាសម្រេចតាមពាក្យសុំ ។

២- ចំពោះដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចប្តឹងឧបាស្រ័យបានឡើយ ។

## មាត្រា ៦.- ការចាត់ចែងរឿងក្តីខុសសមត្ថកិច្ច

១- ប្រសិនបើតុលាការយល់ឃើញថា រឿងក្តីណាមួយមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនទេ តុលាការនេះត្រូវផ្ទេររឿងក្តីនោះទៅតុលាការដែលមានសមត្ថកិច្ច តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិ ។

២- ពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ លើកលែងតែករណីដែលមានការដាក់ពាក្យសុំនៅកាលបរិច្ឆេទ ។ នៅពេលដាក់ពាក្យសុំនេះ ត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់អំពីមូលហេតុនៃពាក្យសុំនោះ ។

## មាត្រា ៧.- សមត្ថកិច្ចជាអាទិភាព និង ការផ្ទេរ

១- ក្នុងករណីមានតុលាការច្រើនមានសមត្ថកិច្ចលើរឿងក្តីណាមួយ តុលាការដែលទទួលពាក្យសុំមុនគេចំពោះរឿងក្តីនោះ ត្រូវមានសមត្ថកិច្ច ។

២- ក្នុងករណីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើយល់ឃើញថាសមរម្យដើម្បីចាត់ចែងរឿងក្តី តុលាការអាចផ្ទេររឿងក្តីនោះទៅតុលាការផ្សេងដែលមានសមត្ថកិច្ចតាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិបាន ។

៣- ពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ លើកលែងតែករណីដែលមានការដាក់ពាក្យសុំនៅកាលបរិច្ឆេទ។

## មាត្រា ៨.- ការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ

តុលាការអាចពិនិត្យភស្តុតាងចំពោះបញ្ហាដែលទាក់ទងនឹងសមត្ថកិច្ចដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន ។

## មាត្រា ៩.- បណ្តឹងជំទាស់

១- ចំពោះដីកាសម្រេចផ្ទេរ និង ដីកាសម្រេចលើកចោលពាក្យសុំផ្ទេរ អាចប្តឹងជំទាស់បាន ។

២- បញ្ញត្តិនៃមាត្រា ៤០ (អំឡុងពេលសម្រាប់ប្តឹងជំទាស់) និង មាត្រា ៤១ (ការបំពេញនូវសកម្មភាពប្តឹងជំទាស់ ក្រោយពីអំឡុងពេលសម្រាប់ប្តឹងជំទាស់បានកន្លងផុត) នៃច្បាប់នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងជំទាស់ដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

## មាត្រា ១០.- អានុភាពនៃដីកាសម្រេចផ្ទេរ ជាអាទិ៍

១- ដីកាសម្រេចស្ថាពរនៃការផ្ទេរ ត្រូវមានអានុភាពឲ្យតុលាការដែលទទួលការផ្ទេរប្រតិបត្តិតាម ។

២- តុលាការដែលទទួលការផ្ទេរ មិនអាចផ្ទេររឿងក្តីទៅតុលាការផ្សេងទៀតបានឡើយ ។

៣- នៅពេលដីកាសម្រេចផ្ទេរចូលជាស្ថាពរ រឿងក្តីនោះត្រូវចាត់ទុកថាតុលាការដែលទទួលការផ្ទេរចាត់ការតាំងពីដើម ។

៤- នៅពេលដីកាសម្រេចផ្ទេរចូលជាស្ថាពរ តុលាការដែលបានសម្រេចការផ្ទេរ ត្រូវបញ្ជូនសំណុំរឿងអំពីរឿងក្តីនេះ ទៅតុលាការដែលទទួលការផ្ទេរ ។

# ផ្នែកទី ២
# រចនាសម្ព័ន្ធនៃតុលាការ

## មាត្រា ១១.- ការជម្រះក្តីលើកទី ១ ដោយចៅក្រមមួយរូប ឬ ដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម

១- នៅសាលាដំបូង រឿងក្តីត្រូវទទួលបន្ទុកដោះស្រាយដោយចៅក្រមម្នាក់ លើកលែងតែករណីដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងក្រោមនេះ ។

២- ចំពោះរឿងក្តីដែលតុលាការយល់ឃើញថា គួរតែត្រូវបានវិនិច្ឆ័យ និង ជម្រះដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ដោយគិតពិចារណាអំពីចំនួននៃជនពាក់ព័ន្ធ និង បញ្ហាផ្សេងទៀត ត្រូវទទួលបន្ទុកដោះស្រាយដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ។

ROYAUME DU CAMBODGE ★ MINISTÈRE DU PALAIS ROYAL

Kol

៣- ក្នុងក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ ត្រូវមានចៅក្រម ៣ (បី) នាក់ ហើយចាត់តាំងម្នាក់ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។

៤- ដីកាសម្រេចឲ្យវិនិច្ឆ័យ និង ជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ដោយយោងតាមកថាខណ្ឌទី ២ ខាងលើនេះ ត្រូវធ្វើឡើងដោយក្រុមប្រឹក្សា ។

## មាត្រា ១២.- ការពិភាក្សានៃក្រុមប្រឹក្សាជំនុំជម្រះ

១- ការពិភាក្សានៃក្រុមប្រឹក្សាជំនុំជម្រះមិនត្រូវធ្វើជាសាធារណៈទេ ។

២- ការពិភាក្សាត្រូវបានបើក និងដឹកនាំដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។

៣- ចៅក្រមម្នាក់ៗ ត្រូវបញ្ចេញមតិយោបល់របស់ខ្លួនក្នុងការពិភាក្សានេះ ។

៤- ដំណើរការនៃការពិភាក្សា មតិយោបល់របស់ចៅក្រមម្នាក់ៗ និង ចំនួនសំឡេងនៃមតិត្រូវរក្សាទុកជាសម្ងាត់ ។

## មាត្រា ១៣.- ការសម្រេចនៃក្រុមប្រឹក្សាជំនុំជម្រះ

១- ការសម្រេចត្រូវធ្វើឡើងដោយមតិភាគច្រើនរបស់ចៅក្រមក្នុងក្រុមប្រឹក្សាជំនុំជម្រះ ។

២- ចៅក្រមម្នាក់ៗ ក្នុងក្រុមប្រឹក្សាជំនុំជម្រះ ត្រូវមានសិទ្ធិសម្រេចស្មើគ្នា ។

# ផ្នែកទី ៣
# ការដកហូតសមត្ថកិច្ចជំនុំជម្រះ បណ្តឹងជំទាស់ និង ការដកខ្លួន

## មាត្រា ១៤.- ការដកហូតសមត្ថកិច្ចជំនុំជម្រះ បណ្តឹងជំទាស់ និង ការដកខ្លួនរបស់ចៅក្រម ជាអាទិ៍

១- បញ្ញត្តិស្តីពីការដកហូតសមត្ថកិច្ចជំនុំជម្រះ បណ្តឹងជំទាស់ និងការដកខ្លួនរបស់ចៅក្រម និង ក្រឡាបញ្ជីតុលាការនៅក្នុងផ្នែកទី ៣ (ការបែងចែករឿងក្តី និង ការដកហូតសមត្ថកិច្ចជំនុំជម្រះ និង បណ្តឹងជំទាស់) ជំពូកទី ២ គន្ថីទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះរឿងក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ ។

២- បញ្ញត្តិនៃមាត្រា ៤០ (អំឡុងពេលសម្រាប់ប្តឹងជំទាស់) និង មាត្រា ៤១ (ការបំពេញនូវសកម្មភាពប្តឹងជំទាស់ ក្រោយអំឡុងពេលសម្រាប់ប្តឹងជំទាស់បានកន្លងផុត) នៃច្បាប់នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងជំទាស់ដែលកំណត់ក្នុងបញ្ញត្តិនៃផ្នែកទី ៣ (ការបែងចែករឿងក្តី

និង ការផាកពិន័យសមត្ថកិច្ចជំនុំជម្រះ និងបណ្តឹងជំទាស់) ជំពូកទី ២ គន្ថីទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលត្រូវបានយកមកអនុវត្ត ដោយយោងតាមកថាខណ្ឌទី ១ ខាងលើនេះ ។

## ជំពូកទី ៣
## ជនពាក់ព័ន្ធ

### មាត្រា ១៥.- ជនពាក់ព័ន្ធ

ចំពោះរឿងក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ ជនដាក់ពាក្យសុំ ភាគីម្ខាងទៀតនៃពាក្យសុំ និងជនផ្សេងទៀត ដែលទទួលឥទ្ធិពលផ្ទាល់ដល់សិទ្ធិរបស់ខ្លួន ឬ ដល់ឋានៈរបស់ខ្លួនតាមផ្លូវច្បាប់ដោយដីកាសម្រេចអំពីរឿងក្តីនោះ អាចចូលរួមក្នុងនីតិវិធីនៃរឿងក្តីនោះ ក្នុងនាមជាជនពាក់ព័ន្ធនៅក្នុងរឿងក្តីនោះ ។

### មាត្រា ១៦.- សមត្ថភាពរបស់ជនពាក់ព័ន្ធ

ជនដែលកំណត់ក្នុងមាត្រា ១៥ (ជនពាក់ព័ន្ធ) ខាងលើនេះ ត្រូវតែជាបុគ្គលដែលអាចក្លាយជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ចតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី និង ច្បាប់ផ្សេងទៀត ។

### មាត្រា ១៧.- សមត្ថភាពក្នុងការធ្វើសកម្មភាពនៃនីតិវិធី ការតំណាងដែលច្បាប់បានកំណត់សម្រាប់ជនដែលគ្មានសមត្ថភាពក្នុងការធ្វើសកម្មភាពនៃនីតិវិធី

១- បុគ្គលដែលមានសមត្ថភាពធ្វើសកម្មភាពដោយខ្លួនឯងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី និង ច្បាប់ផ្សេងទៀត អាចធ្វើសកម្មភាពនៃនីតិវិធីចាំបាច់ ដោយតាំងខ្លួនជាជនពាក់ព័ន្ធក្នុងនីតិវិធីនៃរឿងក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះបាន ។

២- អនីតិជន និង ជននៅក្រោមអាណាព្យាបាលទូទៅ មិនអាចធ្វើសកម្មភាពនៃនីតិវិធីសុពលបានឡើយ ប្រសិនបើសកម្មភាពនោះមិនបានធ្វើឡើងដោយអ្នកតំណាងដែលច្បាប់បានកំណត់ ។ ប៉ុន្តែបញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលបានកំណត់ខាងក្រោមនេះ ៖

ក- ករណីដែលអនីតិជនអាចធ្វើសកម្មភាពដោយឯករាជ្យ ។

ខ- ករណីដែលអនីតិជន និង ជននៅក្រោមអាណាព្យាបាលទូទៅ ធ្វើសកម្មភាពពាក់ព័ន្ធនឹងឋានៈរបស់ខ្លួន ។

៣- បញ្ញត្តិនៃក្រមរដ្ឋប្បវេណី និង ច្បាប់ផ្សេងទៀត ត្រូវយកមកអនុវត្តចំពោះអ្នកតំណាងដែលច្បាប់បានកំណត់ ដូចមានចែងក្នុងកថាខណ្ឌទី ២ ខាងលើនេះ និង សិទ្ធិតំណាងរបស់អ្នកតំណាងនោះ ។

៤- បញ្ញត្តិចាប់ពីមាត្រា ៣៣ (បញ្ញត្តិពិសេសស្តីពីសកម្មភាពបណ្តឹងរបស់ជននៅក្រោមហិតូបត្ថម្ភ និង អ្នកតំណាងដែលច្បាប់បានកំណត់) ដល់មាត្រា ៣៨ (ការអនុវត្តដូចគ្នាចំពោះអ្នកតំណាងនៃនីតិបុគ្គល) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសមត្ថភាពអាចធ្វើសកម្មភាពនៃនីតិវិធីសុពលក្នុងនាមជាជនពាក់ព័ន្ធដែលកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ និង ចំពោះអ្នកតំណាងដែលច្បាប់បានកំណត់ ដូចមានចែងក្នុងកថាខណ្ឌទី ២ និងទី ៣ ខាងលើនេះ និង សិទ្ធិតំណាងរបស់អ្នកតំណាងនោះ ។

**មាត្រា ១៨.- សកម្មភាពនៃនីតិវិធីដែលធ្វើឡើងដោយអ្នកតំណាងដោយអាណត្តិ**

១- ជនពាក់ព័ន្ធអាចធ្វើសកម្មភាពទាក់ទងនឹងនីតិវិធីទាំងអស់ ដោយខ្លួនឯងផ្ទាល់ ឬ ធ្វើសកម្មភាពនោះ ដោយឆ្លងតាមរយៈអ្នកតំណាងដោយអាណត្តិដែលខ្លួនបានជ្រើសតាំង ។

២- ទោះបីជនពាក់ព័ន្ធបានជ្រើសតាំងអ្នកតំណាងដោយអាណត្តិក៏ដោយ ក៏ជននោះអាចធ្វើសកម្មភាពទាក់ទងនឹងនីតិវិធីបានដែរ ។

**មាត្រា ១៩.- លក្ខណសម្បត្តិនៃអ្នកតំណាងដោយអាណត្តិ**

១- អ្នកតំណាងដោយអាណត្តិដែលកំណត់ក្នុងមាត្រា ១៨ (សកម្មភាពនៃនីតិវិធីដែលធ្វើឡើងដោយអ្នកតំណាងដោយអាណត្តិ) ខាងលើនេះ ត្រូវតែជាមេធាវី ឬ ជនដែលបានទទួលនូវការអនុញ្ញាតពីតុលាការ ។

២- តុលាការអាចលុបចោលការអនុញ្ញាតដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដែលផ្តល់ជនក្រៅពីមេធាវីនៅពេលណាក៏បាន ។

**មាត្រា ២០.- ការបញ្ជាក់នូវសិទ្ធិតំណាងដោយអាណត្តិ**

សិទ្ធិអំណាចរបស់អ្នកតំណាងដោយអាណត្តិ ដែលត្រូវបានជ្រើសតាំងដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ១៨ (សកម្មភាពនៃនីតិវិធីដែលធ្វើឡើងដោយអ្នកតំណាងដោយអាណត្តិ) នៃច្បាប់នេះ ត្រូវបញ្ជាក់ជាលាយលក្ខណ៍អក្សរ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះ

អ្នកតំណាងដោយផ្អែកលើការអនុញ្ញាតរបស់តុលាការដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ១៩ (លក្ខណសម្បត្តិនៃអ្នកតំណាងដោយអាណត្តិ) ខាងលើនេះ ។

**មាត្រា ២១.- ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីសិទ្ធិតំណាងដោយអាណត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី**

បញ្ញត្តិនៃមាត្រា ៥៥ (ករណីដែលសិទ្ធិតំណាងដោយអាណត្តិមិនរលត់) មាត្រា ៥៦ (ហេតុនៃការរលត់នូវសិទ្ធិតំណាងដោយអាណត្តិ) និង មាត្រា ៥៧ (វិធានការក្នុងករណីនៃការខ្វះសិទ្ធិតំណាង) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកតំណាងដោយអាណត្តិ ។

## ជំពូកទី ៤
## ប្រាក់ប្រដាប់ក្តី

**មាត្រា ២២.- បន្ទុកនៃប្រាក់ប្រដាប់ក្តី**

១- ដើម្បីដាក់ពាក្យសុំតាមនីតិវិធីនៃរឿងក្តីដែលកំណត់ក្នុងច្បាប់នេះ ត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល ។

២- បញ្ញត្តិនៃមាត្រា ៦២ (ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ) និង មាត្រា ៦៣ (ប្រាក់ប្រដាប់ក្តីភាគី) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះប្រាក់ប្រដាប់ក្តីក្រៅពីពន្ធដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ។

៣- ប្រាក់ប្រដាប់ក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ
គឺជាបន្ទុករបស់អ្នកដាក់ពាក្យសុំ
លើកលែងតែក្នុងករណីដែលមានកំណត់ពិសេសអំពីអ្នកទទួលបន្ទុកនោះក្នុងច្បាប់នេះ ។

៤- ចំពោះរឿងក្តីដែលតំណាងអយ្យការបានដាក់ពាក្យសុំ ឬ រឿងក្តីដែលតុលាការបានចាប់ផ្តើមដោយឆន្ទានុសិទ្ធិរបស់ខ្លួន ប្រាក់ប្រដាប់ក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ ជាបន្ទុករបស់រដ្ឋ ។

៥- បញ្ញត្តិនៃកថាខណ្ឌទី ៣ មាត្រា ៦៤ (ភាគដែលត្រូវទទួលបន្ទុក និង ការសងវិញនូវប្រាក់ប្រដាប់ក្តីដែលបានបង់រួចហើយ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានជនច្រើននាក់ដែលត្រូវទទួលបន្ទុកប្រាក់ប្រដាប់ក្តីដោយរួមគ្នា ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

៦- ក្នុងករណីដែលអ្នកដាក់ពាក្យសុំ ត្រូវបង់ពន្ធដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើអ្នកដាក់ពាក្យសុំមិនបានបង់ពន្ធនោះទេ តុលាការត្រូវកំណត់អំឡុងពេលសមរម្យ និង បង្គាប់ឲ្យបង់ពន្ធនោះ។ ក្នុងករណីនេះ ប្រសិនបើអ្នកដាក់ពាក្យសុំមិនបានបង់ពន្ធនោះទេ តុលាការត្រូវលើកលិខិតពាក្យសុំចោលដោយដីកាសម្រេច ។

៧- ចំពោះដីកាសម្រេចលើកចោលលិខិតពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ៦ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

៨- ដើម្បីប្តឹងជំទាស់ ដោយយោងតាមបញ្ញត្តិនៃមាត្រា ៣៩ (បណ្តឹងជំទាស់) នៃច្បាប់នេះ ត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល ។ បញ្ញត្តិនៃកថាខណ្ឌទី ៦ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកដាក់ពាក្យបណ្តឹងជំទាស់មិនបានបង់ពន្ធនោះ ។

## មាត្រា ២៣.- ដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តី

១- ប្រសិនបើយល់ឃើញថាចាំបាច់សម្រេចអំពីអ្នកទទួលបន្ទុក ឬ ចំនួនទឹកប្រាក់នៃប្រាក់ប្រដាប់ក្តីដែលកំណត់ក្នុងមាត្រា ២២ (បន្ទុកនៃប្រាក់ប្រដាប់ក្តី)ខាងលើនេះ តុលាការត្រូវកំណត់ចំនួនទឹកប្រាក់នៃប្រាក់ប្រដាប់ក្តីនោះ និង ត្រូវចេញដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តីនោះ ព្រមជាមួយគ្នានឹងដីកាសម្រេចអំពីរឿងក្តីនោះ ។

២- ក្នុងករណីដែលមានស្ថានភាពពិសេស តុលាការអាចបង្គាប់ឲ្យជនពាក់ព័ន្ធដែលមិនមែនជាជនដែលត្រូវទទួលបន្ទុកនូវប្រាក់ប្រដាប់ក្តីតាមបញ្ញត្តិនៃច្បាប់នេះ ទទួលបន្ទុកនូវប្រាក់ប្រដាប់ក្តីទាំងស្រុង ឬ មួយភាគបាន ។

៣- ចំពោះដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តី មានតែជនដែលត្រូវបានបង្គាប់ឲ្យទទួលបន្ទុកប្រាក់ប្រដាប់ក្តីនេះទេ ដែលអាចប្តឹងជំទាស់បាន ប៉ុន្តែមិនអាចប្តឹងជំទាស់ដោយឯករាជ្យបានឡើយ ។

## មាត្រា ២៤.- ការអនុវត្តដោយបង្ខំអំពីប្រាក់ប្រដាប់ក្តី

១- ម្ចាស់បំណុលលើប្រាក់ប្រដាប់ក្តី អាចអនុវត្តដោយបង្ខំ ដោយផ្អែកលើដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តីបាន ។

២- បញ្ញត្តិនៃគន្ថីទី ៦ (ការអនុវត្តដោយបង្ខំ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តដោយបង្ខំដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប៉ុន្តែមិនចាំបាច់ធ្វើការបញ្ជូនដីកាសម្រេចមុនពេលអនុវត្តទេ ។

៣- បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣០៥ (ការផ្អាកអានុភាពនៃដីកាសម្រេចដើម) នៃក្រមនីតិវិធីរដ្ឋប្បវេណីត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានបណ្តឹងជំទាស់ ចំពោះដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តី ។

**មាត្រា ២៥.- ការបង់ប្រាក់ប្រដាប់ក្តីជំនួសជាមុន**

ចំពោះប្រាក់ប្រដាប់ក្តីសម្រាប់ការពិនិត្យភស្តុតាង ការកោះហៅ ការជូនដំណឹង និង ការចាត់ចែងចាំបាច់ផ្សេងទៀត ដែលធ្វើឡើងដោយឆន្ទានុសិទ្ធិរបស់តុលាការ រដ្ឋត្រូវបង់ជំនួសជាមុន ប៉ុន្តែចំពោះសកម្មភាពដែលត្រូវការប្រាក់ប្រដាប់ក្តី តុលាការអាចបង្គាប់ឲ្យជនពាក់ព័ន្ធបង់ប្រាក់ប្រដាប់ក្តីនោះជាមុនបាន ។

## ជំពូកទី ៥
## ការវិនិច្ឆ័យ

**មាត្រា ២៦.- របៀបដាក់ពាក្យសុំ និងចំណុចដែលត្រូវសរសេរក្នុងពាក្យសុំ**

១- ពាក្យសុំអាចធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់បាន លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ឬ ច្បាប់ផ្សេងទៀត ។

២- នៅក្នុងលិខិតនៃពាក្យសុំត្រូវសរសេរបញ្ជាក់នូវចំណុចខាងក្រោមនេះ ៖

ក- ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ- ខ្លឹមសារនៃដីកាសម្រេច ឬ សកម្មភាពផ្សេងទៀតរបស់តុលាការដែលអ្នកដាក់ពាក្យសុំទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ ។

៣- ដើម្បីដាក់ពាក្យសុំដោយផ្ទាល់មាត់ អ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្តីថ្លែងការណ៍នូវចំណុចនីមួយៗ ដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ នៅចំពោះមុខក្រឡាបញ្ជី ។ ក្នុងករណីនេះ ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុ និង ចុះហត្ថលេខា ។ កំណត់ហេតុនោះត្រូវបានចាត់ទុកជាលិខិតពាក្យសុំ ។

៤- ក្នុងករណីដែលមានឯកសារជាភស្តុតាង អ្នកដាក់ពាក្យសុំត្រូវភ្ជាប់នូវឯកសារដើម ឬ ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ជាមួយនឹងលិខិតនៃពាក្យសុំ ឬ ត្រូវដាក់ជូនឯកសារទាំងនោះទៅតុលាការនៅពេលដាក់ពាក្យសុំ ។

**មាត្រា ២៧.- ការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ និង ការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ**

១- តុលាការអាចយកអង្គហេតុដែលមិនបានអះអាងដោយអ្នកដាក់ពាក្យសុំ ឬ ដោយភាគីម្ខាងទៀតមកធ្វើជាមូលដ្ឋាននៃដីកាសម្រេចបាន ។

២- ប្រសិនបើយល់ឃើញថាចាំបាច់ តុលាការត្រូវធ្វើការស្រាវជ្រាវអង្គហេតុ និង ធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ ។

**មាត្រា ២៨.- ការទាញហេតុផលដោយផ្ទាល់មាត់ និងការសួរដោយឆន្ទានុសិទ្ធិ**

១- ដើម្បីចេញដីកាសម្រេចអំពីរឿងក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ តុលាការពុំចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ឡើយ ។

២- ក្នុងករណីដែលមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចសួរអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬ ជនផ្សេងទៀតដែលតុលាការយល់ឃើញថាចាំបាច់បាន ។ ក្នុងករណីនេះ តុលាការអាចអនុញ្ញាតឲ្យអ្នកដែលតុលាការយល់ថាសមរម្យ ចូលស្តាប់ជាអ្នកសង្កេតការណ៍បាន ។

**មាត្រា ២៩.-ករណីយកិច្ចបង្ហាញខ្លួនរបស់សាមីខ្លួន**

១- តុលាការអាចកោះហៅអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬ ជនផ្សេងទៀត ដែលតុលាការយល់ឃើញថាចាំបាច់បាន ដោយកំណត់កាលបរិច្ឆេទ ។

២-ក្នុងករណីជនដែលត្រូវបានកោះហៅដោយតុលាការ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនបានបង្ហាញខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវទេ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ១.០០០.០០០ (មួយលាន) រៀល បាន ។

**មាត្រា ៣០.- ការចូលរួមរបស់តំណាងអយ្យការ និង ការជូនដំណឹង**

១- ប្រសិនបើយល់ឃើញថាចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ តុលាការត្រូវជូនដំណឹងទៅតំណាងអយ្យការអំពីរឿងក្តី និង កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ ក្នុងកាលបរិច្ឆេទនៃការសួរ ។

២- ប្រសិនបើយល់ឃើញថាចាំបាច់ការពារផលប្រយោជន៍សាធារណៈ តំណាងអយ្យការអាចបញ្ចេញមតិចំពោះរឿងក្តី និង ចូលរួមក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ ក្នុងកាលបរិច្ឆេទនៃការសួរបាន ។

៣- ក្នុងករណីដែលបានដឹងតាមមុខនាទីរបស់ខ្លួនថា ករណីដែលតំណាងអយ្យការអាចដាក់ពាក្យសុំ ឬ ទាមទារបានកើតឡើង តុលាការ ស្ថាប័នរដ្ឋផ្សេងទៀត និង មន្ត្រីស្ថាប័នទាំងនោះ និង តំណាងអយ្យការ ត្រូវជូនដំណឹងអំពីករណីនោះទៅតំណាងអយ្យការអមតុលាការដែលមានសមត្ថកិច្ច ។

## មាត្រា ៣១.- ការចូលរួមក្នុងនីតិវិធីរបស់ជនពាក់ព័ន្ធនឹងផលប្រយោជន៍

១- ប្រសិនបើយល់ឃើញថាសមរម្យ តុលាការអាចឲ្យជនក្រៅពីអ្នកដាក់ពាក្យសុំ ឬ ភាគីម្ខាងទៀត ក្នុងចំណោមជនពាក់ព័ន្ធដែលកំណត់ក្នុងមាត្រា ១៥ (ជនពាក់ព័ន្ធ) នៃច្បាប់នេះ ចូលរួមក្នុងនីតិវិធីបាន ។

២- ជនដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចចូលរួមក្នុងនីតិវិធីបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

## មាត្រា ៣២.- ការទទួលបន្តនូវនីតិវិធី

១- ក្នុងករណីដែលអ្នកដាក់ពាក្យសុំ ឬ ភាគីម្ខាងទៀត មិនអាចបន្តនីតិវិធីដោយសារមរណភាព ការបាត់បង់លក្ខណសម្បត្តិ ឬមូលហេតុផ្សេងទៀត ជនដែលមានលក្ខណសម្បត្តិក្នុងការដាក់ពាក្យសុំឲ្យដំណើរការនីតិវិធីនោះ តាមច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត អាចដាក់ពាក្យសុំទទួលបន្តនូវនីតិវិធីនោះបាន ។

២- ក្នុងករណីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើយល់ឃើញថាចាំបាច់ តុលាការអាចបង្គាប់ឲ្យជនដែលមានលក្ខណសម្បត្តិក្នុងការដាក់ពាក្យសុំឲ្យដំណើរការនីតិវិធីនោះតាមច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ទទួលបន្តនូវនីតិវិធីនោះបាន ។

## មាត្រា ៣៣.- ការមើលសំណុំរឿង ជាអាទិ៍

១- ប្រសិនបើយល់ឃើញថាសមរម្យ តុលាការអាចអនុញ្ញាតឲ្យមើល ឬឲ្យថតចម្លងសំណុំរឿង ឬ អាចបង្គាប់ឲ្យក្រឡាបញ្ជីប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឯកសារដកស្រង់នៃសំណុំរឿង ឬ លិខិតបញ្ជាក់អំពីចំណុចទាក់ទងនឹងរឿងក្តីបាន តាមពាក្យសុំរបស់ជនពាក់ព័ន្ធនឹងរឿងក្តីនោះ ដោយឲ្យបង់សោហ៊ុយ ។



២- ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ប្រសិនបើអ្នកដាក់ពាក្យសុំ ឬភាគីម្ខាងទៀត ទាមទារឲ្យប្រគល់នូវឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬឯកសារដកស្រង់នៃលិខិតដីកាសម្រេច ឬ ទាមទារឲ្យប្រគល់នូវលិខិតបញ្ជាក់អំពីចំណុចទាក់ទងនឹងរឿងក្តី ក្រឡាបញ្ជីត្រូវប្រគល់ឯកសារ ឬ លិខិតនោះ ។

## មាត្រា ៣៤.- ការអនុវត្តដូចគ្នាតាមក្រមនីតិវិធីរដ្ឋប្បវេណី

១- បញ្ញត្តិស្តីពីកាលបរិច្ឆេទ អំឡុងពេល វិធីធ្វើសេចក្តីបញ្ជាក់ដំបូង នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីដែលកំណត់ក្នុងច្បាប់នេះ លើកលែងតែមានភាពផ្ទុយគ្នានឹងលក្ខណៈនៃនីតិវិធីនេះ ។

២- បញ្ញត្តិស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ ការសាកសួរសាក្សី ការសាកសួរភាគីកោសលវិច័យ ការត្រួតពិនិត្យ និងភស្តុតាងជាឯកសារ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវអនុវត្តដូចគ្នាផងដែរចំពោះករណីដែលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ នៅក្នុងនីតិវិធីដែលកំណត់ក្នុងច្បាប់នេះ លើកលែងតែមានភាពផ្ទុយគ្នានឹងលក្ខណៈនៃនីតិវិធីនេះ ។

# ជំពូកទី ៦
# ការសម្រេចសេចក្តី

## មាត្រា ៣៥.- វិធីសម្រេចសេចក្តី

ដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ត្រូវសរសេរសំអាងហេតុ និងសេចក្តីសម្រេចបញ្ចប់ ហើយចៅក្រមត្រូវចុះហត្ថលេខាលើសេចក្តីសម្រេចនេះ ។

## មាត្រា ៣៦.- ការជូនដំណឹងអំពីដីកាសម្រេច

ដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ ត្រូវជូនដំណឹងទៅជនដែលត្រូវទទួលដីកាសម្រេចនេះ ។ ការជូនដំណឹងអំពីដីកាសម្រេចនេះ ត្រូវធ្វើឡើងតាមរយៈការបញ្ជូន ឬ ការធ្វើជូនឯកសារចម្លងយថាភូតនៃដីកាសម្រេចនោះ ។

**មាត្រា ៣៧.- ការចូលជាស្ថាពរ និង ការបង្កើតអានុភាពនៃដីកាសម្រេច**

១- ដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ មិនត្រូវចូលជាស្ថាពរនៅមុនពេលផុតអំឡុងពេលសម្រាប់ការប្តឹងជំទាស់ដែលកំណត់ក្នុងមាត្រា ៤០ (អំឡុងពេលសម្រាប់ប្តឹងជំទាស់) នៃច្បាប់នេះ ។

២- ការចូលជាស្ថាពរនៃដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានបង្អាក់ដោយការប្តឹងជំទាស់ ដែលត្រូវបានធ្វើឡើងនៅក្នុងអំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ១ នោះ ។

៣- ដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរទេ ។

**មាត្រា ៣៨.- អានុភាពអនុវត្តនៃដីកាសម្រេច**

ដីកាសម្រេចបង្គាប់ឲ្យបង់ប្រាក់ ប្រគល់វត្ថុ អនុវត្តករណីយកិច្ចចុះបញ្ជី ឬ ផ្តល់តាវកាលិកផ្សេងទៀតដែលចូលជាស្ថាពរ ត្រូវក្លាយជាលិខិតអនុវត្តដែលកំណត់ក្នុងមាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## ជំពូកទី ៧
## បណ្តឹងឧបាស្រ័យ

**មាត្រា ៣៩.- បណ្តឹងជំទាស់**

១- បុគ្គលទទួលឥទ្ធិពលដែលខូចប្រយោជន៍ដល់សិទ្ធិ ឬ ឋានៈគតិយុត្តរបស់ខ្លួនដោយសារដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ អំពីរឿងក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ អាចប្តឹងជំទាស់ចំពោះដីកាសម្រេចនោះបាន លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ។

២- ក្នុងករណីដែលត្រូវចេញដីកាសម្រេចតាមតែពាក្យសុំប៉ុណ្ណោះ មានតែជនដែលបានដាក់ពាក្យសុំទេ ដែលអាចប្តឹងជំទាស់ចំពោះដីកាសម្រេចលើកចោលពាក្យសុំបាន ។

**មាត្រា ៤០.- អំឡុងពេលសម្រាប់ប្តឹងជំទាស់**

១- ប្រសិនបើជនដែលអាចប្តឹងជំទាស់ បានទទួលនូវការជូនដំណឹងអំពីដីកាសម្រេច បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃបានទទួលការជូនដំណឹងអំពីដីកាសម្រេចនោះ ។

២- ប្រសិនបើជនដែលអាចប្តឹងជំទាស់ មិនមែនជាជនដែលត្រូវទទួលនូវការជូនដំណឹងអំពីដីកាសម្រេច ដោយយោងតាមបញ្ញត្តិនៃមាត្រា ៣៦ (ការជូនដំណឹងអំពីដីកាសម្រេច) នៃច្បាប់នេះទេ បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលជនដាក់ពាក្យសុំបានទទួលការជូនដំណឹងអំពីដីកាសម្រេចនោះ ។

៣- ចំពោះរឿងក្តីដែលបានចាប់ផ្តើមឡើងដោយឆន្ទានុសិទ្ធិ អំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ ត្រូវគណនាពីថ្ងៃដែលជនបានទទួលក្រោយគេនូវការជូនដំណឹង បានទទួលដំណឹងនោះ ។

៤- អំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ពុំអាចពន្យារបានឡើយ ។

## មាត្រា ៤១.- ការបំពេញនូវសកម្មភាពប្តឹងជំទាស់ ក្រោយពីអំឡុងពេលសម្រាប់ប្តឹងជំទាស់បានកន្លងផុត

១- ក្នុងករណីដែលជនដែលអាចប្តឹងជំទាស់ មិនបានគោរពតាមអំឡុងពេលសម្រាប់ប្តឹងជំទាស់ ដោយគ្មានកំហុសរបស់ខ្លួន ជននោះអាចប្តឹងជំទាស់បានក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍ ក្រោយពេលមូលហេតុនោះបានរលត់ហើយ ចំពោះជនដែលនៅបរទេសវិញ អំឡុងពេលនោះមានចំនួន ២ (ពីរ) ខែ។

២- អំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំអាចពន្យារបានឡើយ ។

## មាត្រា ៤២.- នីតិវិធីនៃការជំនុំជម្រះលើបណ្តឹងជំទាស់

ក្រៅពីបញ្ញត្តិនៃជំពូកទី ៥ (ការវិនិច្ឆ័យ) នៃច្បាប់នេះ បញ្ញត្តិនៃជំពូកទី ៤ (បណ្តឹងជំទាស់) គន្ថីទី ៣ (បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការជំនុំជម្រះលើបណ្តឹងជំទាស់ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសនៅក្នុងជំពូកទី ៧ នេះ ។

# ជំពូកទី ៨
# ការចាត់ចែងរក្សាការពារ

## មាត្រា ៤៣.- នីតិវិធីនៃការចាត់ចែងរក្សាការពារ

១-ក្នុងករណីមានពាក្យសុំអំពីរឿងក្តីដែលកំណត់ក្នុងច្បាប់នេះ តុលាការអាចបង្គាប់ឲ្យធ្វើការរឹបអូសជាបណ្តោះអាសន្ន ការចាត់ចែងជាបណ្តោះអាសន្ន ការជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ

ឬ ការចាត់ចែងរក្សាការពារចាំបាច់ផ្សេងទៀត ដោយដីកាសម្រេចតាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិ ដោយឲ្យដាក់ប្រាតិភោគ ឬ មិនឲ្យដាក់ប្រាតិភោគ ដោយយោងតាមបញ្ញត្តិនៃច្បាប់នេះ ។

២- តុលាការត្រូវបង្គាប់ឲ្យធ្វើការចាត់ចែងរក្សាការពារដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដោយផ្អែកលើសេចក្តីបញ្ជាក់ដំបូង ។

៣-ក្នុងករណីបានដាក់ពាក្យសុំឲ្យចាត់ចែងរក្សាការពារដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អ្នកដាក់ពាក្យសុំ ត្រូវបញ្ជាក់ឲ្យច្បាស់លាស់នូវការចាត់ចែងរក្សាការពារដែលខ្លួនទាមទារ និង មូលហេតុនៃការទាមទារការចាត់ចែងរក្សាការពារនោះ ។

៤- អ្នកដាក់ពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវធ្វើសេចក្តីបញ្ជាក់ដំបូងអំពីមូលហេតុនៃការទាមទារការចាត់ចែងរក្សាការពារ ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ២៧ (ការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ និង ការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ) នៃច្បាប់នេះ ក៏ដោយ ។

៥- ប្រសិនបើយល់ឃើញថាចាំបាច់ តុលាការអាចស្រាវជ្រាវអំពីអង្គហេតុ និង ពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិបាន ។

៦- ដីកាសម្រេចអំពីការចាត់ចែងរក្សាការពារដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវជូនដំណឹងទៅអ្នកទទួលដីកាសម្រេចនោះ ។ ដីកាសម្រេចអំពីការចាត់ចែងរក្សាការពារដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ មានអានុភាពភ្លាមដោយការជូនដំណឹង ។

៧- អានុភាព និងការអនុវត្តនៃការចាត់ចែងរក្សាការពារដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវអនុលោមតាមបញ្ញត្តិស្តីពីអានុភាព និង ការអនុវត្តនូវការរឹបអូសជាបណ្តោះអាសន្ន និង ការចាត់ចែងជាបណ្តោះអាសន្ន នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ។

៨- បញ្ញត្តិនៃមាត្រា ៥៤៥ (ភាពចាំបាច់នៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន) មាត្រា ៥៤៦ (កម្មវត្ថុនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន) មាត្រា ៥៤៧ (ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន) មាត្រា ៥៤៨ (ភាពចាំបាច់នៃដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ជាអាទិ៍) និង មាត្រា ៥៤៩ (វិធីចាត់ចែងជាបណ្តោះអាសន្ន) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការចាត់ចែងរក្សាការពារដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ហើយបញ្ញត្តិនៃមាត្រា ៧១ (វិធីដាក់ប្រាតិភោគ និង ការប្តូរប្រាតិភោគ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះប្រាតិភោគដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ។

## មាត្រា ៤៤.- បណ្តឹងឧទ្ធរណ៍

១- ជនដែលបានដាក់ពាក្យសុំឲ្យចាត់ចែងរក្សាការពារ ដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤៣ ( នីតិវិធីនៃការចាត់ចែងរក្សាការពារ ) ខាងលើនេះ អាចប្តឹងជំទាស់ចំពោះដីកាសម្រេចលើកចោលនូវពាក្យសុំនោះបាន ។

២- ជនដែលអាចប្តឹងជំទាស់ ចំពោះដីកាសម្រេចទទួលស្គាល់ពាក្យសុំអំពីអង្គសេចក្តី អាចប្តឹងជំទាស់ចំពោះការចាត់ចែងរក្សាការពារដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤៣ (នីតិវិធីនៃការចាត់ចែងរក្សាការពារ) ខាងលើនេះបាន ។

៣- ក្នុងករណីដែលបណ្តឹងជំទាស់ត្រូវបានធ្វើឡើងដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ប្រសិនបើមានសេចក្តីបញ្ជាក់ជំបូងអំពីស្ថានភាពដែលច្បាស់ថា នឹងក្លាយជាមូលហេតុនៃការលុបចោលការចាត់ចែងរក្សាការពារ និងអំពីការណ៍ដែលមានការបារម្ភថា ការខូចខាតដែលមានការពិបាកនឹងធ្វើបដិទានឡើងវិញ នឹងកើតឡើងដោយសារការអនុវត្តការចាត់ចែងរក្សាការពារនោះ តុលាការនៃបណ្តឹងជំទាស់ អាចបង្គាប់ឲ្យធ្វើការចាត់ចែងដូចខាងក្រោមនេះ តាមពាក្យសុំ ៖

ក- ផ្អាកការអនុវត្តការចាត់ចែងរក្សាការពារ ដោយឲ្យដាក់ប្រាតិភោគ ឬ មិនឲ្យដាក់ប្រាតិភោគរហូតដល់ពេលដែលដីកាសម្រេចអំពីបណ្តឹងជំទាស់នោះបង្កើតអានុភាព ។

ខ- លុបចោលការចាត់ចែងការអនុវត្តដែលបានធ្វើរួចហើយ ដោយឲ្យដាក់ប្រាតិភោគរហូតដល់ពេលដែលដីកាសម្រេចអំពីបណ្តឹងជំទាស់នោះ បង្កើតអានុភាព ។

៤- ក្នុងអំឡុងពេលដែលសំណុំរឿងក្តី នៅតែមាននៅតុលាការដើម តុលាការដើមនោះក៏អាចបង្គាប់ឲ្យធ្វើការចាត់ចែងដែលកំណត់ក្នុងកថាខណ្ឌទី ៣ ខាងលើនេះបានដែរ ។

៥- បញ្ញត្តិនៃមាត្រា ៤០ (អំឡុងពេលសម្រាប់ប្តឹងជំទាស់) និង មាត្រា ៤១ (ការបំពេញសកម្មភាពប្តឹងជំទាស់ ក្រោយពីអំឡុងពេលសម្រាប់ប្តឹងជំទាស់បានកន្លងផុត) នៃច្បាប់នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងជំទាស់ដែលកំណត់ក្នុងមាត្រានេះ ។ បញ្ញត្តិនៃកថាខណ្ឌទី ៤ និង ទី ៥ នៃមាត្រា ៤៣ (នីតិវិធីនៃការចាត់ចែងរក្សាការពារ) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសេចក្តីបញ្ជាក់ជំបូងដែលកំណត់ក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ហើយបញ្ញត្តិនៃមាត្រា ៧១ (វិធីដាក់ប្រាតិភោគ និង ការប្តូរប្រាតិភោគ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះប្រាតិភោគដែលកំណត់ក្នុងកថាខណ្ឌទី ៣ នោះ ។

៦- បញ្ញត្តិនៃមាត្រា ៥៥៥ (ដីកាសម្រេចបង្គាប់ឲ្យធ្វើបដិទាន) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចលុបចោលនូវដីកាសម្រេចចាត់ចែងរក្សាការពារដែល

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

កំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤៣ (នីតិវិធីនៃការចាត់ចែងរក្សាការពារ) ខាងលើនេះ ដោយផ្អែកលើបណ្តឹងជំទាស់ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ។

## មាត្រា ៤៥.- ការលុបចោលការចាត់ចែងរក្សាការពារដោយសារការផ្លាស់ប្តូរស្ថានភាព

១- នៅក្រោយពេលដែលការចាត់ចែងរក្សាការពារ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៤៣ (នីតិវិធីនៃការចាត់ចែងរក្សាការពារ) នៃច្បាប់នេះ បានចូលជាស្ថាពរ ប្រសិនបើមានការរលត់មូលហេតុនៃការចាត់ចែងរក្សាការពារនោះ ឬ ការផ្លាស់ប្តូរផ្សេងទៀតនៃស្ថានភាព តុលាការអាចលុបចោលការចាត់ចែងរក្សាការពារនោះ តាមពាក្យសុំរបស់ជនដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ៤៤ (បណ្តឹងឧបាស្រ័យ) ខាងលើនេះ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន ។

២- បញ្ញត្តិពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៦ នៃមាត្រា ៤៣ (នីតិវិធីនៃការចាត់ចែងរក្សាការពារ) នៃច្បាប់នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះពាក្យសុំ និង ដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

៣- ជនដែលបានដាក់ពាក្យសុំឲ្យធ្វើការចាត់ចែងរក្សាការពារ អាចប្តឹងជំទាស់ចំពោះដីកាសម្រេចលុបចោលការចាត់ចែងរក្សាការពារ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះបាន ។

៤- ជនដែលបានដាក់ពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹងជំទាស់ចំពោះដីកាសម្រេចលើកចោលពាក្យសុំនោះបាន ។ បញ្ញត្តិពីកថាខណ្ឌទី ៣ ដល់កថាខណ្ឌទី ៥ នៃមាត្រា ៤៤ (បណ្តឹងឧបាស្រ័យ) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះករណីនេះ ។

៥- បញ្ញត្តិនៃមាត្រា ៥៥៥ (ដីកាសម្រេចឲ្យធ្វើបដិទាន) និង មាត្រា ៥៥៦ (អានុភាពនៃដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចលុបចោលការចាត់ចែងរក្សាការពារ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

## មាត្រា ៤៦.- ការគ្រប់គ្រង ការចាត់ចែងរក្សាការពារទ្រព្យសម្បត្តិ និង ការកំណត់ចំណុចត្រូវធ្វើដែលទាក់ទងនឹងការបីបាច់រក្សាក្នុងករណីមានពាក្យសុំឲ្យប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ

១- ក្នុងករណីមានពាក្យសុំទាមទារឲ្យប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅដែលកំណត់ក្នុងមាត្រា ២៤ (ការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ) នៃក្រមរដ្ឋប្បវេណី ប្រសិនបើមានការចាំបាច់ដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិរបស់សាមីខ្លួន ឬ បីបាច់រក្សាសាមីខ្លួន តុលាការអាចជ្រើសតាំង

អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ឬ អាចកំណត់ចំណុចត្រូវធ្វើដែលទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សាមីខ្លួន ឬ ការបើបាច់ក្សោសាមីខ្លួននោះ ចំពោះជនពាក់ព័ន្ធនឹងរឿងក្តីបានរហូតដល់ពេលដែលដីកាសម្រេចអំពីពាក្យសុំឲ្យប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅនោះ បង្កើតអានុភាពតាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិ ដោយមិនឲ្យដាក់ប្រាតិភោគ ។

២- បញ្ញត្តិពីមាត្រា ៣៧ (ការជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដោយតុលាការ) ដល់មាត្រា ៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ជាអាទិ៍) នៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដែលត្រូវបានជ្រើសតាំង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

៣- ក្នុងករណីមានពាក្យសុំទាមទារឲ្យប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ ប្រសិនបើមានការចាំបាច់ពិសេសដើម្បីរក្សាការពារទ្រព្យសម្បត្តិរបស់សាមីខ្លួន តុលាការអាចបង្គាប់ឲ្យសាមីខ្លួនស្ថិតនៅក្រោមអាណាព្យាបាលរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ដែលត្រូវបានជ្រើសតាំងដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះបាន ចំពោះសកម្មភាពដែលទាក់ទងនឹងទ្រព្យសម្បត្តិរបស់សាមីខ្លួននោះ លើកលែងតែសកម្មភាពដែលកំណត់ក្នុងវាក្យខណ្ឌទី ២ មាត្រា ២៦ (សិទ្ធិលុបចោលសកម្មភាព) នៃក្រមរដ្ឋប្បវេណី រហូតដល់ពេលដែលដីកាសម្រេចអំពីពាក្យសុំទាមទារឲ្យប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ បង្កើតអានុភាពតាមពាក្យសុំរបស់អ្នកដែលដាក់ពាក្យសុំទាមទារឲ្យប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅនោះ ។

៤- ដីកាសម្រេចដែលធ្វើឡើងដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវជូនដំណឹងទៅអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ។

៥- ប្រសិនបើដីកាសម្រេចត្រូវបានធ្វើឡើង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ តុលាការត្រូវជូនដំណឹងអំពីការណ៍នោះ ទៅសាមីខ្លួនដោយគ្មានការយឺតយ៉ាវ ។

៦- អំឡុងពេលសម្រាប់ប្តឹងជំទាស់ ចំពោះដីកាសម្រេចដែលធ្វើឡើងដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវគិតពីថ្ងៃដែលមានការជូនដំណឹងទៅអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៤ ខាងលើនេះ ។ ក្នុងករណីនេះ ប្រសិនបើអ្នកគ្រប់គ្រងទ្រព្យសម្បត្តិមានច្រើននាក់ ហើយអ្នកទាំងនោះបានទទួលការជូនដំណឹងនៅកាលបរិច្ឆេទខុសគ្នានោះ អំឡុងពេលសម្រាប់ប្តឹងជំទាស់ ត្រូវគិតពីថ្ងៃដែលមានការជូនដំណឹងចុងក្រោយ ។

៧- ប្រសិនបើដីកាសម្រេចត្រូវបានធ្វើឡើង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ សាមីខ្លួន និង អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ អាចលុបចោលនូវសកម្មភាពរបស់សាមីខ្លួនដែលទាក់ទងនឹងទ្រព្យសម្បត្តិ លើកលែងតែសកម្មភាពដែលកំណត់ក្នុងវាក្យខណ្ឌទី ២ នៃមាត្រា ២៦ (សិទ្ធិលុប



Kol

យោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៦ នៃមាត្រា ៤៣ (នីតិវិធីនៃការចាត់ចែងរក្សាការពារ) នៃច្បាប់នេះ និងថ្ងៃដែលមានការជូនដំណឹង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៤ នៃមាត្រានេះ ។

៦- ប្រសិនបើដីកាសម្រេចត្រូវបានធ្វើឡើង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ សាមីខ្លួននិងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ អាចលុបចោលបាននូវសកម្មភាពដែលកំណត់ក្នុងមាត្រា ៣០ (សិទ្ធិលុបចោលសកម្មភាព) នៃក្រមរដ្ឋប្បវេណី ក្នុងចំណោមសកម្មភាពទាក់ទងនឹងទ្រព្យសម្បត្តិដែលសាមីខ្លួនបានធ្វើ ដោយមិនបានទទួលការយល់ព្រមពីអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ។ បញ្ញត្តិស្តីពីការលុបចោលនូវសកម្មភាពរបស់ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីនេះ ។

## មាត្រា ៤៨.- ការព្យួរអំណាចមេបា ជាអាទិ៍ មុនពេលដែលដីកាសម្រេចឱ្យបង្កើតសុំកូនពេញលេញ បង្កើតអានុភាព

១-ក្នុងករណីដែលមានពាក្យសុំឱ្យចេញដីកាសម្រេចបង្កើតសុំកូនពេញលេញដែលកំណត់ក្នុងមាត្រា ១០០៧ (ទម្រង់នៃការបង្កើតសុំកូនពេញលេញ) នៃក្រមរដ្ឋប្បវេណី ប្រសិនបើមានការចាំបាច់ដើម្បីផលប្រយោជន៍របស់ជនដែលនឹងក្លាយជាកូនសុំ តុលាការអាចព្យួរការអនុវត្តកិច្ចការរបស់អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន របស់ជនដែលនឹងក្លាយជាកូនសុំនោះបាន តាមពាក្យសុំរបស់អ្នកដែលដាក់ពាក្យសុំបង្កើតសុំកូននោះ រហូតដល់ពេលដែលដីកាសម្រេចអំពីពាក្យសុំទាមទារឱ្យបង្កើតសុំកូនពេញលេញនោះបង្កើតអានុភាព ។ ក្នុងករណីនេះ ប្រសិនបើគ្មានអ្នកផ្សេងទៀតដែលមានអំណាចមេបា ឬ ដែលអនុវត្តកិច្ចការរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន តុលាការត្រូវជ្រើសតាំងអ្នកដែលអនុវត្តកិច្ចការនោះជំនួស ។

២- តុលាការអាចផ្លាស់ប្តូរអ្នកដែលអនុវត្តកិច្ចការជំនួស ដែលខ្លួនបានជ្រើសតាំងនោះពេលណាក៏បានដែរ ។

## មាត្រា ៤៩.- ការព្យួរការអនុវត្តកិច្ចការរបស់អ្នកមានអំណាចមេបា និង ការជ្រើសតាំងអ្នកធ្វើកិច្ចការជំនួស

១- ក្នុងករណីមានពាក្យសុំឱ្យប្រកាសការព្យួរ ឬ ការដកហូតអំណាចមេបាដែលកំណត់ក្នុងមាត្រា ១០៤៨ (ការប្រកាសការព្យួរ ឬ ការដកហូតអំណាចមេបា) នៃក្រមរដ្ឋប្បវេណី ប្រសិនបើមានការចាំបាច់ដើម្បីផលប្រយោជន៍របស់កូន តុលាការអាចព្យួរការអនុវត្តកិច្ចការរបស់អ្នកមានអំណាចមេបាបាន តាមពាក្យសុំរបស់អ្នកដាក់ពាក្យសុំនោះ រហូតដល់ពេលដែលដីកាសម្រេចអំពីពាក្យសុំឱ្យ

ប្រកាសការព្យួរ ឬ ការដកហូតអំណាចមេបា បង្កើតអាណាព្យាបាល ។ ក្នុងករណីនេះ ប្រសិនបើគ្មានអ្នកដែលមានអំណាចមេបាផ្សេងទៀតទេ តុលាការត្រូវជ្រើសតាំងអ្នកដែលអនុវត្តកិច្ចការនោះជំនួស ។

២- តុលាការអាចផ្លាស់ប្តូរអ្នកដែលអនុវត្តកិច្ចការជំនួសដែលខ្លួនបានជ្រើសតាំងនោះ នៅពេលណាក៏បានដែរ ។

## ជំពូកទី ៩
## បទប្បញ្ញត្តិពិសេសស្តីពីរឿងក្តីផ្សេងៗ
## ផ្នែកទី ១
## រឿងក្តីអាណាព្យាបាល និង ហិតូបត្ថម្ភ ជាអាទិ៍

### មាត្រា ៥០.- ការពិនិត្យដោយវេជ្ជបណ្ឌិត ជាអាទិ៍ ក្នុងករណីចាប់ផ្តើមអាណាព្យាបាលទូទៅ ជាអាទិ៍

ដើម្បីចេញដីកាសម្រេចប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ២៤ (ការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ) ឬ ដីកាសម្រេចប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ ដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ២៨ (ការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ) នៃក្រមរដ្ឋប្បវេណី តុលាការត្រូវស្តាប់មតិយោបល់ជំនាញរបស់វេជ្ជបណ្ឌិត ឬ ជនផ្សេងទៀតដែលអាចទទួលស្គាល់ថាសមរម្យអំពីស្ថានភាពស្មារតីរបស់សាមីខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលយល់ឃើញច្បាស់លាស់ថាមិនចាំបាច់ ។

### មាត្រា ៥១.- ការសួរសេចក្តីថ្លែងការណ៍របស់សាមីខ្លួន ក្នុងករណីចាប់ផ្តើមអាណាព្យាបាលទូទៅ ជាអាទិ៍

ដើម្បីចេញដីកាសម្រេចដែលកំណត់ក្នុងមាត្រា ៥០ (ការពិនិត្យដោយវេជ្ជបណ្ឌិត ជាអាទិ៍ ក្នុងករណីចាប់ផ្តើមអាណាព្យាបាលទូទៅ ជាអាទិ៍) ខាងលើនេះ តុលាការត្រូវផ្តល់ឱកាសឲ្យសាមីខ្លួនធ្វើសេចក្តីថ្លែងការណ៍ ។

### មាត្រា ៥២.- ការគិតពិចារណាអំពីយោបល់របស់កូន

នៅពេលដែលចេញដីកាសម្រេចកំណត់អំពីអ្នកមានអំណាចមេបាលើកូន ឬ ការចាត់ចែងចាំបាច់ដែលទាក់ទងនឹងការបីបាច់រក្សាកូន យោបល់របស់កូនត្រូវបានយកទៅពិចារណាថ្លឹងថ្លែងសមស្របទៅតាមអាយុ និង សភាពចាស់ទុំរបស់កូននោះ ។

ROYAUME DU CAMBODGE

### មាត្រា ៥៣.- ការគិតពិចារណាអំពីយោបល់របស់សាមីខ្លួន ក្នុងករណីដែលជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន

បញ្ញត្តិនៃមាត្រា ៥២ (ការគិតពិចារណាអំពីយោបល់របស់កូន) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចអំពីអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដែលកំណត់ក្នុងមាត្រា ១០៦៨ (អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានកំណត់ អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំង និង មូលដ្ឋាននៃការជ្រើសតាំង) នៃក្រមរដ្ឋប្បវេណី ។

## ផ្នែកទី ២
## រឿងក្តីបាត់ខ្លួន

### មាត្រា ៥៤.- ការដាស់តឿនជាសាធារណៈ

១- ការដាស់តឿនជាសាធារណៈដែលកំណត់ក្នុងមាត្រា ៤២ (ការដាស់តឿនជាសាធារណៈ) នៃក្រមរដ្ឋប្បវេណី ត្រូវធ្វើឡើងតាមវិធីផ្សាយជាសាធារណៈ ។

២- ការផ្សាយជាសាធារណៈ ត្រូវធ្វើដោយបិទប្រកាសនៅកន្លែងសម្រាប់បិទប្រកាសរបស់តុលាការ និងចុះផ្សាយនៅក្នុងព្រឹត្តិបត្ររបស់ក្រសួងយុត្តិធម៌ ។

៣- ប្រសិនបើយល់ឃើញថាសមរម្យ តុលាការអាចធ្វើការផ្សាយជាសាធារណៈតាមការចុះផ្សាយនៅក្នុងសារព័ត៌មានប្រចាំថ្ងៃ ឬ តាមវិធីផ្សេងទៀតដែលយល់ឃើញថាសមរម្យបាន ដោយបន្ថែមលើវិធីដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ ។

៤- ការផ្សាយជាសាធារណៈដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបញ្ជាក់អំពីចំណុចខាងក្រោមនេះ ៖

ក- ឈ្មោះ និង អាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ។

ខ- ឈ្មោះ និង អាសយដ្ឋានចុងក្រោយដែលត្រូវបានដឹង និង ថ្ងៃ ខែ ឆ្នាំកំណើតរបស់អ្នកអវត្តមាន ។

គ- កំណត់ថា អ្នកអវត្តមានត្រូវផ្តល់ព័ត៌មានអំពីការរស់នៅរបស់ខ្លួននៅមុនពេលចប់អំឡុងពេលនៃការដាស់តឿនជាសាធារណៈ ហើយបើមិនបានផ្តល់ព័ត៌មានមុនអំឡុងពេលនេះទេ អ្នកអវត្តមាននោះនឹងទទួលការប្រកាសអំពីការបាត់ខ្លួន ។

ឃ- កំណត់ថា ជនដែលដឹងអំពីការនៅរស់ ឬ មរណភាពរបស់អ្នកអវត្តមាន ត្រូវផ្តល់ព័ត៌មាន នៅមុនពេលចប់អំឡុងពេលនៃការដាស់តឿនជាសាធារណៈ ។



Kol

ង- ថិរវេលាអំឡុងពេលនៃការដោះស់តឿនជាសាធារណៈ ។

៥- អំឡុងពេលនៃការដោះស់តឿនជាសាធារណៈ ត្រូវមានមិនតិចជាង ៦ (ប្រាំមួយ) ខែ ក្នុងករណីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤១ (លក្ខខណ្ឌដើម្បីធ្វើការប្រកាសអំពីការបាត់ខ្លួន) នៃក្រមរដ្ឋប្បវេណី ហើយមិនតិចជាង ២ (ពីរ) ខែ ក្នុងករណីដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រាដដែល ។

## មាត្រា ៥៥.- ការផ្សាយជាសាធារណៈ និងការជូនដំណឹងអំពីការចូលជាស្ថាពរនៃដីកាសម្រេច

១- ប្រសិនបើដីកាសម្រេចប្រកាសអំពីការបាត់ខ្លួនចូលជាស្ថាពរ ក្រឡាបញ្ជីត្រូវផ្សាយជាសាធារណៈអំពីករណីនោះ និង ត្រូវជូនដំណឹងអំពីករណីនោះ ទៅបុគ្គលដែលទទួលបន្ទុកការងារអត្រានុកូលដ្ឋានរបស់ជនដែលទទួលការប្រកាសអំពីការបាត់ខ្លួននោះ ដោយគ្មានការយឺតយ៉ាវ ។

២- បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលដីកាសម្រេចលុបចោលនូវការប្រកាសអំពីការបាត់ខ្លួន ចូលជាស្ថាពរ ។

# ជំពូកទី ១០

# អវសានប្បញ្ញត្តិ

## មាត្រា ៥៦.- កាលបរិច្ឆេទនៃការអនុវត្តច្បាប់នេះ

ច្បាប់នេះ ត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១០

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ព.រ.ក/០៧១០/៥៩៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ហត្ថលេខា

អង្គ វង្ស វឌ្ឍនា

លេខ: ៥៤៥ ច.ល

...ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ កក្កដា ឆ្នាំ២០១០
...រាជរដ្ឋាភិបាល
... ឌិនកេន

២៥/១២...

## មាតិកា


**ជំពូកទី ១ បទប្បញ្ញត្តិទូទៅ** ..... ១

**មាត្រា ១.–** គោលដៅនៃច្បាប់នេះ ..... ១

**មាត្រា ២.–** គោលបំណងនៃច្បាប់នេះ ..... ១

**មាត្រា ៣.–** វិសាលភាពនៃច្បាប់នេះ ..... ១

**ជំពូកទី ២ តុលាការ** ..... ១

**ផ្នែកទី ១ សមត្ថកិច្ចសាលាជម្រះក្តី** ..... ១

**មាត្រា ៤.–** តុលាការដែលមានសមត្ថកិច្ច ..... ១

**មាត្រា ៥.–** ការកំណត់តុលាការដែលមានសមត្ថកិច្ច ..... ២

**មាត្រា ៦.–** ការបាត់បែងរឿងក្តីខុសសមត្ថកិច្ច ..... ២

**មាត្រា ៧.–** សមត្ថកិច្ចជាអាទិភាព និងការផ្ទេរ ..... ២

**មាត្រា ៨.–** ការពិនិត្យភស្តុតាងដោយធន្ទានុសិទ្ធិ ..... ៣

**មាត្រា ៩.–** បណ្តឹងជំទាស់ ..... ៣

**មាត្រា ១០.–** អានុភាពនៃដីកាសម្រេចផ្ទេរ ជាអាទិ៍ ..... ៣

**ផ្នែកទី ២ រចនាសម្ព័ន្ធនៃតុលាការ** ..... ៣

**មាត្រា ១១.–** ការជម្រះក្តីលើកទី ១ ដោយចៅក្រមមួយរូប ឬ ដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ..... ៣

**មាត្រា ១២.–** ការពិភាក្សានៃក្រុមប្រឹក្សាជំនុំជម្រះ ..... ៤

**មាត្រា ១៣.–** ការសម្រេចនៃក្រុមប្រឹក្សាជំនុំជម្រះ ..... ៤

**ផ្នែកទី ៣ ការដកហូតសមត្ថកិច្ចជំនុំជម្រះ បណ្តឹងជំទាស់ចិត្ត និងការដកខ្លួន** ..... ៤

**មាត្រា ១៤.–** ការដកហូតសមត្ថកិច្ចជំនុំជម្រះ បណ្តឹងជំទាស់ចិត្ត និងការដកខ្លួនរបស់ចៅក្រម ជាអាទិ៍ ..... ៤

**ជំពូកទី ៣ ជនពាក់ព័ន្ធ** ..... ៥

**មាត្រា ១៥.–** ជនពាក់ព័ន្ធ ..... ៥

**មាត្រា ១៦.–** សមត្ថភាពរបស់ជនពាក់ព័ន្ធ ..... ៥

**មាត្រា ១៧.–** សមត្ថភាពក្នុងការធ្វើសកម្មភាពនៃនីតិវិធី ការតំណាងដែលច្បាប់បានកំណត់សម្រាប់ជនដែលគ្មានសមត្ថភាពក្នុងការធ្វើសកម្មភាពនៃនីតិវិធី ..... ៥

**មាត្រា ១៨.–** សកម្មភាពនៃនីតិវិធីដែលធ្វើឡើងដោយអ្នកតំណាងដោយអាណត្តិ ..... ៦

**មាត្រា ១៩.–** លក្ខណសម្បត្តិនៃអ្នកតំណាងដោយអាណត្តិ ...... ៦

**មាត្រា ២០.–** ការបញ្ជាក់នូវសិទ្ធិតំណាងដោយអាណត្តិ ...... ៦

**មាត្រា ២១.–** ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីសិទ្ធិតំណាងដោយអាណត្តិនៅក្នុង ក្រមនីតិវិធីរដ្ឋប្បវេណី ...... ៧

**ជំពូកទី ៤ ប្រាក់ប្រដាប់ក្តី** ...... ៧

**មាត្រា ២២.–** បន្ទុកនៃប្រាក់ប្រដាប់ក្តី ...... ៧

**មាត្រា ២៣.–** ដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តី ...... ៨

**មាត្រា ២៤.–** ការអនុវត្តដោយបង្ខំអំពីប្រាក់ប្រដាប់ក្តី ...... ៨

**មាត្រា ២៥.–** ការបង់ប្រាក់ប្រដាប់ក្តីជំនួសជាមុន ...... ៩

**ជំពូកទី ៥ ការវិនិច្ឆ័យ** ...... ៩

**មាត្រា ២៦.–** របៀបដាក់ពាក្យសុំ និងចំណុចដែលត្រូវសរសេរក្នុងពាក្យសុំ ...... ៩

**មាត្រា ២៧.–** ការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ និងការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ .. ១០

**មាត្រា ២៨.–** ការទាញហេតុផលដោយផ្ទាល់មាត់ និងការសួរដោយឆន្ទានុសិទ្ធិ ...... ១០

**មាត្រា ២៩.–**ករណីយកិច្ចបង្ហាញខ្លួនរបស់សាមីខ្លួន ...... ១០

**មាត្រា ៣០.–** ការចូលរួមរបស់តំណាងអយ្យការ និងការជូនដំណឹង ...... ១០

**មាត្រា ៣១.–** ការចូលរួមក្នុងនីតិវិធីរបស់ជនពាក់ព័ន្ធនឹងផលប្រយោជន៍ ...... ១១

**មាត្រា ៣២.–** ការទទួលបន្តនូវនីតិវិធី ...... ១១

**មាត្រា ៣៣.–** ការមើលសំណុំរឿង ជាអាទិ៍ ...... ១១

**មាត្រា ៣៤.–** ការអនុវត្តដូចគ្នាតាមក្រមនីតិវិធីរដ្ឋប្បវេណី ...... ១២

**ជំពូកទី ៦ ការសម្រេចសេចក្តី** ...... ១២

**មាត្រា ៣៥.–** វិធីសម្រេចសេចក្តី ...... ១២

**មាត្រា ៣៦.–** ការជូនដំណឹងអំពីដីកាសម្រេច ...... ១២

**មាត្រា ៣៧.–** ការចូលជាស្ថាពរ និងការបង្កើតអានុភាពនៃដីកាសម្រេច ...... ១៣

**មាត្រា ៣៨.–** អានុភាពអនុវត្តនៃដីកាសម្រេច ...... ១៣

**ជំពូកទី ៧ បណ្តឹងឧទ្ធរណ៍ស្រ័យ** ...... ១៣

**មាត្រា ៣៩.–** បណ្តឹងជំទាស់ ...... ១៣

**មាត្រា ៤០.–** អំឡុងពេលសម្រាប់ប្តឹងជំទាស់ ...... ១៣

**មាត្រា ៤១.–** ការបំពេញនូវសកម្មភាពប្តឹងជំទាស់ ក្រោយពីអំឡុងពេលសម្រាប់ ប្តឹងជំទាស់បានកន្លងផុត ...... ១៤

**មាត្រា ៤២.**– នីតិវិធីនៃការជំនុំជម្រះលើបណ្តឹងជំទាស់ ..... ១៤

**ជំពូកទី ៨ ការចាត់ចែងរក្សាការពារ** ..... ១៥

**មាត្រា ៤៣.**– នីតិវិធីនៃការចាត់ចែងរក្សាការពារ ..... ១៥

**មាត្រា ៤៤.**– បណ្តឹងឧបាស្រ័យ ..... ១៦

**មាត្រា ៤៥.**– ការលុបចោលការចាត់ចែងរក្សាការពារដោយសារការផ្លាស់ប្តូរស្ថានភាព ..... ១៧

**មាត្រា ៤៦.**– ការគ្រប់គ្រង ការចាត់ចែងរក្សាការពារនូវទ្រព្យសម្បត្តិ និងការកំណត់ចំណុចត្រូវធ្វើដែលទាក់ទងនឹងការបីបាច់រក្សាក្នុងករណីមានពាក្យសុំឲ្យប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ ..... ១៧

**មាត្រា ៤៧.**– ការគ្រប់គ្រង ការចាត់ចែងរក្សាការពារនូវទ្រព្យសម្បត្តិ និងការកំណត់ចំណុចត្រូវធ្វើដែលទាក់ទងនឹងការបីបាច់រក្សា ក្នុងករណីមានពាក្យសុំឲ្យប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ ..... ១៩

**មាត្រា ៤៨.**– ការព្យួរអំណាចមេបា ជាអាទិ៍ មុនពេលដែលដីកាសម្រេចឲ្យបង្កើតសុំកូនពេញលេញ បង្កើតអានុភាព ..... ២០

**មាត្រា ៤៩.**– ការព្យួរការអនុវត្តកិច្ចការរបស់អ្នកមានអំណាចមេបា និងការជ្រើសតាំងអ្នកធ្វើកិច្ចការជំនួស ..... ២០

**ជំពូកទី ៩ បទប្បញ្ញត្តិពិសេសស្តីពីរឿងក្តីផ្សេងៗ** ..... ២១

**ផ្នែកទី ១ រឿងក្តីអាណាព្យាបាល និងហិតូបត្ថម្ភ ជាអាទិ៍** ..... ២១

**មាត្រា ៥០.**– ការពិនិត្យដោយវេជ្ជបណ្ឌិត ជាអាទិ៍ ក្នុងករណីចាប់ផ្តើមអាណាព្យាបាលទូទៅ ជាអាទិ៍ ..... ២១

**មាត្រា ៥១.**– ការសួរសេចក្តីថ្លែងការណ៍របស់សាមីខ្លួន ក្នុងករណីចាប់ផ្តើមអាណាព្យាបាលទូទៅ ជាអាទិ៍ ..... ២១

**មាត្រា ៥២.**– ការគិតពិចារណាអំពីយោបល់របស់កូន ..... ២១

**មាត្រា ៥៣.**– ការគិតពិចារណាអំពីយោបល់របស់សាមីខ្លួន ក្នុងករណីដែលជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន ..... ២២

**ផ្នែកទី ២ រឿងក្តីបាត់ខ្លួន** ..... ២២

**មាត្រា ៥៤.**– ការដាស់តឿនជាសាធារណៈ ..... ២២

**មាត្រា ៥៥.**– ការផ្សាយជាសាធារណៈ និងការជូនដំណឹងអំពីការចូលជាស្ថាពរនៃដីកាសម្រេច ..... ២៣

**ជំពូកទី ១០ អវសានប្បញ្ញត្តិ** ..... ២៣

**មាត្រា ៥៦.**– កាលបរិច្ឆេទនៃការអនុវត្តច្បាប់នេះ ..... ២៣